**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ឡុង មុន្នីកែវ** | **លោក ជិន ទណ្ណារ៉ា** |
| **ឡុង លីឌី** | |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៨ |
| ជំនាន់ទី ២១ | ឆ្នាំសរសេរសារណា ២០២១ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ឡុង បុប្ផាកែវ** និងនាងខ្ញុំឈ្មោះ **ឡុង លីឌី** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវកតញ្ញូតាធម៌ និងការគោរពដឹងគុណ យ៉ាងជ្រាលជ្រៅចំពោះ៖

**លោកឪពុក** និង **អ្នកម្តាយ** ដ៏មានគុណទាំងពីរ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែក្សារ ព្រម ទាំងទំនុកបម្រុងដល់យើងខ្ញុំទាំងពីរនាក់តាំងពីចាប់កំណើត រហូតដល់ធំដឹងក្តី។ លោកអ្នកមានគុណតែងតែ យកចិត្តទុកដាក់ចំណោយទាំងពេលវេលា ពុះពារគ្រប់ឧបសគ្គ ដើម្បីផ្គត់ផ្គង់ឲ្យកូនបានទទួលការអប់រំ តាំងពី ថ្នាក់បឋម រហូតដល់ថ្នាក់បរិញ្ញបត្រ។ លោកឪពុក អ្នកម្តាយ បានលះបង់ទាំងកម្លាំងកាយ និងចិត្ត ក្នុងការផ្តល់ ដំន្មាន ប្រៀនប្រដៅ និងចំណាយទ្រព្យសម្បត្តិដើម្បីឲ្យកូនៗទទួលបានអនាគតដ៏ល្អត្រចាស់ត្រចង់ ដោយមិន មានការរារែក និងប្រកបដោយព្រហ្មវិហាធម៌។ បើគ្មានអ្នកមានគុណទេ យើងទាំងពីរនាក់ ក៏មិនអាចទទួលបាន អ្វីៗមកដល់សព្វថ្ងៃនេះដែរ។ ព្រហ្មវិហារធម៌ និងគុណឧបការរបស់លោកទាំងពីរ ពិតជាមានតម្លៃធំធេងណាស់ គ្មានអ្វីកាត់ថ្លៃបានឡើយ។

**ឯកឧត្តមសាកវិលទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានដេប៉ាតឺម៉ង់ អនុប្រធានដេប៉ាតឺម៉ង់** និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ទាំងអស់ នៃសាកលវិទ្យា ល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**លោក លោកស្រី លោកគ្រូ អ្នកគ្រូ** ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន និងអប់រំឲ្យយើងខ្ញុំទាំងពីរនាក់ ក៏ដូចជា និស្សិតគ្រប់រូបឲ្យមានចំណេះដឹង ដើម្បីចូលរួមចំណែកកសាងធនធានមនុស្ស និងកសាង ប្រទេសជាតិទៅថ្ងៃអនាគត ។ ជាពិសេស លោកគ្រូ **ខិន វណ្ណារ៉ា** ដែលបានបង្ហាត់បង្រៀន ព្រមទាំងផ្តល់ការ ណែនាំក្រុមយើងខ្ញុំទាំងពីរនាក់ ក្នុងការសរសេរអត្ថបទសារណាស្រាវជ្រាវនេះ ដោយបានផ្តល់នូវគំនិត និងវិធី សាស្ត្រស្រាវជ្រាវតាំងពីចាប់ផ្តើមរហូតបានសម្រេចចេញជាលទ្ធផល។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់គ្មានអ្វីសងគុណក្រៅពីលើកម្រាមដៃដប់សំពះគោរពថ្លែងអគុណ និង សូមគោរពធ្វើការបួងសួងដល់ព្រះរតនត្រ័យ សូមលោកតាមថែរក្សា និងជួយដល់អ្នកមានគុណដែលបាន រៀបរាប់ខាងលើ សូមលោក ទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើន ព្រមទាំងពុទ្ធពរទាំងបួនប្រការ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

អស់រយៈពេល៤ឆ្នាំនៃការសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ មុខវិជ្ជា ដែលយើងទាំងពីរនាក់ចូលចិត្ត គឺមុខវិជ្ជា នីតិក្រុមហ៊ុន និងមានកិត្តិយសដ៏ថ្លៃថ្លានៅក្នុងឱកាសដ៏វិសេសវិសាល សម្រាប់ការតាក់តែង និងស្រាវជ្រាវប្រធានបទស្តីពី "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ" នៃសារណាបញ្ចប់ការសិក្សា។ គួរបញ្ជាក់ផងដែលថា វិស័យក្រុមហ៊ុនកំពុងតែមានសន្ទុះនៃការរីកដុសដាលយ៉ាងខ្លាំងនាពេលបច្ចុប្បន្ន និងមានសារៈសំខាន់ នៅក្នុងជិវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសអ្នកដែលមានបំណង់ចង់បង្កើតក្រុមហ៊ុន។ ដូច្នេះហើយ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ" មកធ្វើបទបង្ហាញ។

តាមរយៈប្រធានបទខាងលើ អាចជាគន្លឹះខ្លះៗ ដល់អ្នកដែលមានបំណងចង់បង្កើតក្រុមហ៊ុនពាណិជ្ជកម្មខ្នាតតូចដែលមានការទទួលខុសត្រូវ និងអាចធ្វើការសម្រេចដល់មានប្រសិទ្ធភាពមួយថាខ្លួនគួរជ្រើសរើសក្រុមហ៊ុនប្រភេទណា ដើម្បីប្រកបអាជិវកម្មឲ្យសាកសមទៅនឹងសមត្ថភាពរបស់ខ្លួន រួមទាំងដើមទុន និងជាពិសេសទៀតនោះគឺ រួមចំណែកជួយដល់ការសិក្សារបស់សិស្សនិស្សិតផងដែរ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមធ្វើការខ័ន្តីអភ័យទោសទុកជាមុន រាល់កំហុសខុសឆ្គងដោយអចេតនាត្រង់ប្រការណាមួយចំពោះការធ្វើកិច្ចការស្រាវជ្រាវបញ្ចប់ការសិក្សានេះ។ ប្រសិនបើកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនាក់ មានចន្លោះខ្វះខាតត្រង់ចំណុចណាមួយនោះ យើងខ្ញុំរីករាយស្វាគមន៍ រាល់ការកែរលម្អ និងរិះគន់ក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ និងសិស្សនិស្សិតគ្រប់រូបទាំងអស់។

# មាតិកា

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**ផ្នែកទី១៖ លក្ខខណ្ឌមូលដ្ឋាន** ........ ៣
១.១ ការព្រមព្រៀង ........ ៣
១.២ សមត្ថភាព ........ ៤
១.៣ កម្មវត្ថុ ........ ៤
១.៤ ដើមទុន និងភាគទុន ........ ៥
១.៥ ចំណុចផ្សេងៗ ........ ៦
១.៥.១ នាមករណ៍ ........ ៦
១.៥.២ សញ្ជាតិ ........ ៦
**ផ្នែកទី២៖ ទម្រង់តាមឆន្ទៈ និងតាមការចុះបញ្ជី** ........ ៧
១.១ ទម្រង់តាមឆន្ទៈ ........ ៧
១.២ ទម្រង់តាមការចុះបញ្ជី ........ ៨
១.៣ ការប្រកាសផ្សាយ ........ ៩

## ជំពូកទី២
## ដំណើរការនៃការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**ផ្នែកទី១៖ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន** ........ ១០
១.១ អ្នកគ្រប់គ្រង ........ ១០
១.២ ករណីយកិច្ច សិទ្ធ និងអំណាចរបស់សហកម្មសិទ្ធិករ ........ ១១
១.២.១ ករណីយកិច្ច ........ ១១
១.២.២ សិទ្ធ ........ ១៥

១.២.៣ អំណាច........................................................................................ ២០
**ផ្នែកទី៣៖ ការផ្លាស់ប្តូរសមាសភាពក្រុមហ៊ុន**..............................................................២៩
១.១. ការផ្លាស់ប្តូរសមាសភាពដោយបាត់បង់សហកម្មសិទ្ធិករ......................................២៩
១.១.១ ការផ្លាស់ប្តូរសមាសភាព ....................................................................២៩
១.២ ការផ្លាស់ប្តូរសមាសភាពឲ្យមានសហកម្មសិទ្ធិទូទៅថ្មី .........................................៣១
១.២.១ ការផ្លាស់ប្តូរដែលនាំឲ្យកើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅថ្មី .............................៣១
១.២.២ ការចូលខ្លួនសហកម្មសិទ្ធិករថ្មី និងការដកខ្លួនចេញពីសហកម្មសិទ្ធិ..............................៣១

## ជំពូកទី៣
## ការរំលោយ និងការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**ផ្នែកទី១៖ មូលហេតុ និងនីតិវិធីនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ** ...........................៣២
១.១ ការកំណត់មូលហេតុដែលបង្កឲ្យមានការរំលាយ............................................. ៣៣
១.១.១ មូលហេតុនៃការរំលោយ......................................................................... ៣៣
១.២ នីតិវិធីនៃការរំលោយក្រុមហ៊ុនសហកម្មសិទ្ធិ.................................................... ៣៤
**ផ្នែកទី២៖ ការជម្រះបញ្ជី** .................................................................................. ៣៥
១.១ អ្នកជម្រះបញ្ជី ........................................................................................៣៧
១.១.១ កាទូទាត់ក្នុងការជម្រះបញ្ជី ...................................................................៣៧
១.១.២ អានុភាពនៃការរំលាយក្រុមហ៊ុនកម្មសិទ្ធិទូទៅ.................................................៣៧
**សេចក្តីសន្និដ្ឋាន** ...................................................................................... ៣៩
**អនុសាសន៍**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

គ្រប់គម្រោងនៃផែនការជីវិតរបស់បុគ្គលទាំងអស់តែងតែមានការគិតគូររៀបចំពីអនាគតរបស់ខ្លួន បុគ្គលភាគច្រើនគិតថាការធ្វើការងារជាម្ចាស់លើខ្លួនឯងគឺជាការងាយស្រួល គ្មានសម្ពាធផ្លូវចិត្ត និងគាប់សង្កត់ផ្លូវកាយពីនរណាម្នាក់ឡើយ ផ្ទុយពីបុគ្គលមួយចំនួនទៀតពួកគេគិតថាការធ្វើការងារចាំយកតែប្រាក់ខែ គឺមានភាពងាយស្រួលជាង និងមានសេរីភាពពេញទី មិនមានភាពស្មុកស្មាញទៅវិញ។ ការងារដែលធ្វើជាម្ចាស់លើខ្លួនឯងគឺ សំដៅទៅដល់ការប្រកបកិច្ចការរកស៊ី និងធ្វើជំនួញពាណិជ្ជកម្មនានា។ ពាណិជ្ជករដែលគ្រប់គ្រងពាណិជ្ជកម្មត្រូវតែជាបុគ្គលដែលមាន ធនធាន ចំណេះដឹង គួបផ្សំជាមួយសមត្ថភាព តាមផ្លូវច្បាប់ទើបមានសិទ្ធិប្រកបអាជីវកម្មស្របច្បាប់បាន។

គួរបញ្ជាក់ផងដែរថា នៅក្នុងឆ្នាំ១៩៩៥ ប្រទេសកម្ពុជាបានអនុម័តច្បាប់មួយស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលយកគំរូតាមច្បាប់បារាំង។ ច្បាប់នេះចាប់កំណើតដំបូងគេនៅប្រទេសកម្ពុជាដែលទាក់ទងនឹងរឿងពាណិជ្ជកម្ម មុននឹងច្បាប់ដទៃៗទៀតត្រូវបានអនុម័ត ដូចជាច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មជាដើម។ នៅពេលដែលរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដែលទទួលបានលក្ខណៈសម្បត្តិស្របច្បាប់នោះ អាចសហការគ្នាដោយធ្វើការបណ្តាក់ទុនបង្កើតជាក្រុមហ៊ុនមួយ ក្នុងគោលដៅធ្វើប្រតិបត្តិការពាណិជ្ជកម្មដើម្បីរកប្រាក់ចំណេញរួមគ្នា។ ជាក់ស្តែងដូចដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ មាត្រា ៨ បានកំណត់ថា ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើនដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬសកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជកិច្ចរួមក្នុងគោលបំណងរកប្រាក់ចំណេញ។ តួយ៉ាងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ តម្រូវឲ្យមានម្ចាស់ភាគហ៊ុនចាប់ពីនាក់ឡើងទៅ។ តែប្រសិនបើមានម្ចាស់ហ៊ុនតែម្នាក់ នោះហៅថាសហគ្រាសឯកបុគ្គល។ ជាទូទៅកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចធ្វើឡើងជាលាយលក្ខណ៍អក្សរក៏បាន ឬក៏ធ្វើត្រឹមតែផ្ទាល់មាត់ក៏បាន។ ចំពោះដើមទុនដែលយកមករកស៊ីជាមួយគ្នា ក្នុងប្រភេទក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទៅនេះ គឺដាក់អាចជាសាច់ប្រាក់ ជាទ្រព្យសម្បត្តិ ជាចំណេះដឹង ឬមួយជាជំនាញក៏បាន។ ហើយរយៈពេលនៃកិច្ចសន្យាបង្កើតក្រុមហ៊ុននេះអាចធ្វើឡើងដោយមានរយៈពេលកំណត់ក៏បាន និងមិនកំណត់ក៏បានដូចគ្នា។ ជាក់ស្តែងនៅប្រទេសកម្ពុជាមានក្រុមហ៊ុនពាណិជ្ជកម្មជាច្រើនប្រមាណ ១,០៩០៤ ដែលជាក្រុមហ៊ុនបានចុះបញ្ជីសាឡើងវិញ និងមានក្រុមហ៊ុនថ្មីតំណាងការិយាល័យ និងសាខាក្រុមហ៊ុនបរទេសចំនួន ២,៩៣៧ ក្រុមហ៊ុនទៀត តាមរយៈរបាយការណ៍សុបរបស់ក្រសួងពាណិជ្ជកម្មក្នុងឆ្នាំ ២០១៦។ មួយវិញទៀតនៅក្នុងប្រទេសកម្ពុជារបស់យើង ភាគច្រើនគេនិយមទៅលើក្រុមហ៊ុនមូលធន ជាជាងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទៅទៀត។ នេះហើយជាបញ្ហាដែលត្រូវសង្កត់ធ្ងន់គួរឲ្យកត់សម្គាល់ ថាតើហេតុអ្វីបានជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនសូវជាពេញនិយាមជាងក្រុមហ៊ុនដទៃ? ដោយសារតែមើលឃើញនូវបញ្ហានេះទើប បង្កជាការផ្តួចផ្តើមគំនិតរបស់យើងខ្ញុំក្នុងការជ្រើសរើសយកក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មកបកស្រាយ ព្រោះថាក្រុមហ៊ុននេះក៏ជាប្រភេទក្រុមហ៊ុនខ្នាតតូចដែរ។ បែបនេះហើយទើបញ៉ាំងឲ្យមានការលិចឡើងនូវចម្ងល់ថា តើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះមានទម្រង់ អ្វីខ្លះ? តើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះមានលក្ខណៈពិសេស យ៉ាងដូចម្តេចខ្លះ?

ដើម្បីជាស្ពានឈានដល់ការស្រាយចម្ងល់របស់ប្រធានបទខាងលើ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងវិភាគ ទៅលើឯកសារច្បាប់ និងបទដ្ឋានគតិយុត្ត ក៏ដូចជាឯកសារដទៃដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម ជាពិសេសច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដើម្បីធ្វើការបកស្រាយដោយបែងចែកចេញជាប្លង់គោលមួយដូចខាងក្រោម៖ ជំពូកទី១៖ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ជំពូកទី២៖ ដំណើរការនៃការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ជំពូកទី៣៖ ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។

ក្រោយពីការបែងចែកប្លង់ខាងលើនេះរួចមក យើងក៏បានលើកយកនូវចំណុចសំខាន់ៗ នៃលក្ខណៈរបស់ក្រុមហ៊ុនសិទ្ធិទូទៅមកធ្វើការបកស្រាយ ក្នុងគោលដៅទាញចេញជាចម្លើយ នៃបញ្ហាដែលបានចោទខាងលើ។ យើងខ្ញុំសង្ឃឹមថាតាមរយៈការស្រាវជ្រាវប្រធានបទមួយនេះ នឹងអាចជំនួយដល់ការសិក្សារបស់សិស្សនិស្សិតដែលស្រឡាញ់ចូលចិត្ត មុខវិជ្ជានេះជាពិសេសអ្នកដែលមានបំណងចង់បង្កើតក្រុមហ៊ុនខ្នាតតូច តែមិនដឹងថាគួរជ្រើសរើសយកប្រភេទក្រុមហ៊ុនមួយណាឲ្យបានត្រឹមត្រូវ ក៏ដូចជាទទួលបានចំណេះដឹងដែលទាក់ទង នឹងប្រធានបទនេះផងដែរ។ ដើម្បីកុំឲ្យខាតពេលវេលាយូរសូមលោកអ្នកបើកទៅទំព័របន្ទាប់យើង នឹងនាំអារម្មណ៍លោកអ្នកក្នុងការស្រាយបំភ្លឺនូវចម្ងល់ទាំងឡាយឲ្យកាន់តែជាក់ច្បាស់។

# ជំពូកទី១
# ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ជាដំបូងមុនធ្វើការបកស្រាយពីការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅយើងត្រូវស្វែងយល់ថាអ្វីទៅ ជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ យោងតាមមាត្រា ៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅគឺ ជាកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើនដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិចំណេះដឹង ឬសកម្មភាពរបស់បុគ្គលទាំងនោះដើម្បីប្រកបពាណិជ្ជកិច្ចរួមក្នុងគោលបំណងរកប្រាក់ចំណេញ[1]។ ជាទូទៅក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបានគេស្គាល់ថា ជាទម្រង់អាជីវកម្មមួយដែលវិវឌ្ឍពីទម្រង់អាជីវកម្មឯកកម្មសិទ្ធិនៅពេលណាដែលគេចង់ពង្រីកអាជីវកម្ម ប៉ុន្តែភាគទុនឬជំនាញរបស់ម្ចាស់អាជីវកម្មម្នាក់ៗមានកម្រិតលើកលែងតែកាតព្វកិច្ចក្នុងការសងបំណុលរបស់ក្រុមហ៊ុនលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនដោយគ្មានកម្រិត ។ គេរួមដៃគ្នាជាមួយដៃគូរម្នាក់ ឬច្រើននាក់ដើម្បីបង្កើនឲ្យមានដើមទុនច្រើនដែលទុននោះគេមិនអាចរកបានតែម្នាក់ឯងទេ។ គេក៏អាចត្រូវការអ្នកដែលមានបំណិន ឬជំនាញខ្លះសម្រាប់អាជីវកម្មមកធ្វើជាដៃគូរួមគ្នារកស៊ីដែរ។ ជាក់ស្តែងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ភាគច្រើនជា ក្រុមហ៊ុននាំចេញនាំចូល, ចែកចាយ, លក់រាយ, សេវាកម្ម, ផលិតកម្ម, ផ្នែកគណនេយ្យ, ផ្នែកច្បាប់ (ក្រុមហ៊ុនមេធាវី), ផ្នែក សុខាភិបាល (គ្លីនិក, មន្ទីរពេទ្យ) ជាដើមដែលរួមគ្នាផ្នែកចំណេះដឹង, ជំនាញ, ផ្នែកហិរញ្ញវត្ថុ និងទ្រព្យសកម្មផ្សេងៗដើម្បីធ្វើពាណិជ្ជកិច្ចជាមួយគ្នាក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ និងទទួលខុសត្រូវបំណុលរួមគ្នា។

ក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវឆ្លងកាត់លក្ខខណ្ឌមួយចំនួនស្របតាមច្បាប់សហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។ បុគ្គលដែលមានបំណងចង់បង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវតែបំពេញនូវលក្ខខណ្ឌដែលច្បាប់នេះបានតម្រូវ។

## ផ្នែកទី១៖ លក្ខខណ្ឌមូលដ្ឋាន

ជាទូទៅ លក្ខខណ្ឌមូលដ្ឋានក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺត្រូវធ្វើកិច្ចសន្យាដែលមានទម្រង់ជាលាយលក្ខអក្សរក៏បាន ឬផ្ទាល់មាត់ក៏បាន ដូចមានចែងក្នុង មាត្រា៩ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម[2]។ ការធ្វើកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ តាមកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ នេះជូនកាលអាចហៅបានថាជា លិខិតបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ការធ្វើកិច្ចព្រមព្រៀងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះគឺ បង្ហាញនូវលក្ខណៈ និងគោលបំណងរបស់អាជីវកម្ម នាមករណ៍ អាសយដ្ឋាន ចំនួនប្រាក់ដែលបានវិនិយោគ និងវិធីបែងចែកប្រាក់ចំណេញ ។

### ១.១ ការព្រមព្រៀង

ការព្រមព្រៀងរបស់សហកម្មសិទ្ធិករក៏មានសារៈសំខាន់ខ្លាំងណាស់ដែល ពីព្រោះថាក្នុងការបង្កើត ក៏ដូចជាក្នុងដំណើរការ និងការសម្រេចចិត្តលើកិច្ចការអ្វីមួយនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ជាទូទៅការព្រមព្រៀងកើត

[1] ច្បាប់សហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៨។

[2] ច្បាប់សហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៩។

ឲ្យមានឡើង ស្របពេលនឹងក្នុងការបង្កើតកិច្ចសន្យា ក្នុងនេះផងដែរ នៅពេលដែលសហកម្មសិទ្ធិករទូទៅទាំងអស់មានឆន្ទៈស្របគ្នាបង្កើតឲ្យមានការព្រមព្រៀងកើតមានឡើង នៅពេលធ្វើកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ប្រសិនបើករណីមិនមានការព្រមព្រៀងគ្នានោះនឹងមិនមានការកើតឡើងនូវកិច្ចសន្យាក្រុមហ៊ុន នោះឡើយ។ ម៉្យាងវិញទៀត ក្នុងករណីដែលកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ បានចែងនៅកិច្ចព្រមព្រៀងដោយសហកម្មសិទ្ធិករទូទៅនីមួយពីការព្រមព្រៀងសន្យាថា នឹងធ្វើអ្វី ផ្តល់អ្វីខ្លះដល់ក្រុមហ៊ុន(ភាគទុន) បើសហកម្មសិទ្ធិករបានសន្យា មានការព្រមព្រៀងក្នុងសន្យាហើយនឹងត្រូវគោរពតាមកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ បើពុំដូច្នេះទេ នឹងអាចមានការខាតបង់ទៅកាន់ក្រុមហ៊ុនសហកម្មសិទ្ធិក៏ដូចជាធ្វើឲ្យមានបញ្ហាទៅដល់ដំណើរការរបស់ក្រុមហ៊ុនជាមិនខាន់។

### ១.២ សមត្ថភាព

សមត្ថភាពរបស់សហកម្មសិទ្ធិករទូទៅ ពុំចាំបាច់ជាពាណិជ្ជករនោះទេ បុគ្គលអាចមានឋានៈជាពាណិជ្ជករ ក៏បានមិនមែនជាពាណិជ្ជករក៏បាន ពីព្រោះ ក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅប្រកបពាណិជ្ជកិច្ចភាគច្រើនជាប្រភេទអាជីវកម្មខ្នាតតូច ហើយសហកម្មសិទ្ធិករទូទៅទាំងអស់នោះបង្កើតឡើងក្នុងគោលបំណងរកប្រាក់ចំណេញដែលមានលក្ខណៈរូបភាពខ្នាតតូច ហើយភាគច្រើនទៀតនោះជាក្រុមហ៊ុនគណនេយ្យ គ្លីនិកខ្នាតតូច ក្រុមហ៊ុនកាត់សម្លៀកបំពាក់ក្រុមហ៊ុនមេធាវី មន្ទីពេទ្យ ឬក្រុមហ៊ុននាំចេញ នាំចូលជាដើម។ ការដែលមិនកំណត់បែបនេះក៏ដោយសារ ចង់បើកទូលាយ ក៏ដូចជាលើកទឹកចិត្តនិងឲ្យមានការ រីកចម្រើនខាងវិស័យពាណិជ្ជកម្ម ដែលជាឱកាសក្នុងការពង្រីកវិស័យសេដ្ឋកិច្ច ទើបក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះឡើងឲ្យមានភាពងាយស្រួលដល់បុគ្គលគ្រប់រូប បើទោះបីជាបុគ្គលនោះមិនមែនជាពាណិជ្ជករក៏ដោយ។

### ១.៣ កម្មវត្ថុ

កម្មវត្ថុនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានបំណងទូទៅ និងទំហំនៃសកម្មភាពដែល ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវអនុវត្តដើម្បីឲ្យសម្រេចគោលបំណងទូទៅរបស់ខ្លួន។ គោលបំណងទូទៅរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺស្វែងរកប្រាក់ចំណេញ។ កម្មវត្ថុដែលថ្លែងពីទំហំនៃសកម្មភាពរបស់ក្រុមហ៊ុនគឺ ការថ្លែងរាយបញ្ជីនូវសកម្មភាពដែលក្រុមហ៊ុនត្រូវអនុវត្ត។ ការថ្លែងរាយបញ្ជីនូវសកម្មភាពរបស់ក្រុមហ៊ុននេះធ្វើឡើងដើម្បី ឲ្យមន្ត្រីចុះបញ្ជីដឹងថាសកម្មភាពណាខ្លះទៀតដែលគ្មានការហាមឃាត់ ។ ក្នុងករណី ដែលក្រុមហ៊ុនដែលមានកម្មវត្ថុបើកកន្លែងរកស៊ីផ្លូវភេទ ឬកន្លែងលក់សារធាតុញៀនដែលខុសទៅនឹងច្បាប់បានចែងមិនអាចចុះបញ្ជីបានទេព្រោះជាកម្មវត្ថុមិនស្របច្បាប់ ។ សម្រាប់ទំហំនៃសកម្មភាពរបស់ក្រុមហ៊ុនអាចរាយនូវមុខបញ្ជីសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនខ្លួនបានច្រើនប្រភេទ។ ចំពោះករណីបើក្រុមហ៊ុនមួយមានគោលបំណងចម្បងរកស៊ីខាងលក់ឧបករណ៍ផ្ទះបាយ ដោយអាចរាយនៅ ក្នុងកម្មវត្ថុរបស់ខ្លួននូវបញ្ជីសកម្មភាពជា អាជីវកម្មសំណង់ ភោជនីយដ្ឋាន ភាពយន្ត។ល។ ការរាយខុសនូវគោលបំណងចម្បងរបស់ក្រុមហ៊ុនបែបនេះដោយក្រុមហ៊ុនគិតថា បើថ្ងៃណាមួយក្រហ៊ុនមានការផ្លាស់ប្តូរអាជីវកម្មរបស់ខ្លួននោះគេមិនចាំបាច់កែប្រែ

លក្ខន្តិកៈនិងចុះបញ្ជីម្តងទៀតនូវវិសោធនកម្មលក្ខន្តិកៈជាមួយមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ដែលតម្រូវដោយមាត្រា ១៨ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្មឡើយ[3]។

### ១.៤ ដើមទុន និងភាគទុន

ដើមទុនរបស់ក្រុមហ៊ុនសហសកម្មសិទ្ធិទូទៅ ត្រូវគិតជាសាច់ប្រាក់, វត្ថុ (ចលន ឬអចលនវត្ថុ), ចំណេះដឹង, ឬសេវកម្ម ដែលភាគទុនទាំងនោះ ត្រូវគិតជាសាច់ប្រាក់និងរូបិយប័ណ្ណជាតិ(ប្រាក់រៀល)។ វិភាគទានទាំងនោះនឹងក្លាយជាកម្មសិទ្ធិរបស់ក្រុមហ៊ុនដែលជាផ្នែកមួយនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនផងដែរ។ ដើមទុនជាចំនួន នឹង ផ្តល់ តែទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានកាប្រែប្រួលទៅតាមការរីកចម្រើន ឬមានការខាតបង់ទៅតាមស្ថានភាពនៃអាជីវកម្ម។ យោងតាមមាត្រា ២១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានឲ្យនិយមន័យដើមទុនថា ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួមមានទាំងភាគទុនជាសាច់ប្រាក់ និងជាវត្ថុ។ ភាគទុនជាវត្ថុត្រូវវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការវាយតម្លៃនោះ។ ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនត្រូវរាប់បញ្ចូលភាគទុនជាចំណេះដឹង ជាសេវា ឬភាគទុនជាសកម្មភាពទេ[4]។ ដើមទុន នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺបានកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិ ដែលចូលរួមដោយសហកម្មសិទ្ធិករទូទៅទាំងអស់ដើម្បីចាប់ផ្តើមធ្វើអាជីវកម្មរបស់ពួកគេ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមានភាគទុនដូចជា សាច់ប្រាក់ វត្ថុ(ចលនឬអចលនវត្ថុ) សេវ៉ា ឬសកម្មភាពជាដើម ។ ការបង់ភាគទុនជាសាច់ប្រាក់មានភាពងាយស្រួលទេ ដោយគ្រាន់ផ្ទេរតែសាច់ប្រាក់ទៅក្នុងគណ នេយ្យរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ប៉ុន្តែសម្រាប់ភាគទុនជាចលនវត្ថុ ឬអចលនវត្ថុតម្រូវឲ្យមានការធ្វើលិខិតផ្ទេរសិទ្ធិពីសហកម្មសិទ្ធិករនោះទៅឲ្យក្រុមហ៊ុនបានក្លាយជាអ្នកកាន់កាប់ ហើយក្រុមហ៊ុនត្រូវតែធ្វើការកាន់កាប់លើចលនវត្ថុនោះដើម្បីឲ្យសិទ្ធិនោះកាន់តែមានប្រសិទ្ធិភាពសម្រាប់ពេលតតាំងជាមួយតតិយជន នៅពេលមានការទាមទារផងដែរ។ ចំពោះការផ្ទេរទ្រព្យសម្បត្តិជាចលនវត្ថុ និង អចលនវត្ថុទៅឲ្យក្រុមហ៊ុនៈ គឺដើម្បីធានាថាសហកម្មសិទ្ធិករដែលជាអ្នកចូលភាគទុនជាវត្ថុនោះបង្ហាញពីឆន្ទៈក្នុងកាចូលភាគទុនទៅឲ្យក្រុមហ៊ុនក្លាយជាម្ចាស់ទ្រព្យនោះ ប៉ុន្តែបញ្ហានៅត្រង់ថាការផ្ទេរ អចលនវត្ថុ គឺផ្ទុយពីការផ្ទេរចលនវត្ថុ ត្រង់ថាការធ្វើលិខិតផ្ទេរសិទ្ធិ មិនអាចធ្វើឲ្យអចលនវត្ថុនោះក្លាយជាកម្មសិទ្ធិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិបានទេ មានតែការចុះបញ្ជីសុរិយាដីទេដែលអាចធ្វើឲ្យសហកម្មសិទ្ធិនោះក្លាយជាម្ចាស់លើអចលនវត្ថុនោះបាន។ នេះជាលក្ខខណ្ឌគតិយុត្តដាច់ខាតដើម្បីឲ្យអ្នកទទួលអចលនវត្ថុនោះមានសិទ្ធិអាទិភាពលើតតិយជនដែលមកទាមទាលើអចលនវត្ថុនោះ ដោយយោងតាមមាត្រា ១៣៤ នៃក្រមរដ្ឋប្បវេណី បានចែងថា អនុប្បទាននូវសិទ្ធិប្រត្យក្សលើចលនវត្ថុទៅបុគ្គលណាមួយ មិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានផ្ទេរសិទ្ធិក្នុងការកាន់កាប់ចលនវត្ថុទៅបុគ្គលនោះទេ[5]។ ទោះបីជាច្បាប់សហគ្រាសពាណិជ្ជកម្ម មិនទទួលស្គាល់ក្រុមហ៊ុនសហកម្មសិទ្ធិ

[3] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦ ទំព័រ១០៨, ១០៩។

[4] ច្បាប់សហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២១។

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧មាត្រា ១៣៤។

ទូទៅដែលមិនចុះបញ្ជីជាក្រុមហ៊ុននីតិបុគ្គលក្តីក៏ច្បាប់នៅតែទទួលស្គាល់ក្រុមហ៊ុនសហកម្មសិទ្ធិនេះ ជាក្រុមហ៊ុនសង្គោមចង្គោមមនុស្សព្រោះដើម្បីសេរីភាពក្នុងការជ្រើសរើសទម្រង់ក្រៅប្រព័ន្ធនៃអាជីវកម្មផងដែរ ។ បើសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលចុះបញ្ជីដែលច្បាប់សហគ្រាសពាណិជ្ជកម្មទទួលស្គាល់ជា ក្រុមហ៊ុននីតិបុគ្គលនោះ ក្នុងការផ្ទេរសិទ្ធិលើវត្ថុនានា រួមទាំងអចលននិងចលនវត្ថុមិនមានបញ្ហាចោទទេដោយគ្រាន់តែចុះបញ្ជីទ្រព្យសម្បត្តិក្នុងនាមនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅជាការស្រេច[6] ។

## ១.៥ ចំណុចផ្សេងៗ

### ១.៥.១ នាមករណ៍

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានច្បាប់សហគ្រាសពាណិជ្ជកម្មទទួលស្គាល់ជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅលុះត្រាតែបានចុះបញ្ជីពាណិជ្ជកម្មហើយក្នុងនាមជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវតែមានឈ្មោះ និងសញ្ជាតិ។ ក្នុងច្បាប់ស្តីពីច្បាប់សហគ្រាសពាណិជ្ជកម្ម តាមមាត្រា ១៤ បានបកស្រាយថា រាល់ឈ្មោះរបស់ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវដាក់បញ្ចូលនូវឈ្មោះរបស់សមាជិករបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅម្នាក់ ឬច្រើននាក់ហើយនៅខាងក្រោមនាមករណ៍នោះត្រូវបន្ថែមពាក្យថា«ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ»[7]។ ក្នុងពេលធ្វើពាណិជ្ជកម្មឬអាជីវកម្មក្រុមហ៊ុនសហកម្មសិទ្ធិនោះត្រូវបើប្រាស់នាមករណ៍របស់ខ្លួន។ គួរកត់សម្គាល់ថា ឈ្មោះរបស់សហកម្មសិទ្ធិករគឺជាផ្នែកមួយយ៉ាងសំខាន់ ដែលគេអាចស្គាល់ច្បាស់ នោះគេច្រើននិយាយពី យីហោក្រុមហ៊ុន ជាង នាមករណ៍ក្រុមហ៊ុន ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ក្នុងការដាក់ឈ្មោះក្រុមហ៊ុន កាលណាឈ្មោះនោះជាការផ្សំផ្គុំឡើង ឈ្មោះសមាជិកទាំងឡាយរបស់ក្រុមហ៊ុន រឺឯពាក្យ នាមករណ៍ក្រុមហ៊ុនវិញ គេអាចយកម្មវត្ថុមកផ្គុំគ្នា ឬយកពាក្យណាដែលមានការការវិវត្តមួយដំណាក់កាលទៀតដោយគេភាគច្រើនតែនិយាយ ពីនាមករណ៍ក្រុមហ៊ុនជាង និយាយពីយីយោក្រុមហ៊ុន[8]។ ឧទាហរណ៍ លោក A និង លោក B បានបង្កើតទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមួយ មានឈ្មោះថា CC Computer ដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ម្យ៉ាងតៀតនៅខាងចុងនៃឈ្មោះក្រុមហ៊ុនត្រូវតែដាក់ “ S.N.C., & Co.,” ដើម្បីសម្គាល់ពីទម្រង់ក្រុមហ៊ុនផងដែរ។

### ១.៥.២ សញ្ជាតិ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលធ្វើពាណិជ្ជកិច្ចនៅព្រះរាជាណាចក្រកម្ពុជាចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសកម្ពុជាមានសញ្ជាតិបរទេស ឬអាចមានសញ្ជាតិជាកម្ពុជា បើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះចង់បានសញ្ជាតិជាកម្ពុជា តាមច្បាប់សហគ្រាសពាណិជ្ជកម្ម ត្រង់មាត្រា ១៣ បានលើកឡើងថាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចទទួលបាននូវនីតិបុគ្គលិកលក្ខណៈសញ្ជាតិខ្មែរបានដោយមានលក្ខខណ្ឌចំនួនពីរ រួមមាន៖ (ក) បានបកស្រាយថា ក្រុមហ៊ុនសហកម្មសិទ្ធិសហកម្មទូទៅនោះ ត្រូវចុះបញ្ជី អាស័យដ្ឋាននៃការិយាល័យរបស់ខ្លួនផ្ទាល់ ដោយការិយាល័យចុះបញ្ជី

[6] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦ ទំព័រ ១១៣, ១១៤, ១១៥, ១១៦,១១៧។

[7] ច្បាប់សហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១៤។

[8] ច្បាប់ពាណិជ្ជកម្ម, កៅ មុយថង, ឆ្នាំ២០១៥, ទំព័រ១៩៥។

នោះនៅក្នុងសេចរ៍មានទុន៤០%។ សហកម្មសិទ្ធិករខ្មែរទទួលខុសត្រូវខាងទីផ្សារនៅប្រទេសកម្ពុជារីឯសហកម្មសិទ្ធិករកូរ៉េទទួលខុសត្រូវប្រមូលទិញ និងនាំចូលសំលៀកបំពាក់ ក៏ដូចជាក្រណាត់សំរាប់កាត់សំលើកបំពាក់មកប្រទេសខ្មែរ និង (ខ) ចែងអំពី អំពីអត្ថប្រយោជន៍ក្នុងក្រុមហ៊ុនចាប់ពី៥១ (ហាសិបមួយភាគរយ) ភាគរយត្រូវបានកាន់កាប់ ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលមានសញ្ជាតិខ្មែរ[9]។

- លក្ខខណ្ឌទីមួយគឺ សម្រាប់ឲ្យក្រុមហ៊ុនសហកម្មសិទ្ធិមួយមានសញ្ជាតិជាខ្មែរ គឺក្រុមហ៊ុននោះត្រូវមានការិយា ល័យចុះបញ្ជីនៅក្នុងប្រទេសខ្មែរ។ ក្នុងអត្ថន័យនេះ មានន័យថា ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវតែងតាំងភ្នាក់ងារចុះបញ្ជី មួយដែលមានការិយាល័យចុះបញ្ជីនៅប្រទេសខ្មែរ។ នៅក្នុងការអនុវត្តសព្វថ្ងៃនេះ ក្រុមហ៊ុននៅប្រទេសកម្ពុជាចុះបញ្ជីអាស័យដ្ឋាននៃការិយាល័យរបស់ខ្លួនផ្ទាល់[10]។

- លក្ខខណ្ឌទីពីរគឺ ទីកន្លែងអាជីវកម្មត្រូវស្ថិតនៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ មនុស្សពីរនាក់បានព្រមព្រៀងគ្នាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមួយនាំចូលរថយន្តពីសហរដ្ឋអាមេរិក មកលក់នៅប្រទេសខ្មែរ។ សហកម្មសិទ្ធិករខ្មែរមានទុន ៦០% ចំណែកឯសហកម្មសិទ្ធិករអាមេរិកមានទុន ៤០%។ សហកម្មសិទ្ធិករខ្មែរទទួលខុសត្រូវខាងទីផ្សារនៅប្រទេសកម្ពុជា រីឯសហកម្មសិទ្ធិករអាមេរិកទទួលខុសត្រូវប្រមូលទិញ និងនាំចេញរថយន្ត មកប្រទេសខ្មែរ ។ ចំណែកផលប្រយោជន៍នេះត្រូវសមាមាត្រនៃចំណែកទុនរបស់ខ្លួននៅក្នុងក្រុមហ៊ុន។ ឧទាហរណ៍៖ បើក្រុមហ៊ុនមានទុនចុះបញ្ជីរបស់ខ្លួន ២០០ លានរៀល សហកម្មសិទ្ធិករខ្មែរត្រូវមានចំណែកទុនរបស់ខ្លួនស្មើនឹង ១០២ (មួយរយពីរ) លានរៀលយ៉ាងតិច ទើបក្រុមហ៊ុនសហកម្មសិទ្ធិនេះអាចទទួលសញ្ជាតិខ្មែរបាន[11]។

## ផ្នែកទី២៖ ទម្រង់តាមឆន្ទៈ និងតាមការចុះបញ្ជី

### ១.១ ទម្រង់តាមឆន្ទៈ

ទម្រង់ឆន្ទៈ ក្នុងនេះសំដៅដល់ឆន្ទៈរបស់សមាជិកហ៊ុន ឬសហកម្មសិទ្ធិករទូទៅ នីមួយៗស្របតាមឆន្ទៈគ្នាក្នុងការបង្កើត ក៏ដូចជាយល់ព្រមស្របតាមមតិគ្នាក្នុងនៅក្នុងលក្ខខណ្ឌផ្សេងៗដែលមាននៅក្នុងកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅជាដើម។ ឆន្ទៈរបស់សហកម្មសិទ្ធិករទូទៅនីមួយៗមានសារៈសំខាន់ខ្លាំងក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ បើក្នុងពេលបង្កើតកិច្ចសន្យាក្រុហ៊ុនសហកម្មសិទ្ធិទូទៅឡើង ស្របដែលមានសហកម្មសិទ្ធិករណាមួយមិនយល់ព្រមជាមួយលក្ខខណ្ឌនៅក្នុងកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះក៏មិនអាចបង្កើតឡើងបានដែរ។ ស្របជាមួយគ្នានេះផងដែរ ករណីក្នុងពេលមានបណ្តឹងកើតឡើងក្នុងពេលដំណើរការក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ពេលនោះតុលាការនឹងពិនិត្យបច្ច័យទៅលើ ថាតើភាគីសហកម្មសិទ្ធិករទូទៅទាំងអស់នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅនោះមានគោលបំណងរួមក្នុងការបង្កើត ក្រុមហ៊ុនហសកម្មសិទ្ធិករទូទៅនេះឡើងដែរឬទេ។ ក្នុងករណីនេះផងដែរ តុលាការក៏ធ្វើការពិនិត្យទៅលើចំណុច ពីរទៀតផងដែរស្របទៅតាមបញ្ញត្តិ ច្បាប់សហគ្រាសពាណិជ្ជកម្មត្រង់ មាត្រា១០ ចែងថា

[9] ច្បាប់សហគ្រាសពាណិជ្ជកម្ម, លេខ នសរ/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១៣។
[10] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦ ទំព័រ១០៦ និង១០៧។
[11] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦ ទំព័រ១០៨។

ក្នុងករណីដែលកិច្ចសន្យាមិនច្បាស់លាស់ តុលាការត្រូវពិចារណានូវវិធានដូចខាងក្រោម៖ (ក) ក្នុងករណីដែលបុគ្គលពីរ ឬច្រើននាក់ កាន់កាប់ទ្រព្យសម្បត្តិរួមគ្នា ថាតើបុគ្គលនោះចែករំលែកប្រាក់ចំណេញដែរ ឬ ទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះកើតឡើងដោយទ្រព្យសម្បត្តិរួម ដែរឬទេ។ (ខ) ក្នុងករណីដែលបុគ្គលពីរ ឬ ច្រើនចែករំលែកប្រាក់ចំណូលដែលបានមកពីការធ្វើពាណិជ្ជកិច្ចថាតើតុគ្គលទាំងនោះ មានសិទ្ធិចូលរួមក្នុងទ្រព្យសម្បត្តិរួមនោះ ឬទេ[12]។ ដូចនេះឆន្ទៈរបស់សហកម្មសិទ្ធិករនីមួយៗមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅក៏ដូចជាក្នុងពេលដំណើរការក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅផងដែរ។

**១.២ ទម្រង់តាមការចុះបញ្ជី**

យោងតាម ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៩ និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ ដើម្បីធ្វើការចុះបញ្ជី ត្រូវរៀបចំនូវឯកសារដូចតទៅ៖ ឈ្មោះក្រុមហ៊ុន កម្មវត្ថុ ឬអនុស្សរណៈ ឬលក្ខន្តិកៈក្រុមហ៊ុន ទម្រង់ក្រុមហ៊ុន ទីតាំងការិយាល័យចុះបញ្ជី ដើមទុន លិខិតបញ្ជាក់ការចុះបញ្ជីដើមទុននៅធនាគារ ឈ្មោះអភិបាល និងម្ចាស់ភាគហ៊ុន ម្ចាស់ភាគហ៊ុនផ្សេងទៀត អ្នកមានសិទ្ធិចុះហត្ថលេខា និងបញ្ជីនៃកម្មសិទ្ធិបញ្ញាដែលកាន់កាប់ដោយសហគ្រាសពាណិជ្ជកម្ម ឬអាជីវកម្ម រួមមាន ប្រកាសនីយបត្រតក្កកម្ម ម៉ាកពាណិជ្ជកម្ម និងសិទ្ធិអ្នកនិពន្ធ ក៏ដូចជាឯកសារយោងសំខាន់ៗផ្សេងៗដែលពាក់ព័ន្ធ។ ក្រុមហ៊ុនជាទូទៅត្រូវសន្មតថាត្រូវបានបង្កើតឡើង នៅពេលដែលមាននូវវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះត្រូវបានចេញដោយក្រសួងពាណិជ្ជកម្ម។

ក្នុងរយៈពេល២សប្តាហ៍បន្ទាប់ពីទទួលបានការឯកភាពពីក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវដាក់ពាក្យទៅធ្វើការចុះបញ្ជីបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ។ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកសារដែលនឹងត្រូវផ្តល់ជូនមានដូចតទៅ៖ លេខសម្គាល់អ្នកបង់ពន្ធ វិញ្ញាបនបត្របង់ពន្ធប៉ាតង់ វិញ្ញាបនបត្រអាករលើតម្លៃបន្ថែម លេខសម្គាល់ពន្ធដារ និងលិខិតជូនដំណឹង។ ដោយឡែក សម្រាប់អាជីវកម្មដែលពាក់ព័ន្ធការនាំចេញនាំចូល ក៏ត្រូវមានការស្នើសុំវិញ្ញាបនបត្របង់ពន្ធប៉ាតង់នាំចេញនាំចូលផងដែរ។

យោងតាមច្បាប់ការងារ ក្រុមហ៊ុនត្រូវមកដាក់ពាក្យនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីប្រកាសចំនួននិយោជិក សៀវភៅការងារ និងសៀវភៅបើកប្រាក់ឈ្នួលផងដែរ។ ហើយបើយោងតាមប្រកាសលេខ ៤៤៨ ស្តីពីបញ្ជិការសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសនតិសុខសង្គម ក្រុមហ៊ុនមានកាតព្វកិច្ចមកចុះបញ្ជីនិយោជិតក្នុងស្រុក និងនិយោជិតបរទេស ជាមួយបេឡាជាតិរបបសន្តិសុខសង្គមនៅក្នុងរយៈពេល មិនឱ្យលើសពី៣០ថ្ងៃ ចាប់ពីពេលបើកដំណើរការអាជីវកម្ម។

ការចុះបញ្ជីមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ការចុះបញ្ជីពាណិជ្ជកម្មផ្តល់នូវអត្ថប្រយោជន៍ទាំងផ្នែកច្បាប់ និងផ្នែកសេដ្ឋកិច្ច។ ចំពោះអត្ថប្រយោជន៍ផ្នែកច្បាប់ ការចុះបញ្ជី គឺផ្តល់ឱ្យនូវភាពប្រាកដ

[12] ច្បាប់សហគ្រាសពាណិជ្ជកម្ម, លេខ នសរ/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១០

ប្រជា និងការការពារដោយច្បាប់ នៅក្នុងអំឡុងពេលប្រតិបត្តិការសកម្មភាពអាជីវកម្ម។ ឧទាហរណ៍ ក្រុមហ៊ុនចុះបញ្ជីនឹងទទួលបាន បុគ្គលិកលក្ខណៈស្របច្បាប់ដាច់ដោយឡែកពីម្ចាស់ ក្នុងការធ្វើអាជីវកម្មដោយខ្លួនឯង ។ មានន័យថាក្រុមហ៊ុនមានសិទ្ធិអាចកាន់កាប់នូវទ្រព្យសម្បត្តិផ្ទាល់ខ្លួន ធ្វើការប្រតិបត្តិការសកម្មភាពអាជីវកម្ម និងប្តឹងទាមទារសំណងក្នុងនាមក្រុមហ៊ុនដោយខ្លួនឯងបាន។ មិនត្រឹមតែប៉ុណ្ណោះក្រុមហ៊ុនក៏មានលទ្ធភាពអាចបង្កើត និងទទួលបាននូវកេរ្តិ៍ឈ្មោះ និងជំនឿទុកចិត្តពីអ្នកប្រើប្រាស់ អតិថិជន និងដៃគូសហការដទៃទៀត។ បន្ថែមពីលើនេះ ក្រុមហ៊ុននឹងទទួលបានឱកាសនៅក្នុងការបង្កើននូវកិត្យានុភាពនៃម៉ាក ឬឈ្មោះពាណិជ្ជកម្មរបស់ខ្លួន (ឧទាហរណ៍ ពាណិជ្ជនាមយីហោ និងម៉ាកផ្សេងៗទៀត) សម្រាប់ការពង្រីក និងការលូតលាស់នៃអាជីវកម្មរបស់ខ្លួនក្នុងរយៈពេលវែងឆ្ងាយ។ ហើយនៅក្នុងករណីនៃការបាត់បង់ជីវិត ឬទទួលមរណភាពនៃម្ចាស់ភាគហ៊ុន ឬសមាជិកណាមួយ នោះក្រុមហ៊ុននឹងនៅតែបន្តដំណើរការដូចធម្មតា និងស្នងមរតកទៅតាមច្បាប់ដែលមានជាធរមាន។ គួរតែមានការកត់សម្គាល់ផងដែរថាម្ចាស់ភាគហ៊ុន និង/ឬ សមាជិកផ្សេងទៀត ក៏មិនមានហានិភ័យក្នុងការត្រូវលក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដើម្បីយកមកសងបំណុលរបស់ក្រុមហ៊ុនដែរ លើកលែងតែចំពោះក្រុមហ៊ុនមួយចំនួនដែលស្ថិតក្រោមទម្រង់ដូចជា ក្រុមហ៊ុនឯកជនឯកបុគ្គលជាអាទិ៍។ ចំពោះអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចវិញ ការចុះបញ្ជីក្រុមហ៊ុននឹងផ្តល់ឱកាសសម្រាប់ក្រុមហ៊ុនអាចស្នើសុំហិរញ្ញប្បទានពីធនាគារ អ្នកវិនិយោគ និងស្ថាប័នកម្ចីផ្សេងៗ ដើម្បីពង្រីកអាជីវកម្ម និងទីផ្សាររបស់ខ្លួនឱ្យកាន់តែឆាប់រហ័ស។ ក្រុមហ៊ុនក៏អាចបញ្ចូលឱ្យមាននូវម្ចាស់ភាគហ៊ុនថ្មី ហើយអាចទាក់ទាញវិនិយោគិនដើម្បីដាក់ដើមទុនបន្ថែមផងដែរ។

ផ្ទុយទៅវិញសម្រាប់ការខកខានមិនបានចុះបញ្ជីក្រុមហ៊ុន ជាបច្ចេកទេស ម្ចាស់អាជីវកម្មអាចត្រូវបានសន្មតថាកំពុងតែធ្វើអាជីវកម្មខុសច្បាប់ ឬសកម្មភាពអាជីកម្មដែលមិនទទួលស្គាល់ដោយច្បាប់។ ជាផលវិបាក ម្ចាស់អាជីវកម្មត្រូវបញ្ឈប់សកម្មភាពអាជីវកម្មរបស់ខ្លួនជាបន្ទាន់ ហើយ/ឬ នឹងប្រឈមនិងការពិន័យ ដោយអនុលោមតាម មាត្រា ៤០ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។ មិនត្រឹមតែតែប៉ុណ្ណោះ ម្ចាស់អាជីវកម្មអាចប្រឈមមុខទៅនឹងការប្តឹង ឬការដាក់វិធានការវិន័យ ចំពោះសកម្មភាពអាជីវកម្មខុសច្បាប់ ដែលការទទួលខុសត្រូវនេះអាចនាំឱ្យមានការបាត់បង់នូវទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ម្ចាស់អាជីវកម្ម[13]។

### ១.៣ ការប្រកាសផ្សាយ

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះការអនុវត្ត ការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក ឯកសារនិងការចុះផ្សាយដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវរក្សាទុកជាឯកសារនូវសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយនៅទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន។ ការផ្សាយជាសាធារណៈត្រូវធ្វើឡើង ដើម្បីជាប្រយោជន៍កុំឲ្យមានសមាជិកទាំងឡាយណាទាញយកផលប្រយោជន៍ នៅពេល ក្រុមហ៊ុនត្រូវបានគេចាត់ទុក ជាមោឃៈ។

[13] http://www.anna-associates.com/blog/1621479177373 ការចុះបញ្ជីក្រុមហ៊ុន/សហគ្រាសពាណិជ្ជកម្ម។

# ជំពូកទី២

# ដំណើរការនៃការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

## ផ្នែកទី១៖ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន

### ១.១ អ្នកគ្រប់គ្រង

#### ក. ការតែងតាំង

សមាជិកក្រុមហ៊ុនសហកម្មសិទ្ធិ មានសេរីភាពក្នុងការតែងតាំងអ្នកគ្រប់គ្រងក្នុងក្រុមហ៊ុន។ ដូច្នេះគឺ៖

- អ្នកគ្រប់គ្រងអាចត្រូវបានគេតែងតាំង ដោយយោងតាមលក្ខន្តិកៈ ឬមានលិខិតដោយឡែកណាមួយនៅពេលក្រោយ
- គេអាចមានអ្នកគ្រប់គ្រងម្នាក់ ឬច្រើននាក់
- ភាគច្រើន គេតែងតាំងអ្នកគ្រប់គ្រងដែលជាសមាជិកភាគហ៊ុនប៉ុន្តែគេក៏អាចជ្រើសរើសយកតតិយជនបានផងដែរ ក្នុងនោះតតិយជនអាចជាជនជាតិបរទេសផងដែរ។ តតិយជនដែលជាអ្នកគ្រប់គ្រងមិនទទួលខុសត្រូវបំណុលរបស់ក្រុមហ៊ុនទេ[14]។

ម្យ៉ាងវិញទៀត ការជ្រើសរើសអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុន គឺធ្វើឡើងដោយសម្អាងថាជាជនដែលមានសមត្ថភាពពិតប្រាកដក្នុងការដឹកនាំក្រុមហ៊ុនឲ្យមានការរីកចម្រើន។ គេមិនសូវជ្រើសរើសយកតតិយជនឲ្យធ្វើជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនទេ ដោយសារថា ក្រុមហ៊ុននេះជាក្រុមហ៊ុនដែលមានការទទួលខុសត្រូវដោយគ្មានកំណត់ និងដោយសាមគ្គី។ ហេតុនេះគេក៏មិនអាចទុកចិត្តនរណាម្នាក់ ក្រៅពីសមាជិកភាពហ៊ុនដែលមានសមត្ថភាពនោះឡើយ។ មាត្រា ៣៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចែងថា សហកម្មសិទ្ធិករទូទៅទាំងឡាយ អាចតែងតាំងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ឬបុគ្គលដែលមិនមែនជាសហកម្មសិទ្ធិករទូទៅឲ្យគ្រប់គ្រងកិច្ចការជំនួសខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅនោះ។ អ្នកគ្រប់គ្រង អាចអនុវត្តផ្ទាល់សកម្មភាពនៅក្នុងសិទ្ធិអំណាចសិទ្ធិអំណាចរបស់ខ្លួន ដរាបណាអ្នកគ្រប់គ្រងនោះមិនប្រព្រឹត្តអំពើក្លែងបន្លំ។ ការប្រព្រឹត្តរបស់អ្នកគ្រប់គ្រង ត្រូវជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។

អ្នកគ្រប់គ្រងត្រូវបានដកហូតចេញពីមុខតំណែង ដោយសម្លេងភាគច្រើន ដោយបៀបនៃវត្តមានសហកម្មសិទ្ធិករទូទៅទាំងឡាយក្នុងពេលបោះឆ្នោតលើកលែងតែមានចែងផ្សេងក្នុងកិច្ចសន្យា នៃក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ។

#### ខ. ការបញ្ចប់តួនាទី

ដូចបានបញ្ជាក់ពីខាងលើរួចមកហើយអំពីរបៀបនៃការដកហូតមុខងារជាអ្នកគ្រប់គ្រង។ មាត្រា ៣៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ អ្នកគ្រប់គ្រងត្រូវបានដកហូតចេញពីមុខតំណែង ដោយសម្លេងភាគច្រើនដោយរបៀបនៃ

[14] ច្បាប់ពាណិជ្ជកម្ម, កៅ មុយថង, ឆ្នាំ២០១៥, ទំព័រ១៩៩។

វត្តមានសហកម្មសិទ្ធិករទូទៅក្នុងពេលបោះឆ្នោត លើកលែងតែមានចែងផ្សេង ក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ។

នៅផ្នែកខាងក្រោមនេះ ជាករណីសិក្សានីមួយៗរបស់វាបន្ថែមទៀតគឺៈ

- ការមកដល់នៃពេលវេលា នៅក្នុងលក្ខន្តិៈរបស់ក្រុមហ៊ុនខ្លះមិនបានចែងបញ្ជាក់ពីរយៈពេលនៃការបញ្ចប់តួនាទីជាអ្នកគ្រប់គ្រងលើក្រុមហ៊ុនរបស់សហកម្មសិទ្ធិករម្នាក់ឡើយ ហេតុនេះវាជាមូលហេតុមួយដែលអាចឲ្យគេនិយាយបានថា ភាពជាអ្នកដឹកនាំលើក្រុមហ៊ុន គឺអាចបន្តអស់មួយជីវិត។
- មានហេតុការណ៍ផ្ទាល់ខ្លួន ដែលរារាំងការបំពេញតួនាទីជាបណ្ណាធិការៈ ដូចជា ករណីមរណភាពរបស់សមាជិកភាគហ៊ុន ការធ្លាក់ខ្លួនក្នុងពិការភាព ការបាត់បង់សមត្ថភាពក្នុងការដឹកនាំក្រុមហ៊ុន ច្បាប់ហាមឃាត់មិនឲ្យជាប់ទាក់ទិនទៅនឹងតួនាទីជាអ្នកដឹងនាំក្រុមហ៊ុន ការប្រកាសពី "ក្ស័យធនរបស់បុគ្គល" ឬការប្រកាសថាមានជម្ងឺដែលមិនអាចឲ្យគេដឹកនាំក្រុមហ៊ុនបាន។
- ការសុំលាលែងគឺ អ្នកគ្រប់គ្រងក្រុមហ៊ុនក្នុងគ្រប់ករណីទាំងអស់មានសិទ្ធិនឹងសុំលាលែងពីឋានៈជាអ្នកគ្រប់គ្រងក្រុមហ៊ុនបាន។

## ១.២ ករណីយកិច្ច សិទ្ធ និងអំណាចរបស់សហកម្មសិទ្ធិករ

### ១.២.១ ករណីយកិច្ច

ជាការពិតណាស់ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាក្រុមហ៊ុនដែលកើតឡើងពីកិច្ចសន្យារវាងបុគ្គលពីរ ឬ ច្រើនដោយសន្យាដាក់រួមគ្នានូវភាគទុនជាទ្រព្យសម្បត្តិ ចំណេះដឹង ឬសកម្មភាពដើម្បីប្រកបពាណិជ្ជកិច្ចក្នុងគោលដៅរកប្រាក់ចំណេញ។ ដូច្នេះហើយ នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើង ភាគីទាំងឡាយ នៃកិច្ចសន្យាបង្កើតនោះ ត្រូវជាប់កាតព្វកិច្ចចំពោះក្រុមហ៊ុន ចាប់ពេលដែលកិច្ចសន្យានោះត្រូវបានធ្វើឡើងចប់សព្វគ្រប់។ ប៉ុន្តែប្រសិនបើកិច្ចសន្យានោះចែងផ្សេងអំពីពេលដែលត្រូវជាប់កាតព្វកិច្ច នោះភាគីត្រូវអនុវត្តតាមការចែងនោះ។ ខាងក្រោមនេះគឺជាករណីយកិច្ចសំខាន់ៗមួយចំនួនដែលសហកម្មសិទ្ធិករទូទៅម្នាក់ៗត្រូវបំពេញៈ

- **ករណីយកិច្ចពាក់ព័ន្ធនឹងការបើកក្រុមហ៊ុន**

កិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិដែលភាសាអង់គ្លេសហៅថា Articles of Partnership ឬ Partnership Agreement ជាឯកសារគោលនៃការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ។ ចំពោះឯកសារនេះបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករ ហើយក៏មានចែងអំពីធាតុនៃអាជីវកម្ម ដើមទុន សិទ្ធិ អំណាច ករណីយកិច្ច ការបែងចែកផលចំណេញ ការបែងរំលែកការខាតបង់។ល។[15] សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ និងការចុះ ផ្សាយដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ថ្វីបើសហកម្មសិទ្ធិមិនបានធ្វើកិច្ចព្រមព្រៀងជាលាយលក្ខអក្សរក្តី សហកម្មសិទ្ធិករនៅតែមានករណីយកិច្ចគោរពតាមការព្រមព្រៀងនោះ។ នៅពេលដែលកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានខចែងមិនច្បាស់ វិធាននៃការបកស្រាយកិច្ចសន្យាទូទៅត្រូវយក

[15] ច្បាប់ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រទី១៣៥។

មកអនុវត្ត។ គេត្រូវពិនិត្យទៅលើចេតនារបស់សហកម្មសិទ្ធិករនៅពេលបង្កើតកិច្ចសន្យា ដោយឈរលើខដែលបានចែង នៃកិច្ចសន្យា និងកាលៈទេសៈនៅជុំវិញការបង្កើតកិច្ចសន្យាតែម្តង។ បើសហកម្មសិទ្ធិករទាំងអស់ទទួលយកការបក ស្រាយក្រោមរូបភាពណាមួយហើយការបកស្រាយនោះត្រូវចងកាតព្វកិច្ចលើសហកម្មសិទ្ធិករទាំងអស់។

- **ករណីយកិច្ចក្នុងការបង់ភាគទុន**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ មានកាតព្វកិច្ចបង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនតាមការសន្យារបស់ខ្លួន។ ភាគទុន អាចជា សាច់ប្រាក់ វត្ថុ ឬ សេវាពីមុនដែលបានផ្តល់រួចមកហើយយ៉ាងពិតប្រាកដ ឬជាការសន្យាថានឹងផ្តល់នូវសេវា នាពេលអនាគត[16]។ ថ្វីបើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមិនឲ្យគណនាដើមទុន ដោយរាប់បញ្ចូលភាគទុនជាចំណេះ ដឹង សេវា ឬសកម្មភាពក្តី កិច្ចសន្យាក្រុមហ៊ុនត្រូវតែបែងចែកសមាមាត្រនៃប្រាក់ចំណេញ និងការខាត់បង់ដល់សហកម្ម សិទ្ធិករដែលរួមចំណែកជាចំណេះដឹង សេវា ឬសកម្មភាព[17]។ ប្រសិនបើសហកម្មសិទ្ធិករទូទៅ បានទទួលយល់ព្រម ដាក់ភាគទុនជាទ្រព្យសម្បត្តិ សហកម្មសិទ្ធិករទូទៅនោះ ត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិដែលខ្លួនមានលើទ្រព្យនោះ ទៅដាក់ជាទ្រព្យរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ប្រសិនបើសហកម្មសិទ្ធិករទូទៅ បានទទួលយល់ព្រមដាក់ភាគទុនជាចំណេះដឹង សេវា ឬ សកម្មភាព សហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចរហូត ដរាបណាបុគ្គលនោះនៅតែជាសហកម្មសិទ្ធិករទូទៅ។ សហកម្មសិទ្ធិករទូទៅម្នាក់ៗ គឺជាកូនបំណុលនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ចំពោះរាល់អ្វីៗ ដែល ខ្លួនបានសន្យា ចូលរួមទៅក្នុងក្រុមហ៊ុន។

- **ករណីយកិច្ចរួមចំណែកការខាតបង់របស់ក្រុមហ៊ុន**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវរួមចំណែកការខាតបង់របស់ក្រុមហ៊ុន។ វិធានទូទៅ សហកម្មសិទ្ធិករទូទៅម្នាក់ ត្រូវរួមចំណែកការខាត់បង់របស់ក្រុមហ៊ុនក្នុងចំណែកស្មើគ្នា មិនថាសហកម្មសិទ្ធិកររូបណាបានរួមចំណែកភាគទុន ច្រើន ឬតិចទេ។ ឧទាហរណ៍ថា៖ ក្នុងករណី សហកម្មសិទ្ធិ A និង B រួមការខាតបង់ក្នុងចំណែកស្មើគ្នា ទោះបី A បាន ដាក់ភាគទុនច្រើនជាង B បីដងក៏ដោយ។ ប៉ុន្តែប្រសិនបើនៅក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិករទាំងពីរនាក់ ចែងថា គេយល់ព្រមបង់ខាតទៅតាមសមាមាត្រនៃភាគទុនរបស់គេនោះ គេមានករណីយកិច្ចបង់ខាតតែត្រឹមសមា មាត្រដែលបានកំណត់នោះ។ មាត្រា ២៤ ចែងថា ៖ សមាមាត្រនៃផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅម្នាក់ៗ នៅក្នុងទ្រព្យសម្បត្តិ ប្រាក់ចំណេញ និងការខាតបង់គឺស្មើគ្នា លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យា។ ប្រសិនបើ កិច្ចសន្យាចែងអំពីផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅ ដោយសំដៅចំពោះតែទ្រព្យសម្បត្តិ ប្រាក់ចំណេញ ឬការ ខាតបង់ ពេលនោះសមាមាត្រ ដែលបានបង្កើតឡើងនៅក្នុងករណីនេះត្រូវបានសន្មតជាមុន ដើម្បីអនុវត្តទៅលើតែលើ ករណីទាំងបីនោះ[18]។ នៅពេលដែលសហកម្មសិទ្ធិករបានចែងនៅក្នុងកិច្ចសន្យាតែសមាមាត្រនៃភាគចំណេញតែមិន បានចែងពីសមាមាត្រនៅក្នុងផលប្រយោជន៍ក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ឬសមាមាត្រនៅក្នុងការរួមចំណែកបង់

[16] https://bizkhmer.com/articles/48444 (ដោយលោក៖ ប៉ុម ទូច) , ច្បាប់អាជីវកម្ម។

[17] មាត្រា២១, ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

[18] មាត្រា២៤, ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

ខាតដែលត្រូវទទួល សមាមាត្រនៃប្រាក់ចំណេញនោះត្រូវអនុវត្តចំពោះការខាតបង់ផងដែរ។ ឧទាហរណ៍ថា៖ បុគ្គល A B C និង D ចែងនៅក្នុងកិច្ចសន្យាក្រុមហ៊ុនថា គេត្រូវបែងចែកប្រាក់ចំណេញតាមសមាមាត្រ តាមលំដាប់ ១៧% ៣៣% និង ៥០%។ សមាមាត្រទាំងអស់នេះត្រូវអនុវត្តចំពោះការខាតបង់ និងចំពោះផលប្រយោជន៍ នៅក្នុងទ្រព្យសម្បត្តិផងដែល នៅពេលដែលសហកម្មសិទ្ធិករមិនបានចែងបញ្ជាក់នៅក្នុងកិច្ចសន្យា ពីសមាមាត្រនៃការខាត និងផលប្រយោជន៍នៅក្នុងទ្រព្យសម្បត្តិ។

- **ករណីយកិច្ចចំពោះរាល់ផលកម្រៃ និង ប្រាក់ចំណេញ**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុននូវរាល់ផលកម្រៃ និងប្រាក់ចំណេញទាំងឡាយដែលសហកម្មសិទ្ធិករទូទៅនោះ បានមកពីការធ្វើអាជីវកម្មណាមួយនៅក្នុងពាណិជ្ជកិច្ច ឬ ពីការប្រើប្រាស់ទ្រព្យ សម្បត្តិរបស់ក្រុមហ៊ុនដែលគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិទូទៅផ្សេងទៀត។ សហកម្មសិទ្ធិករទូទៅ ទាំងឡាយមិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ។

- **ករណីយកិច្ចចំពោះការខូតខាតដោយសារកំហុសឆ្គង**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នូវរាល់ការខូចខាតដែលបង្កឡើងដោយកំហុសឆ្គងរបស់សហកម្មសិទ្ធិករទូទៅនោះ។ ក្នុងករណីយកិច្ចត្រូវសងដល់ក្រុមហ៊ុនដែលបង្កដោយកំហុសរបស់សហកម្មសិទ្ធិករនេះក៏ត្រូវបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីដែរ។ ដូច្នេះមាត្រា ២៧ នេះនាំឲ្យមានការសន្និដ្ឋានបានថា សហកម្មសិទ្ធិករមានករណីយកិច្ចប្រុងប្រយ័ត្ន នៅក្នុងការដឹកនាំ ឬចាត់ចែងអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ។ សហកម្មសិទ្ធិករទូទៅត្រូវអនុវត្តកិច្ចការដោយមិនធ្វេសប្រហែស ឬដោយមានចេតនាបំផ្លាញ។ នៅពេលនេះ គេមិនទាន់ដឹងថា តើតុលាការខ្មែរកំណត់ស្តង់ដានៃការប្រុងប្រយ័ត្នត្រឹមកម្រិតណាមួយនៅឡើយ។ សេចក្តីអត្ថាធិប្បាយលើច្បាប់គំរូអាមេរិកាំងស្តីពីក្រុមហ៊ុនសហកម្មសិទ្ធិ (Revised Uniform Partnership Act) លើកយករឿងក្តីមួយឈ្មោះ Rosenthal v. Rosenthal (1988) មកធ្វើជាគំរូដើម្បីកំណត់ពីស្តង់ដានៃការប្រុងប្រយ័ត្ន។ នៅក្នុងរឿងក្តីនេះតុលាការកំណត់ករណីកិច្ចដែលសហភាអាជីវកម្មត្រូវមានចំពោះគ្នាទៅវិញទៅមកដូចតខាងក្រោម៖

ក. ធ្វើកិច្ចការនៅក្នុងកម្រិតនៃការពិនិត្យពិច័យ, ការយកចិត្តទុកដាក់ និងការប៉ិនប្រសប់ ដែលមនុស្សធម្មតាមានការប្រុងប្រយ័ត្ន នឹងអនុវត្តកិច្ចការរបស់ខ្លួននៅក្នុងកាលៈទេសៈស្រដៀងគ្នា និងក្នុងកំណែងស្រដៀងគ្នា។ ឧទាហរណ៍ បើមនុស្សម្នាក់ជាសហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុនម៉ៅសំណង់ មនុស្សនោះត្រូវធ្វើកិច្ចការរបស់ខ្លួនដោយយកចិត្តទុកដាក់ក្នុងការសន្សំសំចៃ ការចាត់ចែងការ និងប្រើការប៉ិនប្រសប់របស់ខ្លួនឲ្យស្រដៀងគ្នា នឹងមនុស្សដទៃទៀតដែលមានឋានៈជាសហកម្មសិទ្ធិករដែលករស៊ីម៉ៅសំណង់គ្នា។

ខ. បំពេញករណីយកិច្ចដែលទាក់ទងនឹងទំនាក់ទំនងរបស់គេ ដោយសុទ្ធចិត្តក្នុងទស្សនៈលើកតម្កើងផលប្រយោជន៍របស់ខ្លួនទៅវិញទៅមក ចំពោះសាច់រឿងដែលស្ថិតនៅក្នុងវិសាលភាពនៃទំនាក់ទំនងនោះ ។ ត្រង់ចំណុចនេះបានសេចក្តីថា នៅពេលបំពេញករណីយកិច្ចរបស់ខ្លួនក្នុងឋានៈជាមិត្តរួម នឹងគ្នា ម្នាក់ត្រូវធ្វើដោយចិត្តស្មោះសរ

ដើម្បីឲ្យកិច្ចការដែលធ្វើក្នុងដែននៃទំនាក់ទំនង (ឧទាហរណ៍ ក្នុងដែននៃការងាររបស់ក្រុមហ៊ុនសហកម្មសិទ្ធិ) នោះបានចំរើនដល់ផលប្រយោជន៍រវាងគ្នានឹងគ្នា)

- បើកបង្ហាញ និងមិនកិបទុកនូវព័ត៌មានសំខាន់ ដែលធ្វើឲ្យប៉ះពាល់ដល់ឋានៈនិងកិច្ចការនៃទំនាក់ទំនងនេះ។ (មានន័យ ថា មិនលាក់បំបាំងព័ត៌មានសំខាន់នឹងគ្នាព្រោះគេមានទំនាក់ទំនងជាអ្នកធ្វើការងារជាមួយគ្នា និងមានកិច្ចការរួមជាផលប្រយោជន៍រួមគ្នា ព្រោះព័ត៌មាននោះមានសារសំខាន់សម្រាប់គេ ក្នុងឋានៈជាភាគីមួយនៃអាជីវិកម្ម)
- មិនប្រើតំណែង ឥទ្ធិពល ឬ ចំណេះដឹង ទាក់ទងនឹងកិច្ចការនិងការរៀបចំរចនាសម្ព័ន្ធទំនាក់ទំនងនោះ ដើម្បីធ្វើឲ្យបានចំណេញបុព្វសិទ្ធិពិសេស ឬយកប្រៀបលើមនុស្សដទៃទៀតដែលពាក់ព័ន្ធក្នុងទំនាក់ទំនងនេះ។

នៅពេលណាដែល សហកម្មសិទ្ធិករណាម្នាក់បង្កការខូចខាត ដោយកំហុសរបស់ខ្លួនសហកម្មសិទ្ធិករនោះត្រូវសងតម្លៃខូចខាតដែលកើតមានចំពោះក្រុមហ៊ុន[19] ។

- **ករណីយកិច្ចដែលកើតពីសកម្មភាពក្នុងនាមក្រុមហ៊ុន**

សកម្មភាពដែលបានអនុវត្តដោយសហកម្មសិទ្ធិករទូទៅម្នាក់ ដែលទាក់ទងទៅនឹងសកម្មភាពរួមរបស់ ក្រុមហ៊ុនត្រូវជាប់កាតព្វកិច្ចទៅនឹងសហកម្មសិទ្ធិករទូទៅផ្សេងទៀត។ សហកម្មសិទ្ធិករទូទៅម្នាក់ៗ គឺជាភ្នាក់ងាររបស់ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ នៅក្នុងទំនាក់ទំនងជាមួយតតិយ ជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ ហើយសហកម្មសិទ្ធិករទូទៅទាំង នោះត្រូវជាប់កាតព្វកិច្ចចំពោះ ក្រុមហ៊ុននូវរាល់អំពើដែលខ្លួនបានអនុវត្តក្នុងនាមក្រុមហ៊ុននោះ។ សហកម្មសិទ្ធិករទូទៅម្នាក់ដែលបានចុះកិច្ចសន្យាជាមួយតតិយជន ត្រូវជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្ម សិទ្ធិទូទៅ នៅពេលណាដែលកាតព្វកិច្ចនោះស្ថិតក្នុងវង្វង់អាជីវកម្មរបស់ក្រុមហ៊ុន ឬនៅពេលណាដែលកម្មវត្ថុនៃកិច្ចសន្យានោះ ជាទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។

- **ករណីយកិច្ចមិនត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន**

សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវរួមគ្នា និង ដាច់ដោយឡែកពីគ្នា នូវកាតព្វកិច្ចទាំងឡាយរបស់ក្រុមហ៊ុននោះ។ តតិយជនត្រូវទាមទារការអនុវត្តកាតព្វកិច្ចបំណុល ឬទ្រព្យសម្បត្តិក្រុមហ៊ុនជាមុនសិន មុននឹងទាមទារពីសហកម្មសិទ្ធិករទូទៅ។ ដូចឃើញនៅក្នុងមាត្រា ២៥ បានចែងថា សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវ ចំពោះក្រុមហ៊ុននូវរាល់ផលកម្រៃ និងប្រាក់ចំណេញទាំងឡាយដែលសហកម្មសិទ្ធិករទូទៅនោះ បានមកពីការធ្វើអាជីកម្មណាមួួយនៅក្នុងពាណិជ្ជកម្ម ឬ ពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅផ្សេងទៀត។ សហកម្មសិទ្ធិទូទៅ ទាំងឡាយមិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ។ ស្របតាមខ្លឹមសារនៃមាត្រានេះផងដែលបង្ហាញឲ្យឃើញថា សហកម្មសិទ្ធិករមិនអាចលួច

[19] ច្បាប់ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រទី១៨៤។

យកមូលនិធិរបស់ក្រុមហ៊ុនទៅប្រើដើម្បីកេងយកចំណេញផ្ទាល់ខ្លួនបានទេ។ ឧទាហរណ៍សហកម្មសិទ្ធិករម្នាក់ដែលលួចបង្វែរប្រាក់របស់ក្រុមហ៊ុនដើម្បីយកទៅចងការយកចំណេញត្រូវទទួលខុសត្រូវយកការប្រាក់ដែលបានពីការចងការនោះមកសងក្រុមហ៊ុនវិញ។ តែបើការយកប្រាក់ក្រុមហ៊ុនទៅចងការនេះមានការយល់ព្រមពីសហកម្មសិទ្ធិករដទៃទៀតទាំងអស់នោះសហកម្មសិទ្ធិករនោះមិនទទួលខុសត្រូវសងការប្រាក់នោះទៅក្រុមហ៊ុនវិញទេ។

ស្របតាមខ្លឹមសារនៃមាត្រាខាងលើនេះដដែល បានបញ្ជាក់យ៉ាងច្បាស់ថា ហាមប្រាមការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដែលគ្មានការយល់ព្រមពីសហកម្មសិទ្ធិដទៃទៀតទាំងអស់ ដើម្បីកេងយកផលប្រយោជន៍ ឬចំណេញខ្លួនឯង។ ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមិនមែនសំដៅតែលើទ្រព្យរូបី ដូចជាប្រាក់កាស អគារ ឧបករណ៍ គ្រឿងបរិក្ខារប៉ុណ្ណោះទេ តែរាប់បញ្ចូលទ្រព្យអរូបីផងដែរ ដូចជាព័ត៌មាន សិទ្ធិនិពន្ធ កម្មសិទ្ធិបញ្ញាផ្សេងៗទៀត[20]។

- **ករណីយកិច្ចរបស់សហកម្មសិទ្ធិករទូទៅថ្មីចំពោះបំណុលរបស់ក្រុមហ៊ុន**

បុគ្គលណាដែលចូលជាសហកម្មសិទ្ធិករទូទៅ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលកើតរួចហើយត្រូវទទួលខុសត្រូវចំពោះបំណុលទាំងអស់ ដែលកើតឡើងដោយសារក្រុមហ៊ុន មុនពេលដែលបុគ្គលនោះចូលជាសហកម្ម សិទ្ធិករទូទៅដូចដែលខ្លួនជាសហកម្មសិទ្ធិករទូទៅនៅពេលដែលបំណុលនោះកើតឡើងដែរ។ ប៉ុន្តែបំណុលទាំងឡាយណាដែលកើតឡើងមុនពេលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅបំណុលនោះអាចត្រូវបានចេញសង ដោយទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយមិនត្រូវបានចេញសងដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បុគ្គល នោះឡើយ លើកលែងតែបុគ្គលនោះមានការព្រមព្រៀងផ្សេងនៅក្នុងលិខិតជាលាយលក្ខណ៍អក្សរ[21]។

### ១.២.២ សិទ្ធ

សហកម្មសិទ្ធិករទូទៅ ទទួលបានសិទ្ធិនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិតាមរយៈការកំណត់នៅក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុន និងប្បញ្ញត្តិនៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ សិទ្ធិទាំងនោះទាក់ទងនឹងបេតិកភ័ណ្ឌ និងទំនាក់ទំនងរវាងសហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុន។ ខាងក្រោមនេះគឺជាសិទ្ធិសំខាន់ៗមួយចំនួនដែលសហកម្មសិទ្ធិករទូទៅម្នាក់ៗត្រូវមាន៖

- **សិទ្ធិកាន់កាប់ នឹងការប្រើប្រាស់ទ្រព្យសម្បត្តិក្នុងក្រុមហ៊ុន**

គ្រប់សហកម្មសិទ្ធិករទូទៅទាំងអស់ជាម្ចាស់រួមលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដូច្នេះម្នាក់ៗមានសិទ្ធិស្មើគ្នាក្នុងការកាប់ទ្រព្យសម្បត្តិ និងប្រើប្រាស់ទ្រព្យសម្បត្តិនោះក្នុងនាមនៃក្រុមហ៊ុន។ ប៉ុន្តែ សហកម្មសិទ្ធិករមិនអាចប្រើប្រាស់ទ្រព្យសម្បត្តិនោះជាប្រយោជន៍ផ្ទាល់ខ្លួនបានទេ លើកលែងតែមានការយល់ព្រមពីសហកម្មសិទ្ធិករដទៃទៀត។ សហកម្មសិទ្ធិករដែលយកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទៅប្រើប្រាស់ ដោយគ្មាការយល់ព្រមពីសហកម្មសិទ្ធិករដទៃទៀត មិនអាចទទួលផលកម្រៃដែលកើតចេញពីការប្រើប្រាស់នោះទេ។ ឧទាហរណ៍ថា៖ ប្រសិនបើសហកម្មសិទ្ធិករម្នាក់យករថយន្តរបស់ក្រុមហ៊ុន (ទោះបីរថយន្តនោះជាវិភាគទានរបស់ខ្លួនក្តី) ទៅដឹកទំនិញយកឈ្នួល ដោយគ្មានការអនុញ្ញាតពីសហ

[20] ច្បាប់ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រទី១៤១។

[21] https://knowledgelegalkrn.blogspot.com/2017/04/blog-post_24.html គេហទំព័រចំណេះដឹងផ្នែកច្បាប់។

កម្មសិទ្ធិករដទៃទៀតសហកម្មសិទ្ធិករនោះត្រូវទទួលខុសត្រូវចំពោះការខូចខាតរបស់រថយន្ត ឬបើបានទទួលកម្រៃពីការដឹកវ៉ាន់ សហកម្មសិទ្ធិករនោះត្រូវបង្វិលកម្រៃនោះទៅឲ្យក្រុមហ៊ុនវិញ។ ដូចដែលមានចែង ក្នុងមាត្រា ២៥ ថា៖ សហកម្មសិទ្ធិករទូទៅម្នាក់ៗត្រូវតែទទួលខុសត្រូវចំពោះក្រុមហ៊ុននូវរាល់ផលកម្រៃ និងប្រាក់ចំណេញទាំងឡាយដែលសហកម្មសិទ្ធិករទូទៅនោះ បានមកពីការធ្វើអាជីវកម្មណាមួយនៅក្នុងពាណិជ្ជកម្ម ឬពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅផ្សេងទៀត ។ សហកម្មសិទ្ធិករទៅទាំងឡាយ មិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ[22]។

- **ផលប្រយោជន៍នៅក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន**

ទន្ទឹមនឹងសិទ្ធិស្មើគ្នានៅក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន សហកម្មសិទ្ធិករត្រូវបានសន្មតថាមានផលប្រយោជន៍ស្មើគ្នានៅក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនដែរ លើកលែងតែនៅពេលចុះកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ សហកម្មសិទ្ធិករម្នាក់ៗចែងបញ្ជាក់ពីទំហំនៃផលប្រយោជន៍របស់ខ្លួននៅក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដើម្បីកំណត់ពីសមាមាត្រនៃផលប្រយោជន៍របស់ខ្លួននៅក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន[23]។

នៅពេលចុះកិច្ចសន្យា សហកម្មសិទ្ធិទូទៅអាចកំណត់ពីតម្លៃសរុបនៃទ្រព្យសម្បត្តិដែលសហកម្មសិទ្ធិករទាំងអស់បានដាក់ចូលក្នុងក្រុមហ៊ុន ហើយកំណត់ភាគរយនៃតម្លៃទ្រព្យសម្បត្តិដែលសហកម្មសិទ្ធិករម្នាក់ៗបានដាក់បញ្ចូលរួចហើយចែងបន្តទៀតថា នៅពេលចែកទ្រព្យសម្បត្តិគ្នា (ដូចជាក្នុងករណីរំលាយក្រុមហ៊ុនជាដើម) សហកម្មសិទ្ធិករម្នាក់ ៗត្រូវបានចំណែកទ្រព្យសម្បត្តិទៅតាមសមាមាត្រនៃផលប្រយោជន៍របស់ខ្លួននៅក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។

- **សិទ្ធិស្មើគ្នានៅក្នុងការគ្រប់គ្រង**

សិទ្ធិស្មើគ្នានៅក្នុងការគ្រប់គ្រងក្រុមហ៊ុន ដោយហេតុថាសហកម្មសិទ្ធិករម្នាក់ៗជាម្ចាស់ក្រុមហ៊ុនសហកម្មសិទ្ធិករម្នាក់ៗត្រូវមានសិទ្ធិនៅក្នុងការគ្រប់គ្រងក្រុមហ៊ុន។ មិនមានសហកម្មសិទ្ធិកររូបណាអាចផាត់សហកម្មសិទ្ធិករម្នាក់ទៀតមិនឲ្យចូលរួមក្នុងសេចក្តីសម្រេចកិច្ចការរបស់ក្រុមហ៊ុនបានឡើយ។ មាត្រា ៣៧ ចែងថា៖ សហកម្មសិទ្ធិករទូទៅត្រូវបានចាត់ទុកថាមានសិទ្ធិគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅនោះ។ សកម្មភាពដែលបានអនុវត្តដោយសហកម្មសិទ្ធិករទូទៅម្នាក់ ដែលទាក់ទង នឹងសហកម្មសិទ្ធិករទូទៅផ្សេងទៀតដែរ។

- **ការលើកលែងសិទ្ធិគ្រប់គ្រង**

ជាការពិតណាស់សិទ្ធិរបស់សហកម្មសិទ្ធិករក្នុងការចូលរួមក្នុងការគ្រប់គ្រងជាសិទ្ធិ ដែលមិនអាចដកហូតបាន ។ ប៉ុន្តែសម្រាប់សហកម្មសិទ្ធិករម្នាក់អាចជ្រើសរើសថាខ្លួនត្រូវចូលប្រឡូកក្នុងការគ្រប់គ្រង ឬ ទុកឲ្យសហកម្មសិទ្ធិករដទៃទៀត ឬអ្នកក្រៅណាមួយផ្សេងទៀតគ្រប់គ្រងក្រុមហ៊ុនជំនួសខ្លួនក៏បាន។ ថ្វីត្បិតបើខ្លួន បានប្រគល់កិច្ចការក្រុមហ៊ុនទៅឲ្យសហកម្មសិទ្ធិករ ឬ អ្នកក្រៅរួចហើយក្តី សហកម្មសិទ្ធិករនោះនៅតែអាចត្រឡប់ចូលមកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិញបានជាដរាប។ ទាក់ទងនឹងសិទ្ធិគ្រប់គ្រងក្រុមហ៊ុន ដោយយោងតាម មាត្រា ៣៤ ចែងថា៖ សហកម្មសិទ្ធិករទូទៅ

[22] មាត្រា២៥, ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។
[23] មាត្រា២៤, ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

ទាំងឡាយអាចធ្វើសេចក្ដីសម្រេចអំពី សិទ្ធិរបស់ខ្លួននៅក្នុងការគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ សហកម្មសិទ្ធិករដែលត្រូវបានផាត់ចេញពីការគ្រប់គ្រងកិច្ចការរបស់ក្រុមហ៊ុនមានសិទ្ធិទាមទារឧបាស្រ័យដើម្បីជួសជុលសិទ្ធិរបស់ខ្លួន ដូចជាអាចប្ដឹងទៅតុលាការឲ្យចេញដីកាបញ្ឈប់ការប្រព្រឹត្តបែបនោះ ឬអាចសុំឲ្យរំលាយក្រុមហ៊ុន (ដូចដែលមានចែងក្នុងមាត្រា ៥៣ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម ចំណុច ក បញ្ជាក់ថា តុលាការអាចរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានដោយសារមូលហេតុអនុវត្តផ្ទុយពីច្បាប់)។

មួយវិញទៀត នៅក្នុងជីវិតជាក់ស្ដែងនៃអាជីវកម្ម ដើម្បីប្រសិទ្ធិភាពនៃការគ្រប់គ្រងក្រុមហ៊ុន សហកម្មសិទ្ធិករអាចព្រមព្រៀងរវាងគ្នា និងគ្នា ដើម្បីផ្ដត់ផ្គង់ឲ្យសហកម្មសិទ្ធិកររូបណាម្នាក់ ឬច្រើននាក់ដែលមានបំណិន និងចំណេះដឹងខាងការគ្រប់គ្រង និងអាជីវកម្ម ឲ្យធ្វើការចាត់ចែងកិច្ចការក្រុមហ៊ុនជំនួសខ្លួន។ ទោះបីយ៉ាងនេះក្ដី សហកម្មសិទ្ធិករដែលផ្ដល់សិទ្ធិឲ្យសហកម្មសិទ្ធិករដទៃទៀតចាត់ចែងកិច្ចការជំនួសខ្លួន នៅតែមានសិទ្ធិចូលរួមនៅក្នុងការសម្រេចលើកិច្ចការណាមួយតាមចិត្តចង់របស់គេ។ ម្យ៉ាងវិញទៀតនោះ សហកម្មសិទ្ធិករអាចព្រមព្រៀងគ្នា ជួលអ្នកដទៃដែលមិនមែនជាសហកម្មសិទ្ធិករឲ្យគ្រប់គ្រងក្រុមហ៊ុនជួសខ្លួនក៏បាន។

- **សម្លេងដែលចាំបាច់ក្នុងការធ្វើសេចក្ដីសម្រេច**

នាខណៈពេលដែលសិទ្ធិចូលរួមនៅក្នុងការចាត់ចែងក្រុមហ៊ុនជាសិទ្ធិដាច់ខាតដែលសហកម្មសិទ្ធិករគ្រប់រូបត្រូវមានស្មើគ្នា សហកម្មសិទ្ធិករអាចព្រមព្រៀងគ្នា ដើម្បីកំណត់ចំនួនសម្លេងដែលអាចអនុម័តលើកិច្ចការអ្វីមួយដោយមានសុពលភាព។ ប្រសិនបើមិនមានការព្រមព្រៀងគ្នាក្នុងការកំណត់ចំនួនសម្លេងជាក់លាក់ណាមួយ ដើម្បីអនុម័តលើកិច្ចការរបស់ក្រុមហ៊ុននោះទេ ច្បាប់សន្មតថា សម្លេងភាគច្រើនដោយធៀបអាចអនុម័តលើកិច្ចការណាមួយប្រកបដោយសុពលភាព[24]។ ដូចជាក្នុងករណី សហកម្មិសទ្ធិករអាចកំណត់ថារាល់ការសម្រេចបញ្ជាទិញឧបករណ៍សម្រប់ដាក់ការិយាល័យដែលមានតម្លៃតិចជាង ៥ លាន រៀលអាចធ្វើបានដោយសហកម្មសិទ្ធិករ "A" ហើយរាល់ការចំណាយលើសពី ៥ លាន រៀលត្រូវសម្រេចដោយសម្លេងភាគច្រើនដោយធៀប (បើក្រុមហ៊ុននេះមានសមាជិក ៣ បីនាក់ គឺត្រូវមានសម្លេងពីរនាក់អនុម័ត)។ ផ្ទុយទៅវិញបើសហកម្មសិទ្ធិករមិនបានចែងពីចំនួនសម្លេងដើម្បីអនុម័តលើកិច្ចការអ្វីមួយទេ ចំនួនសម្លេងដែលត្រូវអនុម័តបាន គឺសម្លេងភាគច្រើនដោយធៀប ក្នុងករណីនេះ គឺពីរសម្លេង។

គួបញ្ជាក់ផងដែលថា ការសម្រេចណាដែលមិនស្របតាមលក្ខខណ្ឌនៃការអនុម័តទេនោះ នាំឲ្យសេចក្ដីសម្រេចនោះមិនមានសុពលភាពរវាងសហកម្មសិទ្ធិករទាំងអស់ តែមិនមែនគ្មានសុពលភាពចំពោះភាគីទីបីទេ ។ សហកម្មសិទ្ធិករម្នាក់ទៀត ដែលធ្វើសកម្មភាពផ្អែកលើសេចក្ដីសម្រេចដោយគ្មានសុពលភាព ត្រូវទទួលខុសត្រូវចំពោះសហកម្មសិទ្ធិករនោះដោយអាចទាមទារឲ្យសហកម្មសិទ្ធិករដែលបំពាននោះជួសជុលការខូចខាតដល់ខ្លួន ដែលបណ្ដាលមកពីការសម្រេចនោះ[25]។ មាត្រា ៣៨ កថាខ័ណ្ឌទី២ ចែងពីលក្ខណៈនៃសេចក្ដីសម្រេចដែលមានសុពលភាព៖ លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរាល់សេចក្ដីសម្រេចត្រូវធ្វើឡើងដោយការបោះ

[24] ច្បាប់ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រទី១២៥។

[25] ច្បាប់ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦។

ឆ្នោតតាមសម្លេងភាគច្រើនដោយបៀបរបស់សហកម្មសិទ្ធិទូទៅដោយមិនគិតតម្លៃអត្ថប្រយោជន៍របស់គេនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ។ ប៉ុន្តែសេចក្តីសម្រេចក្នុងការកែប្រែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវធ្វើឡើងដោយសម្លេងឆ្នោតជាឯកច្ឆន្ទ។ ត្រង់ចំណុចនេះ ចង់បង្ហាញថាសហកម្មសិទ្ធិករម្នាក់ៗសហកម្មសិទ្ធិករមានសម្លេងស្មើគ្នាទោះបីសហកម្មសិទ្ធិកររូបណាមានភាគទុនតិចជាងសហកម្មសិទ្ធិករផ្សេងទៀតក៏ដោយ មានន័យថាសហកម្មសិទ្ធិករម្នាក់អាចបោះឆ្នោតបានមយួសម្លេងដូចគ្នា។ ប៉ុន្តែការសម្រេចដែលយកជាការបាននោះ លុះត្រាតែមានសម្លេងភាគច្រើនដោយធៀប។ ក្នុងករណីដែលក្រុមហ៊ុនមួយមានសហកម្មសិទ្ធិករបួននាក់ នៅពេលសម្រេចលើកិច្ចការមួយគេត្រូវការឲ្យមានសហកម្មសិទ្ធិករបីនាក់ដើម្បីគាំទ្រសំណើធ្វើការនោះ។ ហើយប្រសិនបើមានសហកម្មិសិទ្ធិករពីរនាក់អនុប្បវាទ ពីរនាក់គាំទ្រ និងមួយនាក់ប្រឆាំង គេមិនអាចថា សំណើនោះទទួលបានការគាំទ្រដោយសម្លេងភាគច្រើនដោយធៀបទេ ទោះបីជាសម្លេងគាំទ្រសំណើមានច្រើនជាងសម្លេងប្រឆាំងក៏ដោយ។ សម្លេងភាគច្រើនដោយធៀបគឺជាសម្លេងភាគច្រើននៃសហកម្មសិទ្ធិករទាំងអស់។ ផ្ទុយទៅវិញ ការកំណត់សម្លេងដើម្បីធ្វើការសម្រេចលើកិច្ចការអ្វីមួយ អាចធ្វើទៅបានអាស្រ័យលើកិច្ចសន្យាបង្កើតក្រុមហ៊ុន។

- **សិទ្ធិទទួលព័ត៌មានពីអាជីវកម្ម**

សហកម្មសិទ្ធិករម្នាក់ៗត្រូវមានសិទ្ធិក្នុងការទទួលពត៌មានដោយពេញលេញ ដើម្បីអាចចូលរួមក្នុងការគ្រប់គ្រងក្រុមហ៊ុនមួយបាន វាជាការចាំបាច់សម្រាប់កិច្ចការទាំងអស់ និងចំពោះរបៀបដែលអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានដឹកនាំ។ ការដែលសហកម្មសិទ្ធិករខ្លះទុកឲ្យសហកម្មសិទ្ធិករដទៃទៀតដឹកនាំ និងចាត់ចែងក្រុមហ៊ុនជំនួសខ្លួន នេះមិនមានន័យថា សហកម្មសិទ្ធិករ ដែលមិនគ្រប់គ្រងដោយផ្ទាល់បានបោះបង់សិទ្ធិចង់ដឹងពីប្រតិបត្តិការរបស់ក្រុមហ៊ុនឡើយ។ សហកម្មសិទ្ធិម្នាក់ៗមានសិទ្ធិស៊ើបអង្កេតទង្វើទាំងឡាយរបស់ក្រុមហ៊ុនដើម្បីធ្វើឲ្យគេពេញចិត្តខ្លួនឯងថាអាជិវកម្មរបស់ក្រុមហ៊ុនបានដំណើរការទៅដោយមានការគោរពគោលការណ៍សុទ្ធចិត្ត និងការអនុវត្តល្អរបស់ក្រុមហ៊ុន។ សហកម្មសិទ្ធិករ ដែលគ្រប់គ្រងក្រុមហ៊ុន ត្រូវបំពេញលើករណីយកិច្ចបើកចំហឲ្យសហកម្មសិទ្ធិករដទៃទៀតអនុវត្តសិទ្ធិរបស់ពួកគេ ដើម្បីដឹងពីពត៌មានទាំងអស់របស់ក្រុមហ៊ុន។ សិទ្ធិទទួលពត៌មានពីអាជីវកម្មរួមមានសិទ្ធិពិនិត្យបញ្ជី (ឬគណនេយ្យរបស់ក្រុមហ៊ុន) របាយការណ៍ ផែនការ និងសកម្មភាពរបស់ក្រុមហ៊ុន។ គេអាចពិនិត្យបញ្ជី និងឯកសារដទៃទៀតដោយខ្លួនឯងផ្ទាល់ ឬតែងតាំងអ្នកតំណាងម្នាក់ៗពិនិត្យជំនួសក៏បាន។ សិទ្ធិទទួលពត៌មាននាំឲ្យមានកាតព្វកិច្ចត្រូវផ្តល់ពត៌មានដល់សហកម្មសិទ្ធិករផងដែរ[26]។ មាត្រា ៣៩ ចែងថា៖ សហកម្មសិទ្ធិករទូទៅម្នាក់ៗមានសិទ្ធិទទួលពត៌មានអំពីកិច្ចការទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិពិគ្រោះយោបល់លើសៀវភៅបញ្ជី និងកំណត់ហេតុទោះបីជាសហកម្មសិទ្ធិទូទៅនោះគ្មានតួនាទីជាអ្នកគ្រប់គ្រងក៏ដោយ។ នៅក្នុងការអនុវត្តសិទ្ធិនេះ

[26] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦។

សហកម្មសិទ្ធិករទូទៅមិនត្រូវបង្អាក់កិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុនដោយមិនមានហេតុផលត្រឹមត្រូវ ឬមិនត្រូវធ្វើឲ្យរាំងស្ទះដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀតក្នុងការអនុវត្ត សិទ្ធិដូចគ្នាឡើយ។

- **សិទ្ធិទទួលការទូទាត់សេវាកម្មដែលផ្តល់ឲ្យក្រុមហ៊ុន**

សហកម្មសិទ្ធិករម្នាក់ៗជាម្ចាស់ក្រុមហ៊ុន គេមិនមែនជានិយោជិត ឬជាអ្នកជាប់កិច្ចសន្យាការងាររបស់ក្រុមហ៊ុនទេ ដូច្នេះគេមិនអាចទាមទារតម្លៃតបស្នងពីការងារដែលគេបានធ្វើឲ្យក្រុមហ៊ុនទេ។ មាត្រា ២៦ ចែងថា ៖ គ្មានសហកម្មសិទ្ធិករណាម្នាក់ត្រូវទទួលប្រាក់បៀវត្សពីការធ្វើពាណិជ្ជកម្មក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ។

ទោះបីសហកម្មសិទ្ធិករគ្មានសិទ្ធិជាស្វ័យប្រវត្តិ ដើម្បីទទួលការទូទាត់សេវាកម្មដែលខ្លួនបំពេញចំពោះក្រុមហ៊ុន សហកម្មសិទ្ធិករទាំងអស់អាចចែងនៅក្នុងកិច្ចសន្យាក្រុមហ៊ុន ដើម្បីអនុញ្ញាតឲ្យសហកម្មសិទ្ធិករដែលចំណាយពេលវេលារបស់ខ្លួនដើម្បីធ្វើការឲ្យក្រុមហ៊ុន បានទទួលការទូទាត់ចំពោះសេវាកម្មរបស់ខ្លួន។ ប៉ុន្តែកិសន្យានោះតែចែងពីការទូទាត់សេវាកម្មរបស់សហកម្មសិទ្ធិករម្នាក់ៗ ក្នុងឋានៈជានិយោជិតរបស់ក្រុមហ៊ុន ដែលនឹងត្រូវកំណត់ដោយកិច្ចសន្យាការងាររវាងក្រុមហ៊ុន និងសហកម្មសិទ្ធិករ។ ឧទាហរណ៍ថា សហកម្មសិទ្ធិករ A B និង C បានព្រមព្រៀងបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមួយ ពួកគេបានផ្តាក់ផ្ទុកឲ្យ C ជាអ្នកចាត់ចែងការទូទៅរបស់ក្រុមហ៊ុន។ ដោយសារ C បានលះបង់ពេលវេលារបស់ខ្លួនមកធ្វើការពេញម៉ោងឲ្យក្រុមហ៊ុន អ្នកទាំងបីនាក់អាចចែងនៅក្នុងកិច្ចសន្យាក្រុមហ៊ុន ដើម្បីអនុញ្ញាតឲ្យ C ចុះកិច្ចសន្យាការងារជាមួយក្រុមហ៊ុន ហើយត្រូវទទួលបានប្រាក់បៀវត្ស ៥ លានរៀលក្នុងមួយខែ។

ដើម្បីបានការទទួលផលពីការធ្វើអាជីវកម្មរបស់គេ សហកម្មសិទ្ធិករក៏មានសិទ្ធិដកហូទយកប្រាក់ខ្លះពីប្រាក់ចំណេញដែលអាជីវកម្មបានបញ្ចេញមកដែរ។ តែការដកហូតយកប្រាក់ចំណេញនេះត្រូវតែមានចែងនៅក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ។ ចំពោះកិច្ចសន្យាអាចចែងពីពេលណាដែលសហកម្មសិទ្ធិករអាចដកយកប្រាក់ចំណេញបានហើយក្នុងអត្រាប៉ុន្មានព្រោះពេលខ្លួនក្រុមហ៊ុនត្រូវការរក្សាទុកប្រាក់ចំណេញខ្លះ ដើម្បីធ្វើជាទុនបន្ថែមទៀតដើម្បីពង្រីកអាជីវកម្ម[27]។

- **សិទ្ធិទទួលការទូទាត់វិញនូវការចំណាយរបស់សហកម្មសិទ្ធិករ**

មានពេលខ្លះ សហកម្មសិទ្ធិករម្នាក់បានចំណាយប្រាក់ផ្ទាល់ខ្លួនដើម្បីធ្វើការអ្វីមួយជាប្រយោជន៍ក្រុមហ៊ុន ដូចជាចេញប្រាក់ជួសជុលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ទិញឧបករណ៍សម្រាប់បំរើកិច្ចការក្រុមហ៊ុនជាដើម។ ការចំណាយទាំងនេះចាត់ទុកដូចជាកម្ចីរបស់សហកម្មសិទ្ធិករនោះទៅឲ្យក្រុមហ៊ុន។ ដូច្នេះសហកម្មសិទ្ធិករនោះត្រូវតែមានសិទ្ធិទទួលបានពីក្រុមហ៊ុននូវការចំណាយនោះមកវិញ។ ការចំណាយនេះត្រូវធ្វើនៅក្នុងរង្វង់កិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន និងដោយសុទ្ធចិត្ត។ មាត្រា ២៨ ចែងថា៖ សហកម្មសិទ្ធិករទូទៅដែលប្រកកិច្ចការពាណិជ្ជកម្មដោយស្មោះត្រង់ ចំពោះក្រុមហ៊ុន មានសិទ្ធិទទួលនូវសំណងនៃការខូចខាតដែលខ្លួនបានធ្វើក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិនោះ ហើយមានសិទ្ធិ

[27] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ។

ទទួលនូវ សំណងនៃការខូតខាត់ចំពោះកិច្ចសន្យាដែលខ្លួនបានធ្វើ និងការខាត់បង់ទាំងឡាយដែលខ្លួនទទួលរងនៅក្នុងការប្រតិបត្តិពាណិជ្ជកិច្ច សម្រាប់ក្រុមហ៊ុននោះ។ ឧទាហរណ៍ សហកម្មសិទ្ធិករម្នាក់នៃក្រុមហ៊ុនសហកម្មសិទ្ធិ ដែលធ្វើអាជីវកម្មខាងម៉ាស៊ីនកិនស្រូវ បានទិញម៉ាស៊ីនថតរូបមួយសម្រាប់ក្រុមហ៊ុនក្នុងតម្លៃ ២,០០០ ដុល្លា (តម្លៃធម្មតានៅលើទីផ្សារត្រឹមតែ ៨០០ ដុល្លារ)។ សហកម្មសិទ្ធិករនោះប្រហែលជាមិនបានចំណាយប្រាក់ដោយសុទ្ធសិទ្ធទេ ដោយហេតុថា ក្រុមហ៊ុនប្រហែលជាមិនចាំបាច់ត្រូវការម៉ាស៊ីនថតរូប ហើយតម្លៃក៏ខុសច្រើនពីតម្លៃទីផ្សារដែរ។ ក្នុងករណីនេះដែល ក្រុមហ៊ុនអាចប្រកែកមិនទូទាត់ប្រាក់ថ្លៃទិញម៉ាស៊ីនថតរូបនេះឲ្យសហកម្មសិទ្ធិករនោះវិញទេ ដោយផ្អែកលើមូលហេតុថា សហកម្មសិទ្ធិករនោះចំណាយប្រាក់ដែលមិនទាក់ទង នឹងកិច្ចការរបស់ក្រុមហ៊ុន និងដោយមិនមានភាពស្មោះត្រង់។

- **សិទ្ធិធ្វើអាជីវកម្មដោយឡែក**

គ្រប់សហកម្មសិទ្ធិករទាំងអស់អាចប្រកបអាជីវកម្មណាមួយដោយឡែកក្រៅពីអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលខ្លួនជាសមាជិក កាលណាគ្មានកិច្ចព្រមព្រៀងកម្រិតសិទ្ធិនេះ ហើយអាជីវកម្មដោយឡែកនោះមិនឆក់យកឱកាសអាជីវកម្មរបស់ក្រុមហ៊ុន ឬមិនប្រកួតប្រជែង នឹងអាជីវកម្មរបស់ក្រុមហ៊ុន។ សិទ្ធិនេះកើតចេញពីគោលការណ៍នៃកាតព្វកិច្ចសុទ្ធចិត្ត (Duty of good faith) ដែលចែងនៅក្នុងមាត្រា ២៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មដែលមានសេចក្តីថា៖ សហកម្មសិទ្ធិករទូទៅម្នាក់ៗត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុននូវរាល់ផលកម្រៃបានមកពីការធ្វើអាជីវកម្មណាមួយនៅក្នុងពាណិជ្ជកម្ម ឬពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅផ្សេងទៀត។ សហកម្មសិទ្ធិករទូទៅទាំងឡាយ មិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ ។ ឧទាហរណ៍ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ A B និង C មានអាជីវកម្មរថយន្តដឹកជញ្ជូនអ្នកដំណើរខ្សែភ្នំពេញ-បាត់ដំបង។ A មិនអាចទៅប្រកបអាជីវកម្មដឹកជញ្ជូនភ្នំពេញ-បាត់ដំបូងសម្រាប់ខ្លួនឯងដោយគ្មាការយល់ព្រមជាងឯកច្ឆន្ទពី B និង C បានឡើយ។ បើ A ទទឹងធ្វើអាជីវកម្មនេះ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ A B និង C អាចប្តឹងទាមទារឲ្យ A សងទូទាត់ការបាត់បង់ចំណូល ដែលជាលទ្ធផលនៃការប្រកួតប្រជែងរបស់ D។ ប៉ុន្តែ A មានសេរីភាពក្នុងការប្រកបអាជីវកម្មផ្សេងពីរថយន្តដឹកជញ្ជូនអ្នកដំណើរ ឬអាចប្រកបអាជីវកម្មរថយន្តដឹកអ្នកដំណើរដែរ ប៉ុន្តែមិនមែនខ្សែភ្នំពេញ-បាត់ដំបង។

**១.២.៣ អំណាច**

អំណាចរបស់សហកម្មសិទ្ធិករជាអំណាច ដែលចេញមកពីទំនាក់ទំនងក្នុងភាពជាអ្នកតំណាង។ ទំនាក់ទំនងនេះត្រូវបានបញ្ញត្តិក្នុងមត្រា ៤០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មថា សហកម្មសិទ្ធិករទូទៅម្នាក់ៗ គឺ ជាភ្នាក់ងាររបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅក្នុងទំនាក់ទំនងជាមួយតតិយជន ដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នា ដោយស្មោះ

ត្រង់ហើយសហកម្មសិទ្ធិករទូទៅទាំងនោះ ត្រូវជាប់កាតព្វកិច្ចចំពោះក្រុមហ៊ុននូវរាល់អំពើដែលខ្លួនបានអនុវត្តក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ ការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវបានចាត់ទុកជាគ្មានប្រសិទ្ធិភាព[28]។

យោងតាមមាត្រានេះ រាល់អំពើរបស់សហកម្មសិទ្ធិករណាម្នាក់នៅក្នុងក្របខ័ណ្ឌ នៃការងាររបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នឹងដាក់កាតព្វកិច្ចទៅលើក្រុមហ៊ុននិងទៅលើក្រុមហ៊ុននិងទៅលើសហកម្មសិទ្ធិករដទៃទៀត។ ដូច្នេះ សហកម្មសិទ្ធិករម្នាក់ៗមានតួនាទីជាភ្នាក់ងារ ឬតំណាងរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ តាមមាត្រា ៣៧ កថាខ័ណ្ឌទី២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចែងថា សកកម្មភាពដែលអនុវត្តដោយសហកម្មសិទ្ធិករទូទៅម្នាក់ ដែលទាក់ទងទៅនឹងសកម្មភាពរួមរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវជាប់កាតព្វកិច្ចទៅនឹងសហកម្មសិទ្ធិករម្នាក់ទៀតដែរ[29]។

ក្នុងន័យនេះ សរុបមកក្រុមហ៊ុនសហកម្មសិទ្ធិទូទៅជាម្ចាស់សិទ្ធិនៃសហកម្មសិទ្ធិករទូទៅ រីឯសហកម្មសិទ្ធិករម្នាក់មានតួនាទីជាម្ចាស់សិទ្ធិលើសហកម្មសិទ្ធិករម្នាក់ទៀតផង និងជាភ្នាក់ងារ ឬ តំណាងរបស់សហកម្មសិទ្ធិករម្នាក់ទៀតផង។ ទំនាក់ទំនងភាពជាតំណាងរវាងក្រុមហ៊ុនសហកម្មសិទ្ធិ និង សហកម្មសិទ្ធិករ និងរវាងសហកម្មសិទ្ធិករគ្នាឯង។

ដោយសារទំនាក់ទំនងរវាងក្រុមហ៊ុននិងសហកម្មសិទ្ធិករ មួយផ្នែក និងទំនាក់ទំនងរវាងសហកម្មសិទ្ធិករនិងសហកម្មសិទ្ធិករ មួយផ្នែកទៀត ជាទំនាក់ទំនងដែលមានភាពជាតំណាង ដូច្នេះទំនាក់ទំនងនេះត្រូវគ្រប់គ្រងដោយបញ្ញត្តិច្បាប់ទាក់ទងនឹងភាពតំណាង ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។ ជាមួយគ្នានេះគោលការណ៍នៃទំនាក់ទំនង ដែលចែងនៅក្នុងមាត្រា ៤០ នៃច្បាប់សហគ្រាសពាណិជ្ជកម្មខាងលើក៏មានលក្ខណៈស្របគ្នាជាមួយនឹងទំនាក់ទំនងតំណាងដែលចែងក្នុងមាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណី ដែលបានចែងថា៖ ការតំណាង ការតំណាងសំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យាជាមួយភាគីម្ខាងទៀត ដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះគឺធ្វើសម្រាប់ម្ចាស់សិទ្ធិ ក្នុងទំហំនៃសិទ្ធិតំណាង[30]។ អំណាចរបស់អ្នកតំណាង ឬ ភ្នាក់ងារមានពីរប្រភេទ គឺ អំណាចពិត និង អំណាចដែលមានលក្ខណៈជារូបភាព[31] ដោយអំណាចទាំងពីរនេះនឹងធ្វើការបកស្រាយនៅក្នុងកថាខណ្ឌខាងក្រោម។

- **អំណាចពិត**

អំណាចពិតកើតចេញពីកិច្ចសន្យារវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ដែលនៅក្នុងកិច្ចសន្យានោះមានកំណត់ពីទំហំ ឬ វិសាលភាពនៃសិទ្ធិនិងអំណាចដែលអ្នកតំណាងអាចមាន។ អំណាចដែលម្ចាស់សិទ្ធិប្រគល់ឲ្យតំណាងអាចជាលាយលក្ខណ៍អក្សរ ឬ អាចជាការនិយាយផ្ទាល់មាត់ (តាមរយៈកិច្ចសន្យាសរសេរ ឬ ផ្ទាល់មាត់) និង អំណាចដែល

[28] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៤០។

[29] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣៧។

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៦៤។

[31] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ១៤៨។

កើតចេញពីការសន្និដ្ឋានពីសំដី អាកប្បកិរិយា។ អំណាចពិតនេះជាទំនាក់ទំនងផ្ទៃក្នុងរវាងម្ចាស់សិទ្ធិ និងអ្នកតំណាងប៉ុណ្ណោះ[32]។

- **អំណាចពិតជាក់លាក់**

អំណាចពិតជាក់លាក់ត្រូវបានបញ្ជាក់នៅក្នុងកិច្ចសន្យា ទោះបីសរសេរ ឬ ផ្ទាល់មាត់ក្តី។ តាមមាត្រា ៣៦៦ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីចែងថា ទំហំនៃសិទ្ធិតំណាងត្រូវកំណត់ដោយកិច្ចសន្យា ដែលប្រគល់សិទ្ធិតំណាងទៅឲ្យតំណាង។ ក្នុងករណីដែលសិទ្ធិតំណាងត្រូវកើតឡើងដោយបញ្ញត្តិនៃច្បាប់ ទំហំនៃសិទ្ធិតំណាងក៏ត្រូវកំណត់ដោយច្បាប់ដែរ[33]។ ឧទាហរណ៍៖ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមួយរកស៊ីខាងលក់គ្រឿងសង្ហារឹម ហើយកិច្ចសន្យាក្រុមហ៊ុនចែងថា សហកម្មសិទ្ធិម្នាក់អាចបញ្ជាទិញគ្រឿងសង្ហារឹម ក្នុងតម្លៃត្រឹម ២០លានរៀល ដោយមិនបាច់ពិគ្រោះជាមួយសហកម្មសិទ្ធិករដទៃទៀត។ នេះអំណាចពិតជាក់លាក់ ដែលសហកម្មសិទ្ធិករម្នាក់ៗមាន នៅក្នុងការទិញដូរឥវ៉ាន់ចូលក្រុមហ៊ុន។ សហកម្មសិទ្ធិករដែលបញ្ជាទំនិញលើសពី ២០លានរៀលដោយគ្មានការពិគ្រោះជាមួយសហកម្មសិទ្ធិករដទៃទៀតត្រូវចាត់ទុកថាបានប្រព្រឹត្តលើសអំណាចដោយសារខ្លួនបានធ្វើលើសពីទំហំនៃសិទ្ធិដែលខ្លួនមាន។

- **អំណាចពិតវាទរហិត**

នៅក្នុងករណីជាច្រើននៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមិនបានកំណត់គ្រប់តែសិទ្ធិ និង ករណីយកិច្ចឲ្យសហកម្មសិទ្ធិករនោះទេ សហកម្មសិទ្ធិត្រូវប្រើសុភវិនិច្ឆ័យរបស់ខ្លួនគិតថាធ្វើឲ្យបានសម្រេចកម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន។ អំណាចពិតវាទរហិត អាចត្រូវបានប្រមាណមើលតាមលក្ខណៈវិនិច្ឆ័យនានា ជាពិសេសផ្អែកទៅលើប្រភេទនៃអាជីវកម្ម និង ទំនៀមទម្លាប់ឧស្សាហកម្ម។ បើសកម្មភាពរបស់សហកម្មសិទ្ធិករមានការចាំបាច់គួរសម ដើម្បីដឹកនាំអាជីវកម្មក្នុងដំណើរធម្មតារបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ហើយកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមិនបានហាមឃាត់សកម្មភាពបែបនោះទេ អំណាចរបស់សហកម្មសិទ្ធិករត្រូវបានគេសន្និដ្ឋានថាមានដើម្បីធ្វើកិច្ចការនោះ[34]។

ឧទាហរណ៍ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមួយរកស៊ីលក់ដូរឥវ៉ាន់ សហកម្មសិទ្ធិករអាចរកទិញលក់ ប្រភេទទំនិញដែលគេជួញដូរជាទម្លាប់នៅក្នុងអាជីវកម្មប្រភេទនេះ។ ឧទាហរណ៍មួយទៀត ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមួយមានអាជីវកម្មខាងជួលអាគារជាលំនៅឋាន។ សហកម្មសិទ្ធិករ A មាននាទីជាអ្នកមើលការខុសត្រូវលើកិច្ចការអាគារ។ ក្រុមហ៊ុនមិនបាចែងបញ្ជាក់ ពីកិច្ចការអ្វីខ្លះដែល A ត្រូវបំពេញទេ។ A បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនមួយទៀតដើម្បីតាំងម៉ាស៊ីនត្រជាក់ និង កែលំអអាគារឲ្យមានរូបសម្ផស្សនិងសោភ័ណភាពទាក់ទាញអតិថិជនឲ្យមកជួលអគារ។ ទោះបីមិនសប្បាយចិត្តនឹងការកែលំអអាគារនេះក្តី សហកម្មសិទ្ធិករដទៃទៀតមិនអាចប្រកែកថា A គ្មានអំណាចចុះកិច្ចសន្យារបស់ A ក្តីវិធានច្បាប់ទូទៅសន្មតថា A មានអំណាចពិតវាទរហិត ក្នុងការធ្វើកិច្ចការណាមួយដែលស្ថិតនៅ

---

[32] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ១៤៨។

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៦៦.១។

[34] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ១៤៩។

ក្នុងវង្វង់កម្មវត្ថុនៃក្រុមហ៊ុនសហកម្មសិទ្ធិ ឬ និយាយម៉្យាងទៀតតាមភាសានៃក្រមរដ្ឋប្បវេណីខែរថា A មានអំណាចពិតវាទរហិតនៅក្នុង ទំហំនៃសិទ្ធិតំណាង។ ទំហំនៃសិទ្ធិតំណាងនេះ គឺ ការធ្វើឲ្យអាជីវកម្មជួលអាគារបានអូសទាញអតិថិជនឲ្យបានច្រើន និងបានផលកំរៃដល់ក្រុមហ៊ុន។ ការតាំងម៉ាស៊ីនត្រជាក់ និង ការកែលំអអាគារនេះស្ថិតនៅ ក្នុងទំហំនៃសិទ្ធិដែលក្រុមហ៊ុនប្រគល់ឲ្យ។ ដូច្នេះ កិច្ចសន្យាដែល A បានចុះជាមួយក្រុមហ៊ុនផ្គត់ផ្គង់ជាមួយនោះ ចងកាតព្វកិច្ចលើក្រុមហ៊ុននិងសហកម្មសិទ្ធិករដទៃទៀត[35]។

នៅក្នុងក្រមរដ្ឋប្បវេណីខ្មែរ កាលណាទំហំនៃសិទ្ធិមិនបានកំណត់ជាក់លាក់ទេនោះអំណាចរបស់អ្នកតំណាងអាចអនុវត្តបានត្រឹមតែកិច្ចការថែរក្សា និង កិច្ចការកែលំអ និង មិនអាចលាតសន្ធឹងទៅដល់កិច្ចការណាដែលមានចរិតលក្ខណៈធ្វើឲ្យមានការផ្លាស់ប្តូរលក្ខណៈវត្ថុ និង សិទ្ធិជាកម្មវត្ថុនៃតំណាងបានឡើយ។ តាមមាត្រា ៣៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មចែងថា រាល់សហកម្មសិទ្ធិករទូទៅមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅហើយការអនុវត្តសិទ្ធិនោះមិនត្រូវបានបង្អាក់ដោយសារកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ។ លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រាល់សេចក្តីសម្រេចត្រូវធ្វើឡើងដោយការបោះឆ្នោតតាមសំឡេងភាគច្រើនដោយប្រៀបរបស់សហកម្មសិទ្ធិករទូទៅ ដោយមិនគិតតម្លៃអត្ថប្រយោជន៍របស់គេនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ។ ប៉ុន្តែសេចក្តីសម្រេចក្នុងការកែប្រែកិច្ចសន្យា នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវធ្វើឡើងដោយសំឡេងឆ្នោតជាឯកច្ឆន្ទ[36]។ ដូច្នេះ ក្នុងករណីក្រុមហ៊ុនសហកម្មសិទ្ធិ បើកិច្ចសន្យាបង្កើតក្រុមហ៊ុនមិនបានចែងពីទំហំនៃអំណាចរបស់សហកម្មសិទ្ធិករទេ ឬ សហកម្មសិទ្ធិករភាគច្រើនមិនបានអនុម័តយល់ព្រមលើកិច្ចការណារទេ។ សហកម្មសិទ្ធិករម្នាក់ៗមានអំណាចពិតវាទរហិត ត្រឹមតែធ្វើកិច្ចការណាដែលសំរាប់ថែរក្សា ឬ សម្រាប់កែលំអតែប៉ុណ្ណោះ។ មាត្រា ៣៦៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីចែងថា ក្នុងករណីដែលទំហំ នៃសិទ្ធិតំណាងមិនបានកំណត់ទេ អ្នកតំណាងត្រូវមានសិទ្ធិចំពោះអំពើថែរក្សា និងអំពើកែលំអ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះអំពើកែលំអដែលផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការតំណាង[37]។ ក្នុងមាត្រានេះមានន័យថា កាលណាទំហំនៃសិទ្ធិតំណាងមិនត្រូវបាន កំណត់ឲ្យបានជាក់លាក់ទេ អ្នកតំណាងដែលត្រូវបានប្រគល់អំណាចឲ្យថែរក្សាវត្ថុមួយ មានអំណាចត្រឹមតែការពារវត្ថុ ឬ សិទ្ធិ ដូចជាអាចចុះកិច្ចសន្យាជាមួយក្រុមហ៊ុនជួសជុលឲ្យជួសជុលវត្ថុនោះ ដើម្បីរក្សាវត្ថុនោះ។ រីឯកិច្ចការកែលំអវិញអ្នកតំណាងមានអំណាចអាចធ្វើឲ្យវត្ថុមួយ ឬ សិទ្ធិមួយកើនតម្លៃ ដូចជាជួសជុលអាគារដើម្បីធ្វើឲ្យគុណភាពអាគារនោះបានប្រសើរជាងមុន។

យោងតាមមាត្រា ៤១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានចែងថា សហកម្មសិទ្ធិករទូទៅម្នាក់ដែលបានចុះកិច្ចសន្យាជាមួយតតិយជនត្រូវជាប់ កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលណាដែលកាតព្វកិច្ចនោះស្ថិត ក្នុងវង្វង់អាជីវកម្មរបស់ក្រុមហ៊ុន ឬ នៅពេលណាដែលកម្មវត្ថុ នៃកិច្ចសន្យានោះជាទ្រព្យ សម្បត្តិដែលត្រូវបាន

[35] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ១៥០។

[36] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៣៨។

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៦៦.២។

ប្រើប្រាស់ដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ[38]។ ក្នុងមាត្រានេះបានបង្ហាញពី ទំហំនៃអំណាចដែលសហកម្មសិទ្ធិករ គឺមានចំពោះកិច្ចការអ្វីដែលសហកម្មសិទ្ធិករបានធ្វើ ក្នុងវង្វង់អាជីវកម្ម របស់ក្រុមហ៊ុន ឬ ចំពោះកិច្ចសន្យាទាំងឡាយដែលក្នុងនោះរួមមានជាមួយនឹងតតិយជនផងដែរ។ ជាឧទាហរណ៍ដែលធ្វើឡើងក្នុងការទិញដូររបស់ដែលសម្រាប់ការប្រើប្រាស់នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ កិច្ចការក្នុង វង្វង់អាជីវកម្ម គឺជាសកម្មភាពទាំងឡាយណាដែលមនុស្សទូទៅយល់ថាចាំបាច់ ដើម្បីចាត់ចែងសហគ្រាសពាណិជ្ជកម្មមួយឲ្យបានជោគជ័យ ដែលគេវិនិច្ឆ័យទៅលើចរិតលក្ខណៈនៃ សហគ្រាសនោះ និង ដោយសកម្មភាព របស់អ្នកដទៃដែលធ្វើសកម្មភាពនៅក្នុងមុខរបរដូចគ្នា និង វិស័យដូចគ្នា។ ឧទាហរណ៍ កិច្ចការក្នុងវង្វង់អាជីវកម្មនៃក្រុមហ៊ុនលក់សំណង់ គឺ ការទិញលក់សារពើភ័ណ្ឌ ទាក់ទងនឹងគ្រឿងសំណង់ ការទិញដូរឧបករណ៍សំរាប់ដំណើរការក្រុមហ៊ុន។ ស្របតាមអន្តន័យនេះ ចាត់ទុកថាកិច្ចការណាមួយដែលស្ថិតនៅក្នុងវង្វង់អាជីវកម្ម គឺ ជាកិច្ចការទាំងឡាយណាដែលធ្វើឡើងក្នុងគោលដៅធ្វើឲ្យក្រុមហ៊ុនរីកចម្រើន ឬជោគជ័យ (ទោះលទ្ធផលចុងក្រោយត្រូវខាតបង់ក្តី)។ ដើម្បីវាស់វែងថា តើកិច្ចការនោះ សំដៅធ្វើឲ្យក្រុមហ៊ុនរីកចម្រើននោះ គេមិនយកហេតុផលអត្តនោម័តរបស់សហកម្មសិទ្ធិករដែលធ្វើកិច្ចការនោះទេ តែគេត្រូវវិនិច្ឆ័យថា បើក្រុមហ៊ុនមួយមានរបរដូចគ្នា តើសហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុននោះនឹងធ្វើកិច្ចការ ដូចសហកម្មសិទ្ធិករខាងដើម ដែលអះអាងថាខ្លួនធ្វើកិច្ចការនេះដើម្បីឲ្យក្រុមហ៊ុនបានរីកចម្រើនដែរ ឬ ទេ។ ឧទាហរណ៍ សហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុនសំណង់ម្នាក់ ដែលឃើញតម្លៃដីកាន់តែឡើងថ្លៃ ក៏សម្រេចចិត្តតែឯកឯងយកប្រាក់ក្រុមហ៊ុនទិញដីទុកលក់ ដោយអះអាងថាខ្លួនមានបំណងល្អដើម្បីទិញដីយកចំណេញឲ្យក្រុមហ៊ុន។ ទោះបីការទិញដីនេះជាគំនិតល្អ អាចធ្វើឲ្យក្រុមហ៊ុនបានចំរើនមួយកម្រិតទៀតក៏ដោយ ទង្វើរបស់សហកម្មសិទ្ធិករនេះមិនមែនធ្វើនៅក្នុងវង្វង់អាជីវកម្មទេ ព្រោះសហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុនសំណង់ទូទៅប្រហែលជាមិនប្រថុយប្រថានរកស៊ីរបរមួយ ដែលមិនមែនជាជំនាញរបស់ខ្លួន។

កិច្ចការដែលធ្វើឡើងនៅក្នុងវង្វង់នៃអាជីវកម្មនេះហើយ ដែលជាកិច្ចការបានមកពីអំណាចពិតវាទរហិត ទោះបីកិច្ចសន្យាបង្កើតក្រុមហ៊ុនមិនបានចែងបញ្ជាក់ពីទំហំនៃអំណាចដែលសហកម្មសិទ្ធិករអាចធ្វើបានក៏ដោយ។ នៅក្នុងមាត្រា ៤១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម នេះសបញ្ជាក់ឲ្យឃើញថា សហកម្មសិទ្ធិករទូទៅ គឺមាន អំណាចពិតវាទរហិត នៅក្នុងករណីដែលសហកម្មសិទ្ធិករនោះ ចុះហត្ថលេខាដើម្បីទិញវត្ថុអ្វីមួយហើយវត្ថុនោះត្រូវបានយកមកប្រើប្រាស់ដោយក្រុមហ៊ុន។ ការណ៍ដែលក្រុមហ៊ុនទទួលយកវត្ថុដែលទិញនោះមកប្រើ ជាអាកប្បកិរិយាមួយទទួលស្គាល់នូវសកម្មភាពទិញដូររបស់សហកម្មសិទ្ធិករ[39]។

- **អំណាចដែលមានលក្ខណៈជារូបភាព**

អំណាចដែលមានលក្ខណៈជារូបភាព គឺជាអំណាចដែលមើលចេញពីខ្សែភ្នែករបស់ភាគីទីបី គឺមិនមែនជាអំណាចដែលកំណត់រវាងសហកម្មសិទ្ធិករ និង សហកម្មសិទ្ធិករ ឬ សន្និដ្ឋានចេញពីអាកប្បកិរិយារបស់សហកម្មសិទ្ធិករ ឬទំនៀមទម្លាប់អាជីវកម្មទេ។ មានស្ថានការណ៍បីដែលបង្កើតអំណាចដែលមានលក្ខណៈជារូបភាពគឺ អ្នកតំណាងបាន

[38] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៤១។

[39] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ១៥២ ។

ធ្វើកិច្ចការជាមួយតតិយជនដោយហួសពីទំហំនៃសិទ្ធិតំណាង, សិទ្ធិតំណាងបានរលត់ និង ម្ចាស់សិទ្ធិមិនបានប្រគល់សិទ្ធិតំណាង។

លក្ខខណ្ឌទីមួយ គឺនៅពេលដែលអ្នកតំណាងបានធ្វើកិច្ចការជាមួយតតិយជនដោយហួសពីទំហំនៃសិទ្ធិតំណាង ដែលកំណត់ដោយម្ចាស់សិទ្ធិ តែតតិយជននោះមិនបានដឹងពីទំហំនៃសិទ្ធិនោះមានត្រឹមណាទេ គឺ គេគ្រាន់តែដឹងថា មនុស្សពីរនាក់មានទំនាក់ទំនងភាពជាតំណាង គឺ កិច្ចការដែលធ្វើនៅក្នុងដែននៃទំនាក់ទំនងនេះ។ វិធាននៃការទទួលខុសត្រូវចំពោះភាគីទីបី ទាក់ទងនឹងអ្នកតំណាងអនុវត្តកិច្ចការហួសពីទំហំនៃសិទ្ធិតំណាងត្រូវបានចែងក្នុងមាត្រា ៣៧២ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីថា ១. ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យា ដោយហួសពីទំហំនៃសិទ្ធិតំណាង ប្រសិនបើភាគីម្ខាងទៀត (តតិយជន) ជឿជាក់ថា អ្នកតំណាងមានសិទ្ធិតំណាងចំពោះកិច្ចសន្យានោះ ហើយគ្មានកំហុសក្នុងការជឿនោះទេ ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងអនុវត្តកិច្ចសន្យានោះចំពោះភាគីម្ខាងទៀត (តតិយជន)[40]។

លក្ខខណ្ឌទីពីរ គឺ ពេលដែលទំនាក់ទំនងភាពជាអ្នកតំណាងនិងម្ចាស់សិទ្ធិបានចប់ទៅហើយ តែអ្នកតំណាងនោះបានបន្តកិច្ចការរបស់ខ្លួនដែលធ្លាប់ធ្វើកាលពីខ្លួននៅជាអ្នកតំណាងរបស់ម្ចាស់សិទ្ធិ។ អ្នកតំណាងក្តី ម្ចាស់សិទ្ធិក្តី មិនបានប្រកាសឲ្យដឹងពីការបញ្ចប់ទំនាក់ទំនងភាពជាតំណាងនេះឲ្យពិភពខាងក្រៅដឹងទេ។ តតិយជនម្នាក់ធ្វើការជាមួយអ្នកតំណាងនោះ ដោយជឿជាក់ថាអ្នកតំណាងនោះនៅមានទំនាក់ទំនងភាពជាតំណាងជាមួយម្ចាស់សិទ្ធិ។ វិធាននៃការទទួលខុសត្រូវចំពោះភាគីទីបីទាក់ទងនឹងការរលត់សិទ្ធិតំណាងត្រូវបានចែងក្នុងមាត្រា ៣៧២.២ នៃក្រមរដ្ឋប្បវេណីថា ២. ក្រោយពីពេលដែលសិទ្ធិតំណាងបានរលត់ ប្រសិនភាគីម្ខាងទៀត (តតិយជន) បានធ្វើកិច្ចសន្យាជាមួយនឹងម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យា នោះចំពោះភាគីម្ខាងទៀត (តតិយជន) ដឹងអំពីការរលត់នោះដោយមានកំហុស[41]។

លក្ខខណ្ឌទីបី គឺស្ថានការណ៍មួយទៀត មនុស្សម្នាក់មិនបានប្រគល់អំណាចឲ្យទៅអ្នកណាម្នាក់ដើម្បីធ្វើជាតំណាងឲ្យខ្លួនទេ ប៉ុន្តែ មនុស្សនោះតាមពាក្យសម្តី ឬ អាកប្បកិរិយា បណ្តោយឲ្យមនុស្សម្នាក់ទៀតនោះ យកឈ្មោះខ្លួនប្រើប្រាស់ដើម្បីធ្វើកិច្ចការណាមួយជាមួយតតិយជន ដោយសារពាក្យសម្តី ឬ អាកប្បកិរិយាដូច្នេះ បានជាព្រមធ្វើកិច្ចការជាមួយអ្នកដែលខ្លួនសន្មតថាអ្នកតំណាងនោះ។ វិធាននៃការទទួលខុសត្រូវចំពោះភាគីទីបីទាក់ទងនឹងការដែលមនុស្សម្នាក់គ្មានសិទ្ធិតំណាងសោះ តែខ្លួនដូចជាអ្នកមានសិទ្ធិតំណាងឲ្យម្ចាស់សិទ្ធិណាម្នាក់ ត្រូវបានចែងក្នុង មាត្រា ៣៧២ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីថា ៣. ក្នុងករណីដែលម្ចាស់សិទ្ធិមិនបានប្រគល់សិទ្ធិតំណាងទៅអ្នកផ្សេង ប៉ុន្តែ ម្ចាស់សិទ្ធិបានបង្ហាញដូចជាខ្លួនបានប្រគល់សិទ្ធិតំណាងនោះទៅឲ្យអ្នកផ្សេង ឬ អនុញ្ញាតឲ្យអ្នកផ្សេងនោះបង្ហាញថា អ្នក

[40] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៧២.១។

[41] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៧២.២។

នោះមានសិទ្ធិតំណាង ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យាចំពោះភាគីម្ខាងទៀត (តតិយជន) ដឹងពីនត្ថិភាពនៃសិទ្ធិតំណាងនោះ ឬ មិនដឹងអំពីនត្ថិភាពនោះដោយមានកំហុស[42]។

- **អំណាចដែលមានលក្ខណៈជារូបភាពនៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម**

គោលគំនិតនៃអំណាចដែលមានលក្ខណៈជារូបភាព ក្នុងកថាខណ្ឌ ៣ នៃក្រមរដ្ឋប្បវេណី ក៏បានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ៤៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មដែរ។ ជាវិធានទូទៅ បុគ្គលដែលក្លែងខ្លួនជាសហកម្មសិទ្ធិករនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមួយត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះតតិយជន ដែលធ្វើកិច្ចការដោយស្មោះត្រង់ជាមួយបុគ្គល់នោះ។ ភាពស្មោះត្រង់នោះមានន័យថា តតិយជនបានធ្វើកិច្ចការដោយមានជំនឿយ៉ាងសមរម្យថា បុគ្គលដែលខ្លួនធ្វើការជាមួយជាអ្នកតំណាងនោះទេ។

មាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចែងថា បុគ្គលណាម្នាក់ដែលធ្វើឲ្យបុគ្គលផ្សេងទៀតជឿទុកចិត្ត ដោយផ្ទាល់ ឬ ដោយប្រយោលថាខ្លួនជាសហកម្មសិទ្ធិករទូទៅ ប៉ុន្តែការពិតបុគ្គលនោះមិនមែនជាសហកម្មសិទ្ធិទូទៅទេ ត្រូវទទួលខុសត្រូវចំពោះតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយ ដោយស្មោះត្រង់ដូចសហកម្មសិទ្ធិករទូទៅពិតៗដែរ[43]។ ប៉ុន្តែវិធាននៃការទទួលខុសត្រូវចំពោះភាគីទីបី នេះនឹងមានការផ្លាស់ប្តូ នៅក្នុងលក្ខណ្ឌដែលមានចែង ក្នុង មាត្រា ៤៥ កថាខណ្ឌ ២ ដោយ កាលណាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានដឹងពីការក្លែងយកឈ្មោះរបស់ខ្លួនទៅប្រើ ប៉ុន្តែពុំបានបញ្ឈប់សកម្មភាពក្លែង ឬ ជាពិសេសពុំបានជូនដំណឹងដល់តតិយជនឲ្យបានជ្រាបពីឋានៈពិតប្រាកដរបស់បុគ្គលដែលតតិយជនបាន ឬ កំពុងធ្វើកិច្ចការជាមួយ។ ក្នុងករណីខកខានបែបនេះ ការទទួលខុសត្រូវចំពោះតតិយជននឹងត្រូវធ្លាក់ទៅលើក្រុមហ៊ុនសហកម្មសិទ្ធិវិញ។ ធាតុផ្សំនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅគឺ៖ មានការយកឈ្មោះក្រុមហ៊ុនទៅប្រើ, អ្នកដែលប្រើឈ្មោះនោះគ្មានសិទ្ធិតំណាង, អ្នកដែលប្រើឈ្មោះនោះគ្មានសិទ្ធិតំណាង, ក្រុមហ៊ុនបានដឹងពីការប្រើឈ្មោះនោះ និង មិនបានចាត់ការការពាតតិយជនពីការប្រើឈ្មោះក្លែងនោះ។

- **លក្ខខណ្ឌដែលតតិយជនអាចតតាំង និងអំណាចដែលមានលក្ខណៈជារូបភាព**

ដើម្បីទាមទាឲ្យភាគីម្នាក់ទទួលខុសត្រូវចំពោះអំណាចដែលមានលក្ខណៈជារូបភាព តតិយជនត្រូវតែមានស្មោះត្រង់ និងសុទ្ធចិត្ត នៅក្នុងការទាក់ទងធ្វើពាណិជ្ជកិច្ច ជាមួយបុគ្គលដែលបង្ហាញអំណាចដែលមានលក្ខណៈជារូបភាព។ នេះមានន័យថា នៅក្នុងការធ្វើពាណិជ្ជកម្មនេះ នៅពេលមានអង្គហេតុអ្វីមួយដែលកើតមានឡើង និងតម្រូវឲ្យមានការចូលរួមពីតតិយជន នោះការលើកលែងអំពីរឿងអ្វីមួយនោះត្រូវតែធ្វើឲ្យតតិយជនមានជំនឿទុកចិត្តលើ ដោយមានហេតុផលសមរម្យ ថាបុគ្គលដែលខ្លួនធ្វើពាណិជ្ជកិច្ចជាមួយនោះ ជាសហកម្មសិទ្ធិករនៃក្រុមហ៊ុនសហកម្មសិទ្ធិ

[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៧២.៣។

[43] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, កថាខណ្ឌ១ មាត្រា ៤៥។

ទូទៅមួយដែលខ្លួនទាមទារឲ្យទទួលខុសត្រូវ (មាត្រា ៤៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងមាត្រា ៣៧២.១ ក្រមរដ្ឋប្បវេណី)។

នៅក្នុងករណីដែលបុគ្គលម្នាក់បានឈប់ពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួចហើយ តែបានបង្ហាញនូវអំណាចដែលមានលក្ខណៈជារូបភាព តតិយជនត្រូវបានបង្ហាញដោយហេតុផលសមរម្យ ថាខ្លួនមិនបានដឹងពីការឈប់ ឬលាលែង របស់បុគ្គលនោះពីក្រុមហ៊ុនឡើយ។ ប៉ុន្តែបើការមិនដឹងនោះជាកំហុសរបស់ខ្លួន នោះតតិយជនមិនអាចទាមទារឲ្យក្រុមហ៊ុនសហកម្មសិទ្ធិទទួលខុសត្រូវបានឡើយ។ ឧទាហរណ៍ បើច្បាប់តម្រូវឲ្យក្រុមហ៊ុនចុះផ្សាយពីការផ្លាស់ប្តូរសមាសភាពនៃក្រុមហ៊ុននៅក្នុងការសែត ដែលអ្នកជំនួញមានកាតព្វកិច្ចត្រូវតាមដានការផ្សាយទាំងនោះ តែខកខនមិនបានតាមដានទៅវិញ នេះគឺជាកំហុសរបស់តតិយជនហើយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនទទួលខុសត្រូវចំពោះអំពើនៃអតីតសហកម្មសិទ្ធិករ ដែលបង្ហាញអំណាចដែលមានលក្ខណៈជារូបភាពឡើយ (មាត្រា ៣៧២.២ ក្រមរដ្ឋប្បវេណី)[44]។

- **អំណាចគ្រប់គ្រងក្រុមហ៊ុន**

សហកម្មសិទ្ធិករម្នាក់ៗ មានអំណាចគ្រប់គ្រង ឬត្រួតត្រាក្រុមហ៊ុនដូចគ្នា តែសហកម្មសិទ្ធិករទាំងអស់អាចប្រតិភូអំណាចរបស់ខ្លួនឲ្យទៅសហកម្មសិទ្ធិករណាម្នាក់ ឬ អ្នកក្រៅណាម្នាក់បំពេញករណីយកិច្ចជា សហកម្មសិទ្ធិករគ្រប់គ្រង ឬ ជាអ្នកគ្រប់គ្រង។ អំណាចរបស់សហកម្មសិទ្ធិករគ្រប់គ្រងអាចត្រូវបានកំណត់ដោយសហកម្មសិទ្ធិករគ្នាឯងដោយជាក់លាក់ ដោយកម្រិតទំហំនៃអំណាចដែលសហកម្មសិទ្ធិករគ្រប់គ្រងអាចប្រើប្រាស់បាន។ ប៉ុន្តែនៅចំពោះមុខ តតិយជន ងំណាចនៃហកម្មសិទ្ធិករគ្របគ្រងគឺ ជាអំណាចទូទៅ ដែលសហកម្មសិទ្ធិករម្នាក់ៗមាន។ តតិយជនមិនចាំបាច់ដឹងថា សហកម្មសិទ្ធិករគ្រប់គ្រងបានទទួលអំណាចត្រឹមណា ប៉ុនណានៅក្នុងការធ្វើកិច្ចការ ឬ ពាណិជ្ជកិច្ចជាមួយខ្លួនដើម្បីឲ្យសេចក្តីសម្រេចរបស់សហកម្មសិទ្ធិករគ្រប់គ្រងនោះ ចងកាតព្វកិច្ចលើសហកម្មសិទ្ធិករដទៃទៀតនោះទេ[45]។

- **អំណាចចុះហត្ថលេខាលើកិច្ចសន្យា**

អំណាចចុះកិច្ចសន្យារវាងក្រុមហ៊ុននិងតតិយជន អាចត្រូវបានកំរិតដោយកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ប៉ុន្តែ ការចុះហត្ថលេខាលើកិច្ចសន្យាដោយសហកម្មសិទ្ធិករណាម្នាក់ដែលធ្វើឡើងនៅក្នុងទំហំនៃអំណាចរបស់សហកម្មសិទ្ធិករនោះ ក៏ចងការតព្វកិច្ចលើសហកម្មសិទ្ធិករដទៃទៀតផងដែរ (មាត្រា ៤១ ច្បាប់ស.គ.ព)។ តតិយជនដែលធ្វើកិច្ចការដោយសុទ្ធចិត្ត ជាមួយសហកម្មសិទ្ធិករដែលចុះហត្ថលេខា អាចលើកឡើងពីគោលការណ៍នៃអំណាចដែលមានលក្ខណៈជារូបភាពនៃសហកម្មសិទ្ធិករចុះហត្ថលេខា ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។ តតិយជនមិនជាប់ជំពាក់នឹងការព្រមព្រៀងគ្នាជាសម្ងាត់រវាងសហកម្មសិទ្ធិករគ្នាឯង ដើម្បីកំរិតអំណាចលើសសហកម្មសិទ្ធិករមួយ ឬ ច្រើននាក់នោះទេ។ បន្ទុកភស្តុតាងនៃការដឹងពីការកំរិតអំណាចនេះស្ថិត នៅលើភាគីដែលកំរិតអំណាច មានន័យ

[44] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ១៦០។

[45] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ១៦២។

ថាសហកម្មសិទ្ធិករដទៃទៀតក្រៅពីសហកម្មសិទ្ធិករដែលចុះហត្ថលេខា។ សហកម្មសិទ្ធិករដែលចុះហត្ថលេខា ត្រូវទទួលខុសត្រូវចំពោះសហកម្មសិទ្ធិករដទៃទៀត។ ប៉ុន្តែបើនៅមុនការចុះហត្ថលេខាកិច្ចសន្យា បើសហកម្មសិទ្ធិករចុះហត្ថលេខា បានជូនដំណឹងផ្ទាល់មាត់ក្តី ជាលាយលក្ខណ៍អក្សរក្តីទៅតតិយជនអំពីការមិនអនុញ្ញាតឲ្យមានការចុះហត្ថលេខាលើសាច់រឿងណាមួយ (ឧទាហរណ៍ ទិញឧបករណ៍ បោះពុម្ព) នោះការចុះហត្ថលេខា មិនបានចងកាតព្វកិច្ចលើសហកម្មសិទ្ធិករផ្សេងទៀតនោះទេ។ ប៉ុន្តែបើសហកម្មសិទ្ធិករនោះចុះហត្ថលេខាខ្ចីអ្វីមួយដោយប្រើឈ្មោះខ្លួនឯងផ្ទាល់ ហើយរបស់នោះត្រូវបានយកមកប្រើជាផលប្រយោជន៍របស់ក្រុមហ៊ុននោះក្រុមហ៊ុនត្រូវទទួលខុសត្រូវចំពោះការជំពាក់បំណុលរបស់សហកម្មសិទ្ធិករដែលចុះហត្ថលេខានោះ[46]។

- **អំណាចក្នុងការបណ្តេញសហកម្មសិទ្ធិករទូទៅចេញពីក្រុមហ៊ុន**

ជាទូទៅ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមួយត្រូវចប់ជីវិតរបស់ខ្លួនកាលណាភាគីនៃកិច្ចសន្យាបង្កើតក្រុមហ៊ុនដកខ្លួន ឬ ត្រូវបញ្ឈប់ ពីព្រោះកិច្ចសន្យានោះត្រូវបានរំលាយ។ ផ្ទុយទៅវិញច្បាប់ស្តីសហគ្រាសពាណិជ្ជកម្ម បានទុកសិទ្ធិឲ្យអាជីវកម្មអាចបន្តទៅទៀតបាន បើទោះបីជាសមាសភាពនៃក្រុមហ៊ុនមានការប្រែប្រួលដោយសារការឈប់ ឬការបញ្ឈប់សមាជិកណាមួយក៏ដោយក្តី ដោយច្បាប់នេះបានចែងយ៉ាងច្បាស់ថា សហកម្មសិទ្ធិករទាំងឡាយអាចបណ្តេញសហកម្មសិទ្ធិករមួយទៀតនោះ ឬ ដទៃទៀតចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដោយសារសហកម្មសិទ្ធិករមួយទៀតនោះ ឬ ដទៃទៀតនោះបានរំលោភលើការតព្វកិច្ចរបស់ខ្លួនដែលមានចំពោះក្រុមហ៊ុន។

ការសម្រេចរបស់សហកម្មសិទ្ធិករភាគច្រើនដោយប្រៀបអាចកំណត់ធ្វើជាសេចក្តីសម្រេចបញ្ចេញ សហកម្មសិទ្ធិករមួយទៀតចេញបាន។ កាតព្វកិច្ចទូទៅដែលសហកម្មសិទ្ធិករត្រូវមានចំពោះក្រុមហ៊ុន គឺ ភក្តីភាពនិង និងទំនុកចិត្ត ដែលរួមមាន ការមិនប្រកួតប្រជែងដោយគ្មានការអនុញ្ញាត, ការមិនដណ្តើមយកអាជីវកម្មរបស់ក្រុមហ៊ុន, ការមិនបង្កើតទំនាស់ផលប្រយោជន៍។ កាតព្វកិច្ចជាក់លាក់ដទៃទៀតមាន កាតួកិច្ចរួមបង់ខាត, កាតព្វកិច្ចផ្តល់ពត៌មាន, កាតព្វកិច្ចគោរពតាមសេចក្តីសម្រេចដោយ សម្លេងគ្រប់គ្រាន់តាមច្បាប់ ឬ តាមកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិ។ ឧទហរណ៍ បើក្រុមហ៊ុនសហកម្មសិទ្ធិមួយមានសមាជិកបីនាក់ សហកម្មសិទ្ធិករពីរនាក់ទៀតអាចបណ្តាញសហកម្មសិទ្ធិករម្នាក់បាន។ តាមមាត្រា ៥២ ច្បាប់សហគ្រាសពាណិជ្ជកម្មបានចែងថា សហកម្មសិទ្ធិករទូទៅទាំងឡាំយអាចបណ្តេញចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនូវសហកម្មសិទ្ធិករទូទៅ ដែលខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ឬ ដែលធ្វើឲ្យរាំងស្ទះដល់ដំណើរការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ តាមរយៈការបោះឆ្នោតដោយសម្លេងភាគច្រើនដោយធៀប។ ក្នុងករណីដែលមានការជំទាស់ សហកម្មសិទ្ធិទូទៅទាំងឡាយអាចស្នើសុំការអនុញ្ញាតពីតុលាការដើម្បីដកសហកម្មសិទ្ធិករទូទៅនោះចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ តុលាការអាចអនុញ្ញាតនូវការស្នើសុំនោះ

[46] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ១៦៣។

បានលុះត្រាតែតុលាការពិចារណា ឃើញថាការសុំដកចេញនោះសមស្រប ហើយចេញដីកាផ្អែកទៅតាមកំហុស របស់សហកម្មសិទ្ធិករទូទៅ[47]។

ដូចបានឃើញនៅក្នុងមាត្រាខាងលើ មូលហេតុសម្រាប់ការបណ្តេញចេញមិនមែនមានត្រឹមតែការរំលោភលើកាតព្វកិច្ចក្នុងឋានៈជាសហកម្មសិទ្ធិករនោះទេ។ មូលហេតុនេះមានលក្ខណៈទូលំទូលាយគួរសម ដែលអាចគ្របដណ្តប់លើបញ្ហានានាដូចជា ការរាំងស្ទះដល់កិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុន ដូចជាការរំខានដល់កិច្ចចាត់ការសកម្មភាពរបស់ក្រុមហ៊ុន និង ការរាំងស្ទះនឹងយុទ្ធសាស្ត្រអាជីវកម្មរបស់ក្រុមហ៊ុន ដូចជានៅក្នុងករណីដែលរារាំងដល់ការពង្រីកអាជីវកម្មជាដើម។ ការបណ្តេញសហកម្មសិទ្ធិករមួយចេញពីក្រុមហ៊ុន គឺជាបញ្ហាធ្ងន់ធ្ងរ។ សហកម្មសិទ្ធិភាគច្រើនអាចប្រើប្រាស់សម្លេងភាគច្រើនរបស់ខ្លួនដើម្បីបណ្តេញចេញ សហកម្មសិទ្ធិករនោះ ដោយសំអាងថា សហកម្មសិទ្ធិករនោះរារាំងមិនឲ្យអាជីវកម្មរីកមានការរីកចម្រើន អាស្រ័យហេតុនេះហើយបានជា មាត្រា ៥២ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម បានចែថា សហកម្មសិទ្ធិករដែលត្រូវបានគេសម្រេចបណ្តាញចេញមានឱកាសតវ៉ានឹងសេចក្តីសម្រេចបែបនេះ ដោយប្តឹងទៅតុលាការ។ តុលាការសម្រេចឲ្យបណ្តេញ ឬ មិនបណ្តេញដោយចេញដីការសម្រេច[48]។ តាមមាត្រា ៧១១ នៃក្រមរដ្ឋប្បវេណីបានចែងថា សហកម្មសិទ្ធិករម្នាក់អាចត្រូវបញ្ឈប់ពីក្រុមហ៊ុនសហកម្មសិទ្ធិបាន លុះត្រាតែមានសម្លេងជាឯកច្ឆន្ទពីសហកម្មសិទ្ធិករដទៃទៀតក្រៅពី សហកម្មសិទ្ធិករដែលត្រូវបញ្ឈប់។ ឧទាហរណ៍ ក្រុមហ៊ុនសហកម្មសិទ្ធិមួយមានសមាជិក ៥ នាក់ បើចង់បណ្តេញសហកម្មសិទ្ធិករណាម្នាក់ គេត្រូវមានសម្លេង ៤នាក់គាំទ្រក្នុងការបណ្តេញចេញ។ ការបណ្តេញចេញនេះទៀតសោត ត្រូវមានមូលហេតុត្រឹមត្រូវ ហើយនៅក្នុងចំណុចនេះផងដែរ មាត្រា ៧១១ ក៏បានចែងយ៉ាងច្បាស់ថា៖ ការលុបឈ្មោះសមាជិកក្រុមហ៊ុន អាចអនុវត្ត បានដោយមតិយលព្រមជាឯកច្ឆន្ទពីសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន តែក្នុងករណីមានមូលហេតុត្រឹមត្រូវប៉ុណ្ណោះ។ ប៉ុន្តែ បើមិនបានជូនដំណឹងពីការលុបឈ្មោះ ដលសមាជិកដែលត្រូវបានលុបឈ្មោះទេ ពុំអាចយកទៅតតាំងជាមួយនឹងសមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះនោះបានឡើយ[49]។

## ផ្នែកទី៣៖ ការផ្លាស់ប្តូរសមាសភាពក្រុមហ៊ុន

ការផ្លាស់ប្តូរសមាសភាពក្រុមហ៊ុនកើតឡើងនៅពេលដែលសហកម្មសិទ្ធិករម្នាក់លាលែងពីក្រុមហ៊ុន, ស្លាប់ ឬ នៅពេលដែលមានបុគ្គលណាម្នាក់ចូលមកជាសហកម្មសិទ្ធិករថ្មី។

### ១.១. ការផ្លាស់ប្តូរសមាសភាពដោយបាត់បង់សហកម្មសិទ្ធិករ

#### ១.១.១ ការផ្លាស់ប្តូរសមាសភាព

##### ក. ករណីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនចុះបញ្ជីជានីតិបុគ្គល

---

[47] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, កថាខណ្ឌ២ មាត្រា ៥២។

[48] ច្បាប់ ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ១៦៦។

[49] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧១១។

ជាគោលការណ៍ទូទៅ នៅក្នុងករណីនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅណាដែលមិនចុះបញ្ជីជានីតិបុគ្គល កាលណាសហកម្មសិទ្ធិករម្នាក់លាលែង ឬ ស្លាប់ នោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវចប់ដែរ ព្រោះទំនាក់ទំនងកិច្ចសន្យានៃការបង្កើតក្រុមហ៊ុនត្រូវបញ្ចប់ ដោយសារភាគីណាមួយនៃកិច្ចសន្យាឈប់ជាភាគីនៃកិច្ចសន្យានោះ។ ការបន្តអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិអាចធ្វើបាន នៅក្នុងទម្រង់នៃកិច្ចសន្យាថ្មីរវាងសហកម្មសិទ្ធិករដែលនៅសល់ដើម្បីបន្តអាជីវកម្មដដែល។ តែសហកម្មសិទ្ធិទូទៅមិនចាំបាច់ធ្វើរៈកិច្ចសន្យាក៏បាន បើពួកគេបានចែងនៅក្នុងកិច្ចសន្យាដើម្បីបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដំបូង ថាគេនឹងនៅបន្តក្រុមហ៊ុនតទៅទៀត ក្នុងករណីដែលមានសហកម្មសិទ្ធិសំទ្ធិករណាម្នាក់លាលែង ឬស្លាប់ ដោយគ្រាន់តែចែងពីនីតិវិធីនៃការផ្ទេរផលប្រយោជន៍របស់សហកម្មសិទ្ធិករដែលលាលែង ឬស្លាប់។ បុគ្គលណាមួយអស់សិទ្ធិករទូទៅ បង្កឲ្យមានការរំលាយដោយស្វ័យប្រវត្តិនូវក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ លើកលែងតែកិច្ចសន្យាចែងផ្សេងនេះ ។ មួយវិញទៀតបុគ្គលដែលអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅមានជាអាទិ៍ សហកម្មសិទ្ធិករដែលដកខ្លួនពីក្រុមហ៊ុន, សហកម្មសិទ្ធិករដែលទទួលមរណភាព, សហកម្មសិទ្ធិករដែលត្រូវបានបណ្តេញចេញពីក្រុមហ៊ុន[50]។

## ខ. ករណីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចុះបញ្ជីជានីតិបុគ្គល

ជាការចម្លែកដែលច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានចែងជាទូទៅ ការផ្លាស់ប្តូរសមាសភាពក្រុមហ៊ុនសហកម្មសិទ្ធិនាំឲ្យក្រុមហ៊ុនរលាយជាស្វ័យប្រវត្តិ ដោយគ្មានការបែងចែករវាងប្រភេទនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ចុះបញ្ជី និងមិនចុះបញ្ជី។ គោលដៅមួយក្នុងចំណោមគោលដៅនានានៃទ្រឹស្តីបុគ្គលភាព គឺនិរន្តរភាពនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលណាមានការផ្លាស់ប្តូរសមាសភាព។ យោងតាមន័យនៃមាត្រា ៤៩ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មខ្មែរ និរន្តរភាពនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនអាស្រ័យលើឋានៈគតិយុត្ត (ជានីតិបុគ្គល) នៃក្រុមហ៊ុនទេ ថ្វីបើមាត្រា ១២ នៃច្បាប់ដដែលចែងថា "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមាននីតិបុគ្គលិកដាច់ដោយឡែកពីសហកម្មសិទ្ធិករម្នាក់ៗ"។ មានន័យថា ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបន្តជីវិតរបស់ខ្លួន បន្ទាប់ពីមានការផ្លាស់ប្តូរសមាសភាពក្រុមហ៊ុន លុះត្រាតែកិច្ចសន្យានបង្កើតក្រុមហ៊ុនចែងខមួយដែលថា ក្រុមហ៊ុននៅបន្តបុគ្គលភាពរបស់ខ្លួនទោះបីមានការផ្លាស់ប្តូរសមាសភាពក៏ដោយ។ ការសរសេរចែងបែបនេះអាចជៀសវាងពីអានុភាពគតិយុត្តដែលមានលើរឿងក្តីដូចខាងក្រោម[51]៖ នៅក្នុងសេចក្តីអធិប្បាយលើច្បាប់គំរូអាមេរិកាំង "សើរើ" ស្តីពីក្រុមហ៊ុនសហកម្មសិទ្ធិ (Revised Uniform Partnership Act 1997 "RUPA") អ្នកព្រាងច្បាប់សើរើ នោះមើលឃើញគុណវិបត្តិនៃទ្រឹស្តីចង្កោមមនុស្ស ដែលមានជាប់នៅក្នុងច្បាប់គំរូចាស់ដែលថា ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវចប់ជីវិតនៅពេលមានការផ្លាស់ប្តូរ។ សេចក្តីអធិប្បាយលើមាត្រា ២០១ បានបញ្ជាក់ថា ដោយសារក្រុមហ៊ុនសហកម្មសិទ្ធិជានីតិបុគ្គល ទោះបីមានការផ្លាស់ប្តូរសមាសភាពក្តី ក្រុមហ៊ុនសហកម្មសិទ្ធិនៅតែបន្តនិរន្តរភាពរបស់ខ្លួនដដែល គឺគ្មានក្រុមហ៊ុនសហកម្មសិទ្ធិចាស់ ឬក្រុមហ៊ុនសហកម្មសិទ្ធិថ្មី ដោយសារតែការផ្លាស់ប្តូរសមាសភាពក្រុមហ៊ុននោះទេ។ មានករណីមួយនៅសហរដ្ឋអាមេរិក

[50] មាត្រា ៤៨,ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

[51] ច្បាប់ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រទី១៧០។

កាលពីឆ្នាំ ១៩៨៥ ឈ្មោះ Fairway Development Co. V. Title Insurance Co. ដែលនៅក្នុងរឿងក្តីនេះ តុលាការបានសម្រេចថា ក្រុមហ៊ុនសហកម្មសិទ្ធិថ្មីមួយមិនអាចទាមទារសំណងប្រាក់ធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងបានទេ ព្រោះកិច្ចសន្យាបានរ៉ាប់រងនោះត្រូវបានធ្វើជាមួយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចាស់ កាលពីមិនទាប់មានការផ្លាស់ប្តូរសមាសភាពក្រុមហ៊ុន ដោយសារមរណភាពនៃសហកម្មសិទ្ធិករម្នាក់។ ក្រោយពីមរណភាពរបស់សហកម្មសិទ្ធិករនោះទៅតុលាការបានសម្រេចថាក្រុមហ៊ុនចាស់នោះបានរលាយរួចទៅហើយ។ ដូច្នេះ ការអនុម័តយកទ្រឹស្តីបុគ្គលភាពជាច្បាប់នាំឲ្យក្រុមហ៊ុនសហកម្មសិទ្ធិមានទម្រង់ជានីតិបុគ្គល ដូច្នេះ នីតិបុគ្គលបន្តជីវិតធម្មជាត់ ដោយមិនទាក់ទង នឹងការផ្លាស់ប្តូរសមសភាពក្រុមហ៊ុន។ បើករណីខាងលើត្រូវបានសម្រេចនាពេលបច្ចុប្បន្ន លទ្ធផល នឹងផ្ទុយពីការសម្រេចកាលពីឆ្នាំ ១៩៨៥[52]។

### ១.២ ការផ្លាស់ប្តូរសមាសភាពឲ្យមានសហកម្មសិទ្ធិទូទៅថ្មី

#### ១.២.១ ការផ្លាស់ប្តូរដែលនាំឲ្យកើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅថ្មី

នៅក្នុងករណីដែលកិច្ចសន្យាបង្កើតក្រុមហ៊ុនដំបូងមិនបានចែងពីនិរន្តរភាព នៃក្រុមហ៊ុនកាលណាមានការផ្លាស់ប្តូរសមាសភាពក្រុមហ៊ុនដោយការដកខ្លួន ឬមរណភាពនៃសហកម្មសិទ្ធិករ បើភាគីចង់បន្តអាជីវកម្មក្រោមរូបភាពក្រុមហ៊ុនសិទ្ធិទូទៅថ្មី គេត្រូវមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិដែលនៅសល់ ហើយត្រូវចាត់ការចុះបញ្ជីពីការកែប្រែសមាសភាពនៃកក្រុមហ៊ុននោះ។ ក្រុមហ៊ុនសហកម្មសិទ្ធិទៅអាចបន្តសកម្មភាពទៅបាន ដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ និងដោយការអនុវត្តលក្ខខណ្ឌតម្រូវនៃការតម្កល់ទុក និងការចុះបញ្ជីដើម្បីបង្ហាញអំពីការកែប្រែនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ ប្រសិនបើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរកិច្ចសន្យានោះត្រូវធ្វើការកែប្រែឲ្យសមស្របតាមនោះដែរ។

#### ១.២.២ ការចូលខ្លួនសហកម្មសិទ្ធិករថ្មី និងការដកខ្លួនចេញពីសហកម្មសិទ្ធិ

មូលដ្ឋាននៃការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺការទុកចិត្ត និងសេចក្តីស្មោះត្រង់ទៅវិញទៅមក រវាងសហកម្មសិទ្ធិករទាំងអស់ដើម្បីឲ្យការប្រកបអាជីវកម្មប្រព្រឹត្តទៅដោយជោគជ័យ ហេតុដូច្នេះហើយបានជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ជាទូទៅមានសហកម្មសិទ្ធិករជាសាច់ញាតិ ឬ ជាមិត្តភ័ក្រ្តនឹងគ្នា។ ការបញ្ចូលសមាជិកថ្មីទៅក្នុងក្រុមហ៊ុនទាមទារឲ្យមានការទុកចិត្តពីសហកម្មសិទ្ធិករទាំងអស់។ នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដើម្បីឲ្យសមាជិកថ្មីចូលរួមក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទៅបាន សមាជិកថ្មីនោះត្រូវទទួលបានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករបច្ចុប្បន្ន[53] ។ គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយអាចក្លាយជាសហកម្មសិទ្ធិករទូទៅដោយគ្មានការយល់ព្រមជាឯកច្ឆន្ទ ពីគ្រប់សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទៅបានឡើយ។

ក្រៅពីលក្ខខណ្ឌនៃការយល់ព្រមពីសហកម្មសិទ្ធិករទាំងអស់ សមាជិកថ្មីខ្លួនឯងក៏ត្រូវទទួលស្គាល់កាតព្វកិច្ចដែលមានមកស្រាប់នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែល។ មានន័យថាបុគ្គលថ្មីដែលចូលជាសហកម្មសិទ្ធិករត្រូវ

---

[52] ច្បាប់ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រ ១៦៧ និង១៧០។

[53] មាត្រា ៣១,ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

ទទួលស្គាល់បំណុលទាំងអស់របស់ក្រុមហ៊ុន ដែលមានពីដើមមករហូតដល់ថ្ងៃចូលជាសហកម្មសិទ្ធិករថ្មីនៃបុគ្គលនោះ។ ប៉ុន្តែចំពោះបំណុលចាស់នេះ សហកម្មសិទ្ធិករថ្មីទទួលខុសត្រូវច្រើនបំផុត ត្រឹមតែភាគទុនរបស់គាត់ដែលបានដាក់នៅក្នុងក្រុមហ៊ុន។ មាត្រា ៤៣ ចែងថា បុគ្គលណាដែលចូលជាសហកម្មសិទ្ធិករទូទៅនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលកើតរួចហើយត្រូវទទួលខុសត្រូវចំពោះបំណុលទាំងអស់ ដែលកើតឡើងដោយសារក្រុមហ៊ុន មុនពេលដែលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅ ដូចដែលខ្លួនជាសហកម្មសិទ្ធិករទូទៅនៅពេលបំណុលនោះកើតឡើងដែរ។

ចំណែកឯការដកខ្លួននៃសហកម្មសិទ្ធិករជាបញ្ហាមួយទៀតដែលកិច្ចសន្យាក្រុមហ៊ុនត្រូវព្រាងទុនជាមុខ។សហកម្មសិទ្ធិករម្នាក់អាចដកខ្លួនពីក្រុមហ៊ុនដោយសារមូលហេតុណាមួយ៉ាងៈ សុខភាពចង់ផ្លាស់ប្តូរកិច្ចការ, ធុញទ្រាន់ នឹងសហកម្មសិទ្ធិករគ្នាឯង, មើលមិនឃើញអនាគតនៃអាជីវកម្ម។ ល ។[54]

ការដកខ្លួននៅក្រោមលក្ខខណ្ឌពីរដំបូងអាចធ្វើទៅបាន ដោយសហកម្មសិទ្ធិករគ្រាន់តែជូនដំណឹងជាមុនពីការដកខ្លួន ហើយការដកខ្លួននោះធ្វើដោយសុទ្ធចិត្ត មានន័យថា មិនធ្វើក្នុងគោលបំណងបង្កព្យសនកម្មដល់ក្រុមហ៊ុនឡើយ។ តែច្បាប់មិនបានបញ្ជាក់ថា ការដកខ្លួនដោយអសុទ្ធចិត្តត្រូវទទួលការរារាំងដោយសហកម្មសិទ្ធិករដទៃទៀត ឬយ៉ាងណាទេ។ ការដកខ្លួននៅក្រោមលក្ខខណ្ឌទីបីអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីសហកម្មសិទ្ធិករភាគច្រើនដាច់ខាត ឬតាមការយល់ព្រមពីចំនួនសហកម្មសិទ្ធិករដែលកិច្ចសន្យាកំណត់។ ចំពោះការដកខ្លួនដោយគ្មានការផ្ទេរផលប្រយោជន៍ ការចាត់ចែងផលប្រយោជន៍របស់សហកម្មសិទ្ធិករដែលដកខ្លួនគួរអនុវត្តដូចករណីសហកម្មសិទ្ធិករស្លាប់ដែលបានពិពណ៌នានៅផ្នែកខាងក្រោយដែរ (ផ្នែក "មរណភាពនៃសហកម្មសិទ្ធិករ")។

ឧទាហរណ៍ សហកម្មសិទ្ធិករអាចចែងនៅក្នុងកិច្ចសន្យាក្រុមហ៊ុនស្តីពីការឲ្យជនណាម្នាក់ជាសាច់ញាត់ ឬជាតំណាងចូលមកជំនួសជាសហកម្មសិទ្ធិករបន្ត ដើម្បីឲ្យក្រុមហ៊ុនមាននិរន្តរភាព។ នៅក្នុងរឿងនេះ តើមានអ្វីប្លែកនៅក្នុងក្រមរដ្ឋប្បវេណី? សេចក្តីអធិប្បាយ មាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណីចែងថា ការដកខ្លួនដោយស្ម័គ្រចិត្តអាចធ្វើបានលុះត្រាតែមានការចាំបាច់ដែល "ពុំអាចជៀសវាងបាន"។ បើការដកខ្លួននោះធ្វើឲ្យខូចប្រយោជន៍របស់ក្រុមហ៊ុន សហកម្មសិទ្ធិករពុំអាចដកខ្លួនបានឡើយ លើកលែងតែ "ពុំអាចជៀសវាងបាន"[55]។ លក្ខខណ្ឌនេះអនុវត្តចំពោះទាំងកិច្ចសន្យាក្រុមហ៊ុនមានកំណត់និងទាំងកិច្ចសន្យាក្រុមហ៊ុនគ្មានពេលកំណត់។

## ជំពូកទី៣

## ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

### ផ្នែកទី១៖ មូលហេតុ និងនីតិវិធីនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

[54] ច្បាប់ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦។

[55] សូមមើលសេចកក្តីអធិប្បាយមាត្រា ៧០៩, ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៣៖ គន្ថី ៥, ទំព័រ ១៤៦។

**១.១ ការកំណត់មូលហេតុដែលបណ្ដាលឲ្យមានការរំលាយ**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវរំលាយដោយមូលហេតុដូចជា

**១.១.១ មូលហេតុនៃការរំលាយ**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវរំលាយដោយឆន្ទៈនៃសហកម្មសិទ្ធិករ, ភាពក្ស័យធននៃសហកម្មសិទ្ធិករណាមួយ និងសាលក្រមតុលាការបង្គាប់ឲ្យរំលាយ។ ចំពោះមូលហេតុដែលមានចែងក្នុងកិច្ចសន្យា (ដូចជាគោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់ គ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត និងតាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ) និងដោយតុលាការស្របទៅតាមមូលហេតុច្បាប់។ សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅដែលធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនត្រូវចប់ នៅពេលដែលក្រុមហ៊ុននោះត្រូវបានរំលាយ លើកលែងតែចំពោះសកម្មភាពទាំងឡាយណាដែលជាផលវិបាកដ៏ចាំបាច់នៃពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន និងធ្វើពុំទាន់ចប់សព្វគ្រប់។ ប៉ុន្តែរាល់កិច្ចការដែលបានធ្វើជាប្រក្រតីក្នុងក្រុមហ៊ុនដោយសហកម្មសិទ្ធិករទូទៅ ដែលមិនបានដឹងអំពីការរំលាយក្រុមហ៊ុននោះ ហើយនៅតែធ្វើសកម្មភាពដោយស្មោះត្រង់ សហកម្មសិទ្ធិករនោះត្រូវជាប់កាតព្វកិច្ចជាមួយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិករទូទៅដទៃទៀត ដូចដែលក្រុមហ៊ុននោះនៅជាធរមាននៅឡើយ[56]។ ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនអាចប៉ះពាល់សិទ្ធិតតិយជនដែលធ្វើពាណិជ្ជកម្មជាមួយដោយស្មោះត្រង់ និងមិនអាចប៉ះពាល់ទៅនឹងបុគ្គលណាមួយដែលបានចុះកិច្ចសន្យាជាមួយសហកម្មសិទ្ធិករទូទៅ ឬមិនអាចប៉ះពាល់ទៅនឹងភ្នាក់ងារណាម្នាក់ដែលធ្វើកិច្ចការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ[57]។

**ក. ការរំលាយដោយពេញច្បាប់**

ព្រឹត្តិការណ៍មួយចំនួនដែលនាំឲ្យក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានរំលាយដោយស្វ័យប្រវត្តិតែម្តង ប្រសិនបើក្នុងកិច្ចសន្យារបស់ក្រុមហ៊ុននោះមិនបានចែងពីការការពារបម្រុងទុកនូវព្រឹត្តការណ៍ទាំងអស់នោះទេ។ ព្រឹត្តិការណ៍ទាំងនោះរួមមានៈ

- ផលប្រយោជន៍របស់សហកម្មសិទ្ធិករម្នាក់ត្រូវបានផ្ទេរ
- មរណភាពនៃសហកម្មសិទ្ធិករណាម្នាក់
- សហកម្មសិទ្ធិករណាម្នាក់ត្រូវបានដាក់ឲ្យស្ថិតនៅក្នុងសភាពក្ស័ធន
- ការដកខ្លួនពីសហកម្មសិទ្ធិករណាម្នាក់
- ការបណ្តេញចេញនូវសហកម្មសិទ្ធិករណាម្នាក់។

**ខ. ការរំលាយដោយអំណាចកិច្ចសន្យាបង្កើតក្រុមហ៊ុន**

សកម្មភាពមួយចំនួនដែលជាព្រឹត្តិការណ៍ដែលអាចកំណត់នៅក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុន ដើម្បីជាធ្នូនសម្រាប់បើកឲ្យមានការរំលាយក្រុមហ៊ុនបាន។

---

[56] មាត្រា៥៦, ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

[57] មាត្រា៥៧,ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

- ការបញ្ចប់កិច្ចការនៃអាជីវកម្មស្របតាមគោលបំណងនៃកិច្ចសន្យាបង្កើតក្រុមហ៊ុន (លើកលែងតែសហកម្មសិទ្ធិករព្រមព្រៀងគ្នាជាឯកច្ឆន្ទដើម្បីបន្ត ) ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានបង្កើតឡើងដោយមានការកំណត់មួយនៃកិច្ចសន្យាអាចពន្យារបន្តសកម្មភាពរបស់ខ្លួនបានដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅអស់ តែម្តង[58]។
- អលទ្ធភាពក្នុងការបំពេញកិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន
- សហកម្មសិទ្ធិករព្រមព្រៀងគ្នាជាឯកច្ឆន្ទដើម្បីបញ្ចប់ក្រុមហ៊ុន

### គ. ការរំលាយដោយអំណាចតុលាការ

គេអាចស្វែងរកតុលាការដើម្បីធ្វើអន្តរាគមន៍ក្នុងការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដោយសារតែមានមូលហេតុមួយចំនួនៈ

- ចំពោះសេចក្តីសម្រេចរបស់តុលាការដែលអាចឲ្យរំលាយក្រុមហ៊ុនដោយសារតែមូលហេតុផ្លូវច្បាប់។
- ចំពោះសាលក្រមតុលាការបង្គាប់ឲ្យសហកម្មសិទ្ធិករណាម្នាក់ដកខ្លួន ឬបញ្ជាឲ្យរឹបអូសផលប្រយោជន៍របស់សហកម្មសិទ្ធិករណាម្នាក់ទៀតនៅក្នុងក្រុមហ៊ុន (ដូចជាដើម្បីយកទៅសងបំណុលដោយឡែករបស់សហកម្មសិទ្ធិករនោះ ទាងដែលមិនពាក់ព័ន្ធនឹងបំណុលរបស់ក្រុមហ៊ុនជាដើម)។

គួបញ្ជាក់ផងដែលថា សេចក្តីសម្រេចរបស់តុលាការអាចផ្អែកទៅលើមូលដ្ឋាននានាដូចខាងក្រោមៈ

- សហកម្មសិទ្ធិកររូបណាមានវិបត្តសតិ
- សហកម្មសិទ្ធិករប្រព្រឹត្តអំពើទុច្ចរិតផ្សេងៗ មានដូចជាក្លែងបន្លំមូលនិធិ
- សហកម្មសិទ្ធិករប្រព្រឹត្តផ្ទុយ នឹងខនៃកិច្ចសន្យាដែលបានព្រមព្រៀងរួច[59]។

## ១.២ នីតិវិធីនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិ

សេចក្តីសម្រេចក្នុងការរំលាយជាផ្លូវក៏ជាជំហានទីមួយនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិ គឺសហកម្មសិទ្ធករត្រូវធ្វើសេចក្តីសម្រេចពីការរំលាយក្រុមហ៊ុន ដោយការកំណត់នូវថ្ងៃចូលជាធរមាន នៃការរំលាយក្រុមហ៊ុនឲ្យបានត្រឹមត្រូវ។

### ក. កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុន

ដើម្បីចៀសវាងជម្លោះនៅក្នុងដំណើរការរំលាយក្រុមហ៊ុន សហកម្មសិទ្ធិករគួរធ្វើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុន។ កិច្ចព្រមព្រៀងនេះអាចបែងចែកដូចជាៈ

- ចេតនារំលាយក្រុមហ៊ុន
- កាលបរិច្ឆេទនៃការរំលាយជាធរមាន
- ការជូនដំណឹងពីការរំលាយក្រុមហ៊ុន

[58] មាត្រា៥៤, ,ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

[59] ច្បាប់ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រទី១៨៧។

- ការតែងតាំងអ្នកជម្រះបញ្ជី និងការសងទូទាត់សេវាជម្រះបញ្ជី
- អំណាចរបស់អ្នកជម្រះបញ្ជី
- ករណីយកិច្ចរបស់អ្នកជម្រះបញ្ជី
- ករណីកិច្ចរបស់សហកម្មសិទ្ធិករម្នាក់ៗនៅក្នុងដំណើរការជម្រះបញ្ជី (ដូចជាការផ្តល់ឯកសារដែលពាក់ព័ន្ធ)
- ការបែងចែកផលប្រយោជន៍របស់សហកម្មសិទ្ធិករ
- នីតិវិធិនៃការជម្រះបញ្ជី
- ចំនួនសំខាន់ស្តីពីដោះស្រាយជម្លោះផ្សេងៗ

**ខ. ការជូនដំណឹងស្តីពីការរំលាយក្រុមហ៊ុន**

ជំហានបន្ទាប់ គឺសហកម្មសិទ្ធិកររូបណាត្រូវចាត់ការធ្វើសេចក្តីជូនដំណឹងអំពីការរំលាយដល់មន្ត្រីចុះបញ្ជី និងសាធារណៈជនពីការរំលាយ។ ការជូនដំណឹងនេះមានផលប្រយោជន៍លើការការពារទាមទារពីតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយក្រុមហ៊ុន ឬសហកម្មសិទ្ធិករណាម្នាក់ក្រោយពីក្រុមហ៊ុនត្រូវបញ្ចប់ប្រតិបត្តិការរបស់ខ្លួនរួចហើយនោះ។ ដូចដែលមានចែងក្នុងមាត្រា ៥៩ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម សហកម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅតាមទម្រង់បែបបទ ដែលបានកំណត់ និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជីផងដែរ។ សហកម្មសិទ្ធិករទូទៅត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនកនុងរយៈពេល ៤ (បួន) សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបោះពុម្ព ឬផ្សាព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅនោះ ឬនៅក្នុងការផ្សព្វផ្សាយផ្សេងទៀតដូចមានចែងនៅក្នុងបទបញ្ជារបស់ក្រួសងពាណិជ្ជកម្ម។ លិខិជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវមានចែងក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម[60]។

ម្យ៉ាងវិញទៀតបើការជូនដំណឹងដែលធ្វើតាមទម្រង់ខាងលើជាការគ្រប់គ្រាន់តាមផ្លូវច្បាប់ ដើម្បីតតាំង និងការទាមទាររបស់តតិយជនក្តី ជាការគួរសហកម្មសិទ្ធិករគួរតែធ្វើលិខិតជូនដំណឹងមួយទៀតដល់តតិយជនដែលធ្លាប់ធ្វើពាណិជ្ជកិច្ចជាមួយខ្លួន ដើម្បីឲ្យពួកគេបានដឹងពីការរំលាយក្រុមហ៊ុន និងបញ្ឈប់ការធ្វើពាណិជ្ជកិច្ចក្រោយថ្ងៃរំលាយក្រុមហ៊ុន។

## ផ្នែកទី២៖ ការជម្រះបញ្ជី

ការជម្រះបញ្ជី គឺជាដំណើរការចាត់ចែងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដើម្បីយកទៅសងបំណុលរបស់ក្រុមហ៊ុន រួចហើយយកផលលក់ដែលនៅសល់ពីការសងបំណុលទៅបែងចែកឲ្យសហកម្មសិទ្ធិករម្នាក់ៗទៅតាមសមាមាត្រនៃចំណែកផលប្រយោជន៍របស់គេ ឬតាមរូបមន្តនៃការបែងចែកណាមួយដែលមានចែងនៅក្នុងកិច្ច

[60] មាត្រា៥៩, ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

សន្យាបង្កើតក្រុមហ៊ុន។ ក្រោយពីនោះមក ក្រុមហ៊ុនត្រូវបានរំលាយជាស្ថាពរ។ ពេលជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ សហកម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំនឹងទៅមន្ត្រីចុះបញ្ជី អំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ តាមទម្រង់បែបបទដែលបានកំណត់ និងត្រូវធ្វើការតែងតាំង អ្នកជម្រះ បញ្ជីផង។

សហកម្មសិទ្ធិករទូទៅត្រូវធ្វើការចុះផ្សាយជាបន្ទាប់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ០៤(បួន) សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបោះពុម្ព ឬ ផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុន មានការិយាល័យរបស់ខ្លួននៅទីនោះ ឬ នៅក្នុងការផ្សព្វផ្សាយផ្សេងទៀត ដូចដែលមានចែងក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម។ លិខិតជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវមានចែងក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម។ នៅពេលធ្វើការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅសិទ្ធិក្នុងការកាន់កាប់ នឹងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវប្រគល់ឲ្យអ្នកជម្រះបញ្ជី។ អ្នកជម្រះបញ្ជីត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកចាត់ចែងលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងអ្នកជម្រះបញ្ជីត្រូវបានផ្តល់សិទ្ធិពេញលេញក្នុងការចាត់ចែងទាំងមូល។ អ្នកជម្រះបញ្ជីមានសិទ្ធិទាមទារ ពីសហកម្មសិទ្ធិករទូទៅទាំងអស់នូវឯកសារនានា និងការបកស្រាយដែលពាក់ព័ន្ធដល់សិទ្ធិ និងកាតព្វកិច្ចនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិទៅសងបំណុលបៀវត្សបុគ្គលិក បំណុលពន្ធរបស់រដ្ឋ និងបំណុលផ្សេងទៀតទៅតាមសិទ្ធិជាមុនរួចទើបធ្វើការបែងចែកភាគទុ។ អ្នកជម្រះបញ្ជីត្រូវធ្វើការកាតចំណែកទ្រព្យសម្បត្តិ ដែលនៅសេសសល់ឲ្យទៅសហកម្មសិទ្ធិករទូទៅទាំងឡាយទៅតាមសមាមាត្រស្មើៗគ្នា ប្រសិនបើគ្មានចែងផ្សេងនៅក្នុងកិច្ចសន្យា នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ។

ក្នុងករណីដែលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមាន រួមទាំងទ្រព្យសម្បត្តិរបស់តតិយជនអ្នកជម្រះបញ្ជិត្រូវតែបង្វិលទ្រព្យសម្បត្តិរបស់តតិយជន ទៅឲ្យតតិយជនវិញ។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រហូតដល់រយៈពេល ១០ (ដប់)ឆ្នាំ ចាប់ពីពេលដែលបានជម្រះបញ្ជីរួច។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាង ប្រសិនបើឯកសារទាំងនោះតម្រូវឲ្យទុកជាភស្តុតាង។ ការជម្រះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបានបញ្ចប់ដោយធ្វើការតម្កល់ទុកនូវសេចក្តីជូនដំណឹងអំពីការបិទបញ្ជី នៅក្រសួងពាណិជ្ជកម្មតាមបែបបទដែលបានកំណត់ទុក និងការតម្កល់ទុកឯកសារនេះគឺជាការ លុបចោលនូវ នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។

សហកម្មសិទ្ធិករត្រូវតែងតាំងអ្នកជម្រះបញ្ជីម្នាក់ឲ្យបំពេញកិច្ចការជម្រះបញ្ជី។ សហកម្មសិទ្ធិករទូទៅអាចតែងតាំងសហកម្មសិទ្ធិករណាម្នាក់ជាអ្នកជម្រះបញ្ជីក៏បាន ឬតែងតាំងអ្នកក្រៅពីបាន។ អ្នកជម្រះបញ្ជីត្រូវមានសិទ្ធិ និងអំណាចដូចតទៅនេះ៖

- ទាមទារយកឯកសារនានាដែលជួយដល់ការជម្រះបញ្ជី (ដូចជាកិច្ចសន្យាបង្កើតក្រុមហ៊ុន, បញ្ជីគណនេយ្យ, បញ្ជីទ្រព្យរបស់សម្បត្តិក្រុមហ៊ុន, កិច្ចសន្យានានាដែលក្រុមហ៊ុនបានធ្វើជាមួយតតិយជន, កិច្ចសន្យាការងារ ។ល។
- កាន់កាប់, ប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន

- យកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទៅលក់ និងសងម្ចាស់បំណុលរបស់ក្រុមហ៊ុនទៅតាមលំដាប់សិទ្ធិបុរិមានៃបំណុល, បង់ពន្ធដែលក្រុមហ៊ុននៅជំពាក់រដ្ឋ, បង់ការចំណាយផ្សេងៗទាក់ទង នឹងការជម្រះបញ្ជី
- បង្វិលទ្រព្យសម្បត្តិរបស់តតិយជនដែលក្រុមហ៊ុនយកមកប្រើ
- យកទ្រព្យសម្បត្តិដែលនៅសល់ទាំងអស់ទៅបែងចែកឲ្យសហកម្មសិទ្ធិករតាមសមាមាត្រនៃចំណែកផលប្រយោជន៍របស់គេ (ក្នុងករណីកិច្ចសន្យាបង្កើតក្រុមហ៊ុនបានចែងពីសមាមាត្រនោះ) ឬបែងចែកស្មើគ្នា (បើសិនកិច្ចសន្យាក្រុមហ៊ុនមិនបានចែងបញ្ជាក់អំពីសមាមាត្រណែចំណែកផលប្រយោជន៍)
- ប្រសិនបើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមិនមានគ្រប់គ្រាន់ដើម្បីជម្រះបំណុលបានទេ អ្នកជម្រះបញ្ជីត្រូវតម្រូវឲ្យសហកម្មសិទ្ធិករម្នាក់ៗយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនមកបន្ថែមដើម្បីជម្រះបំណុលតទៅទៀត[61]។

## ១.១ អ្នកជម្រះបញ្ជី

### ១.១.១ ការទូទាត់ក្នុងការជម្រះបញ្ជី

ការទូទាត់នៅក្នុងការជម្រះបញ្ជីត្រូវធ្វើតាមលំដាប់នៃដំណាក់កាលនីមួយៗដូចជា៖

ក. អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទៅសងទូទាត់ឲ្យបុគ្គលិករបស់ក្រុមហ៊ុន និងថ្លៃសេវា និងលើការចំណាយក្នុងការជម្រះបញ្ជី

ខ. អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទៅទូទាត់ពន្ធដារ

គ.បន្ទាប់មកអ្នកជម្រះបញ្ជីត្រូវយកទ្រព្យរបស់ក្រុមហ៊ុនទៅសងម្ចាស់បណុលទៅតាមសិទ្ធិបុរិមារបស់គេ។ម្ចាស់បំណុលដែលបានធ្វើសុក្រឹតកម្មលើសិទ្ធិប្រាតិភោគីជាម្ចាស់បំណុលដែលមានសិទ្ធិបុរិមាខ្ពស់ជាងគេ[62]

ឃ. ប្រសិនបើទ្រព្យទាំងអស់របស់ក្រុមហ៊ុមិនអាចយកទៅទូទាត់បំណុលបានទេ អ្នកជម្រះបញ្ជីត្រូវបង្គាប់ឲ្យសហកម្មសិទ្ធិករនីមួយៗ ដាក់ទ្រព្រសម្បត្តិផ្ទាល់ខ្លួនបន្ថែមតាមសមាមាត្រនៃការចំណេញ/ខាតរបស់ខ្លួន។ បើសហកម្មសិទ្ធិករណាមួយក្នុងបណ្តាសហកម្មសិទ្ធិករដទៃទៀតដែលមានទ្រព្យផ្ទាល់ខ្លួននោះមកសងម្ចាស់បំណុលបន្ថែម។

ង. បើទ្រព្យក្រុមហ៊ុនត្រូវបានយកទៅទូទាត់បំណុលរួចហើយ ហើយនៅសល់អ្នកជម្រះបញ្ជីត្រូវយកទ្រព្យដែលនៅសល់នោះ ទៅតាមសមាមាត្រនៃផលប្រយោជន៍របស់សហកម្មសិទ្ធិករម្នាក់ៗនៅក្នុងក្រុមហ៊ុន

ច. ចុងបញ្ចប់ អ្នកជម្រះបញ្ជីត្រូវតម្កល់ទុកបាយការណ៍ការបិទការជម្រះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម

ឆ. ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម តែម្តង។

### ១.១.២ អានុភាពនៃការរំលាយក្រុមហ៊ុនកម្មសិទ្ធិទូទៅ

ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលជានីតិបុគ្គលបន្តបុគ្គលភាពរបស់ខ្លួនរហូតដល់ការជម្រះបញ្ជីបានចប់សព្វគ្រប់។ នៅពេលដែលក្រុមហ៊ុនត្រូវបានប្រកាសថាត្រូវបានរំលាយសហកម្មសិទ្ធិករទាំងអស់ត្រូវបញ្ឈប់សកម្មភាពអាជីវកម្មក្នុងនាមក្រុមហ៊ុន ជាមួយតតិយជនបើពុំនោះទេ សហកម្មសិទ្ធិករត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន កិច្ចការដែលធ្វើជាមួយតតិយ

[61] មាត្រា ៤២,ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

[62] មាត្រា ១២,ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។

ជននៅមិនទាន់ចប់នៅឡើយទេ កិច្ចការនោះត្រូវធ្វើឲ្យចប់ ហើយសកម្មភាពបញ្ចប់កិច្ចការនោះនៅតែចងកាតព្វកិច្ចលើក្រុមហ៊ុនដដែល[63]។

[63] ច្បាប់ក្រុមហ៊ុន, លោក កុយ នាម, ឆ្នាំ២០១៦, ទំព័រទី១៩០។

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវលើប្រធានបទស្ដីពី "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ" រួចមកយើងខ្ញុំបានស្វែងយល់អំពីក្របខ័ណ្ឌនៃក្រុមហ៊ុនសហកម្មសិទ្ធិមានទម្រង់ក្រុមហ៊ុន គឺក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និង ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ប៉ុន្តែប្រធានបទរបស់យើងខ្ញុំគឺ ផ្ដោតសំខាន់ទៅលើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ តែប៉ុណ្ណោះ។ ដូចបានបង្ហាញក្នុងប្រធានបទខាងលើ រួចមកហើយថា ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវសិក្សាទៅលើ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដំណើរការនៃការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនសិទ្ធិទូទៅ និងការរំលាយ ក៏ដូចជាការជ្រះបញ្ជីក្រុមហ៊ុនក្រុមហ៊ុនសហកម្មសិទ្ធិទូទៅផងដែរ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ទទួលបាននូវបុគ្គលលិកលក្ខណៈសញ្ជាតិខ្មែរ លុះត្រាតែ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាផ្ទាល់តែម្ដង ហើយអត្ថប្រយោជន៍ នៅក្នុងក្រុមហ៊ុនចាប់ពី ៥១% ឡើងទៅត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដែល មានសញ្ជាតិខ្មែរ។ នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបានដាក់បញ្ចូលនូវនាមរបស់សហកម្មសិទ្ធិករទូទៅ ម្នាក់ឬច្រើននាក់ ហើយនៅខាងក្រោយ ឬខាងក្រោមនាមករណ៍នោះត្រូវបន្ថែមពាក្យថា « ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ» ដោយក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅត្រូវប្រើប្រាស់នាមករណ៍របស់ខ្លួននៅពេលធ្វើ ពាណិជ្ជកិច្ច ហើយសហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក ឯកសារ និង ការចុះផ្សាយ ដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងមួយវិញទៀតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវរក្សាទុកជាឯកសារនូវសៀវភៅបញ្ជី និងកំណត់ហេតុងទាំងឡាយនៅទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន។ នៅពេលសហកម្មសិទ្ធិករទូទៅបានយល់ព្រមបង់ភាគទុននូវចំនួនទឹកប្រាក់ណាមួយ ហើយខកខានមិនបានបង់វិញ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួលខុសត្រូវ ចំពោះការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះបានសន្យាបង់ រួមទាំងការខូចខាតបន្ថែមទៀតដែលត្រូវទាមទាពីរសហកម្មសិទ្ធិករទូទៅនោះ។ នៅពេលសហកម្មសិទ្ធិករទូទៅ បានទទួលយល់ព្រមដាក់ភាគទុន ជាចំណេះដឹងសេវា ឬជាសកម្មភាព សហកម្មសិទ្ធិករទូទៅនោះ ត្រូវជាប់កាតព្វកិច្ចរហូត ដរាបណាបុគ្គលនោះនៅតែជាសហកម្មសិទ្ធិករទូទៅនោះ។ កិច្ចសន្យាជាលាយលក្ខណ៍អក្សរ សៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ ប្រសិនបើភាគទុនរបស់សហកម្មសិទ្ធិករទូទៅ ជាចំណេះដឹង សេវា ឬជាសកម្មភាព។ ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រួមមានភាគជាទុនសាច់ប្រាក់ និងជាវត្ថុ។ ភាគទុនជាវត្ថុត្រូវវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការវាយតម្លៃនោះ។ ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវគណនាជារូបិយវត្ថុជាតិ។

ម្យ៉ាងវិញទៀត ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ ហើយធ្វើការសិក្សាទៅលើមូលហេតុដែលមានចែងក្នុងកិច្ចសន្យា និងការរំលាយក្រុមហ៊ុនដោយតុលាការស្របតាមមូលហេតុរបស់ច្បាប់។ អ្នកជម្រះបញ្ជី ត្រូវធ្វើការចាត់ចែងចំណែកទ្រព្យសម្បត្តិ ដែលនៅសេសសល់ឲ្យទៅសហកម្មសិទ្ធិទូទៅនោះទេ។ ក្នុងករណី ដែលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានរួមទាំងទ្រព្យសម្បត្តិរបស់តតិយជនផង។ អ្នកជម្រះបញ្ជីត្រូវតែបង្វិលទ្រព្យសម្បត្តិរបស់

តតិយជនទៅឲ្យតតិយជននោះវិញ។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរហូតដល់រយៈពេល ១០ឆ្នាំ ចាប់ពីពេលដែលបានជម្រះបញ្ជីរួច។

សរុបសេចក្តីមក ការដាក់ទុនក្នុងគោលដៅស្វែងរកប្រាក់ចំណេញរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមានទម្រង់សម្តែងចេញជារូបភាពផ្សេងៗចាប់ពីការធ្វើអាជីវកម្មតូចតាច បុគ្គលខ្លះបោះទុនដំណើរការតែម្នាក់ឯង បុគ្គលខ្លះទៀតប្រមូលគ្នីគ្នាដាក់ទុនចូលហ៊ុនជាក្រុមហ៊ុនរួមមានការដាក់ជាទឹកប្រាក់ ការដាក់ជាព្រទ្យសម្បត្តិ រីឯខ្លះទៀតដាក់ជាចំណេះដឹង បទពិសោធន៍ ឬជំនាញ ដើម្បីធ្វើសកម្មភាពសេដ្ឋកិច្ច ក្នុងផលប្រយោជន៍បង្កើតជាធនធាន ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ សហគមន៍ និងសេដ្ឋកិច្ចជាតិ ផងដែរ។ លើសពីនេះទៅទៀតសកម្មភាពនៃការបណ្តាក់ទុនមិនត្រឹមតែស្តែងឡើងតាមរយៈចំណងវប្បធម៌ពីប្រទេសមួយទៅប្រទេសមួយនោះទេ ថែមទាំងបង្កឲ្យមានការបណ្តុំជាភាគហ៊ុនដែលកើតឡើងដោយពហុជាតិសាសន៍ជាច្រើនទៀតផង។

# អនុសាសន៍

មុននឹងធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី « ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ » យើងទាំងពីរបាន សង្កេតឃើញវិស័យក្រុមហ៊ុនមានការរីចម្រើនជាខ្លាំងគួឲ្យកត់សម្គាល់នៅក្នុងប្រទេសកម្ពុជាអស់រយៈកាលជាច្រើនឆ្នាំ មកហើយ។

ក្នុងនាមយើងខ្ញុំជានិស្សិតច្បាប់ យើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីសោមនស្សរីករាយខ្លាំងណាស់ ដែល បានសិក្សាស្រាវជ្រាវលើវិស័យពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា ជាពិសេសទៅលើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែល យើងខ្ញុំទាំងពីរនាក់ជ្រើសរើសយកមកធ្វើបទបង្ហាញ នៃការបញ្ចប់ការសិក្សា។ ក្នុងនោះផងដែលក៏បានលេចចេញជា បញ្ហាចោទជាសំណួរថា ហេតុអ្វីបានជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ពុំសូវមានការពេញនិយមពីសំណាក់ពាណិជ្ជករ កម្ពុជា? បន្ទាប់ពីឆ្លងកាត់ការសិក្សាស្រាវជ្រាវមកទើបដឹងអំពីមូលហេតុសំខាន់មួយចំនួនទាក់ទងទៅនឹងបញ្ហានេះ។

ជាការពិតណាស់ ជាក់ស្តែងនៅប្រទេសកម្ពុជា ពាណិជ្ជករតែងតែនិយមជ្រើសរើសប្រភេទក្រុមហ៊ុនសហម្ម សិទ្ធិមានកម្រិត, ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមូលធនជាដើម ក្នុងការបង្កើតក្រុមហ៊ុន។ នេះជាមូលហេតុសំខាន់ដែលបង្កឲ្យយើងខ្ញុំទាំងពីរធ្វើការសិក្សាទៅលើប្រធានបទ « ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ » ដើម្បីស្រាយចម្ងល់។ ក្រោយមកបានឆ្លុះបញ្ចាំងឲ្យឃើញនូវលក្ខណៈសម្បត្តិក៏ដូចជាគុណវិបត្តិរបស់ក្រុមហ៊ុនសហកម្ម សិទ្ធិទូទៅនេះតែម្តង។

គួបញ្ជាក់ផងដែលថា ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវមានម្ចាស់ភាគហ៊ុនចាប់ពី ២ (ពីរ) នាក់ឡើងទៅ ។ ចំពោះកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចធ្វើឡើងជាលាយលក្ខណ៍អក្សរក៏បាន ឬធ្វើត្រឹមតែផ្ទាល់មាត់ក៏ បានដូចគ្នា។ សម្រាប់ដើមទុនដែលយកមកដាក់រកស៊ីជាមួយគ្នា ក្នុងប្រភេទក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះ គឺអាច ដាក់ជាសាច់ប្រាក់ ទ្រព្យសម្បត្តិ ឬជាចំណេះដឹង។ ហើយរយៈពេលនៃកិច្ចសន្យាបង្កើតក្រុមហ៊ុននេះអាចធ្វើឡើងដោយ មានរយៈពេលកំណត់ក៏បាន ឬដោយរយៈពេលមិនកំណត់ក៏បាន។ តួយ៉ាងគុណវិបត្តិធំបំផុត គឺនៅត្រង់ថា ការទទួល ខុសត្រូវលើបំណុលវិញ គឺមានលក្ខណៈពិសេសត្រង់ថា ជាការទទួលខុសត្រូវដោយគ្មានកម្រិត ត្រង់កន្លែងនេះចង់បាន ន័យថា នៅក្នុងករណី ដែលក្រុមហ៊ុនជំពាក់បំណុលគេ ហើយក្រុមហ៊ុនមិនមានលុយគ្រប់គ្រាន់ ដើម្បីសងបំណុលនេះ ទេ ម្ចាស់ភាគហ៊ុន ត្រូវចេញលុយពីហោប៉ៅខ្លួនឯង ដើម្បីសងបំណុលដែលជំពាក់គេនោះ។ ម្ចាស់ភាគហ៊ុនម្នាក់ៗ ត្រូវ រ៉ាប់រងបំណុល ទៅតាមសមាមាត្រនៃចំណែកហ៊ុនដែលខ្លួនមាននៅក្នុងក្រុមហ៊ុន។ ក៏ប៉ុន្តែ មានចំណុចសំខាន់ មួយទៀត ដែលត្រូវចាប់អារម្មណ៍ គឺនៅត្រង់ថា ទោះបីជាម្ចាស់ភាគហ៊ុនម្នាក់ៗ ទទួលខុសត្រូវលើបំណុលទៅតាម ចំណែកហ៊ុនរបស់ខ្លួនក៏ពិតមែន ប៉ុន្តែប្រសិនបើក្នុងករណីមានវិវាទរឿងមិនសងបំណុល ម្ចាស់បំណុលអាចប្តឹងទាមទារ បំណុលទាំងអស់ពីម្ចាស់ហ៊ុនរូបណាតែម្នាក់ ដោយមិនចាំបាច់ប្តឹងទាមទារចំណែកពីម្ចាស់ហ៊ុនម្នាក់ៗដាច់ពីគ្នាទេ។ ក្នុងករណីនេះ ម្ចាស់ហ៊ុនណា ដែលត្រូវម្ចាស់បំណុលប្តឹង គឺត្រូវតែសងបំណុលទាំងអស់តាមបណ្តឹង គឺសងទាំង ចំណែកបំណុលខ្លួនឯង និងចំណែកបំណុលរបស់ម្ចាស់ហ៊ុនផ្សេងទៀតរួចហើយគាត់អាចទៅទាមទារគិតគូរទូទាត់ ជាមួយម្ចាស់ហ៊ុនផ្សេងទៀត។

ជាទូទៅ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គេច្រើនបង្កើតឡើង នៅក្នុងអាជីវកម្មជាលក្ខណៈវិជ្ជាជីវៈ ដូចជា បង្កើតគ្លីនិកពេទ្យ ការិយាល័យមេធាវី គណនេយ្យករ ស្ថាបត្យករ ឬកុងស៊ុលតង់ ជាដើម។ ព្រោះវាមានលក្ខណៈងាយស្រួលនៅត្រង់ថា ប្រភេទក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះ អាចចាប់ផ្តើមដំណើរការបានដោយមិនទាមទារដើមទុនច្រើន។ មានគ្នាតែពីរបីនាក់ មានកម្លាំង មានពេលវេលា មានចំនេះជំនាញ មានដើមទុនម្នាក់បន្តិចៗ ល្មមអាចចូលហ៊ុនគ្នាដើម្បីទិញ ឬជួលទីតាំង និងសម្ភារៈសំខាន់ៗដែលចាំបាច់ គឺអាចចាប់ផ្តើមដំណើរការបង្កើតជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្នុងការប្រកបអាជីវកម្មបាន ហើយក៏មិនតម្រូវឲ្យមានឯកសារច្បាប់អ្វីស្មុគស្មាញច្រើនដែរ។ ដោយមើលឃើញនូវកត្តាដំដ៏សំខាន់ និងមានប្រយោជន៍ទាំងនេះហើយ ទើបយើងខ្ញុំចង់លើកទឹកចិត្តដល់ពាណិជ្ជករទាំងអស់មកចាប់អារម្មណ៍ លើការបង្កើតក្រុមហ៊ុនជាប្រភេទសហក្មមសិទ្ធិទូទៅនេះ។

# ឯកសារយោង

## ១.ឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្ត

### ១.១ ក្រម

- ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

### ១.២ ច្បាប់

- ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។
- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, លេខ នស/រកម/០៦៩៥/០៤, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥។

### ១.៣ ប្រកាស

- ប្រកាសស្តីពីការចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម, លេខ៣៨១ ពណ.នតកប្រក, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៨។

## ២. សៀវភៅ

- កុយ នាម, ច្បាប់ក្រុមហ៊ុន, ភ្នំពេញ, ឆ្នាំ២០១៦។
- គង់ សាផន, នីតិពាណិជ្ជកម្ម, ភ្នំពេញ, ឆ្នាំ ២០១៧។
- សន សោភ័ណ្ឌ, នីតិពាណិជ្ជកម្ម, ភ្នំពេញ , ឆ្នាំ ២០១៣។
- ខាត់ ធី, នីតិពាណិជ្ជកម្ម, ភ្នំពេញ, ២០១៥។
- អ៊ីវ ប៉ូលី ,នីតិក្រុមហ៊ុន, ភ្នំពេញ, ឆ្នាំ២០០៨។
- កៅ មុយចង,ច្បាប់ពាណិជ្ជកម្ម, បោះពុម្ពលើកទី៣, ឆ្នាំ២០១៥។
- សៀវភៅស្តីពីមហាជនក្រុមហ៊ុនឯកជន និងក្រុមហ៊ុនសហកម្មសិទ្ធិ។
- សៀវភៅណែនាំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងការប្រកបអាជីវកម្មអនុលោមតាមច្បាប់។

## ៣. គេហទំព័រ

https://www.rfi.fr/km/different-types-of-companies-in-cambodian-law (កម្មវិធីផ្សេងទៀត/ នាទីយល់ដឹងអំពីច្បាប់ និងជំនួញ ០៨.១១.២០១២) (ចូលទស្សនាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១)

https://knowledgelegalkrn.blogspot.com/2017/04/blog-post_24.html (គេហទំព័រចំណេះដឹងផ្នែកច្បាប់)។ (ចូលទស្សនាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១)

http://www.anna-associates.com/blog/1621479177373 ការចុះបញ្ជីក្រុមហ៊ុន/សហគ្រាសពាណិជ្ជកម្ម (ចូលទស្សនាថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១)

# ឧបសម្ព័ន្ធ

# ច្បាប់

# ស្តីពី

# សហគ្រាសពាណិជ្ជកម្ម

ស៊ី

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះកំណត់ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ដែលធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។ ក្រុមហ៊ុនមូលធនមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ។

**មាត្រា ២.–**

នៅក្នុងច្បាប់នេះ ពាក្យបច្ចេកទេសទាំងឡាយមាននិយមន័យដូចតទៅ :

១-បុគ្គលមានន័យថារូបវន្តបុគ្គល ឬ នីតិបុគ្គល ។

២-មន្ត្រីចុះបញ្ជីមានន័យថាអ្នកចុះបញ្ជី ដែលបានតែងតាំងដោយអនុលោមទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

៣-ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមានន័យថាការិយាល័យដែលបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ។

៤-បុត្រសម្ព័ន្ធមានន័យថាក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនដែលគ្រប់គ្រងដោយក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនផ្សេងទៀត ដែលជា “ក្រុមហ៊ុនមេ” ។

ក-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសហកម្មសិទ្ធិគឺក្រុមហ៊ុនសហកម្មសិទ្ធិមេនោះកាន់កាប់អត្ថប្រយោជន៍ភាគច្រើននៃអត្ថប្រយោជន៍របស់បុត្រសម្ព័ន្ធនោះ ។

ខ-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមូលធនគឺក្រុមហ៊ុនមូលធនមេនោះត្រូវកាន់កាប់ភាគច្រើននៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុន ។

**មាត្រា ៣.-**

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវមានទីស្នាក់ការចុះបញ្ជី និងភ្នាក់ងារចុះបញ្ជីជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវទីកន្លែងជាក់លាក់របស់ទីស្នាក់ការចុះបញ្ជី ដែលមានអាសយដ្ឋានពិតប្រាកដ និងអាសយដ្ឋានសម្រាប់ទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាសយដ្ឋានទាំងនោះខុសគ្នា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវឈ្មោះរបស់ភ្នាក់ងារចុះបញ្ជី ហើយភ្នាក់ងារចុះបញ្ជីនោះ ត្រូវតែជារូបវន្តបុគ្គល ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់ ។ ភ្នាក់ងារចុះបញ្ជីមានសិទ្ធិទទួលលិខិតផ្លូវការ និងឯកសារទាំងឡាយ ព្រមទាំងដីកាអញ្ជើញ ដីកាកោះពីតុលាការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី និងការផ្លាស់ប្តូរភ្នាក់ងារចុះបញ្ជីក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីមានការផ្លាស់ប្តូរ ។

ក្រុមហ៊ុនដែលបង្កើតឡើងស្របតាមច្បាប់នេះ ត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

ឯកសារទាំងឡាយនៃព័ត៌មានតម្រូវដោយច្បាប់ ដែលត្រូវផ្តល់ទៅឱ្យក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវប្រគល់ឱ្យទៅភ្នាក់ងារចុះបញ្ជីនៅឯទីស្នាក់ការចុះបញ្ជី នៅក្នុងអំឡុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់ ។

ឯកសារទាំងឡាយអាចប្រគល់ឱ្យទៅសហកម្មសិទ្ធិករបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចប្រគល់ឱ្យទៅសហកម្មសិទ្ធិករទូទៅបានក្នុង

ករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ឬ អាចប្រគល់ឱ្យទៅអភិបាលបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនមូលធន ។

ប្រសិនបើការបញ្ជូនឯកសារមិនអាចធ្វើទៅតាមវិធីខាងលើនេះទេ ឯកសារទាំងនោះអាចប្រគល់ទៅឱ្យមន្ត្រីចុះបញ្ជី ហើយមន្ត្រីចុះបញ្ជីនោះ ត្រូវផ្ញើឱ្យ ទៅក្រុមហ៊ុនវិញ តាមអាសយដ្ឋានចុងក្រោយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនដូចដែលមាននៅក្នុងបញ្ជីពាណិជ្ជកម្មស្រាប់ ។ ការបញ្ជូនឯកសារតាមរយៈមន្ត្រីចុះបញ្ជីត្រូវបានចាត់ទុកថាជាការបញ្ជូនទៅក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ។

**មាត្រា ៥.-**

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវប្រើនាមករណ៍ជាភាសាខ្មែរ ។ នាមករណ៍ជាភាសាខ្មែរ ត្រូវដាក់នៅផ្នែកខាងលើបង្អស់ ហើយត្រូវមានទំហំធំជាងភាសាដទៃទៀតប្រសិនបើមាន ។ ការបកប្រែន័យរបស់នាមករណ៍ក្រុមហ៊ុនពីភាសាមួយទៅភាសាមួយទៀតត្រូវបានហាមឃាត់ ។ នាមករណ៍ជាភាសាខ្មែរ និងភាសាដទៃទៀតត្រូវមានសូរសព្ទដូចគ្នា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវចារឹកជាភាសាខ្មែរ នៅផ្នែកខាងលើនៃត្រាសញ្ញាក្បាលលិខិត បែបបទឯកសារ ឬឯកសារដែលប្រើប្រាស់ជាសាធារណៈ និងនៅផ្នែកលើនៃសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មជាសាធារណៈ ដែលតាំងនៅលើដែនដី ដែនទឹក និងដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនអាចប្រើប្រាស់ និងអាចកំណត់ឈ្មោះជាភាសាដទៃទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន ។

**មាត្រា ៦.-**

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ដែលខកខានមិនបានបង់សោហ៊ុយ ប្រាក់ពិន័យ ការប្រាក់ដែលជំពាក់ក្រសួងពាណិជ្ជកម្ម ត្រូវហាមឃាត់ក្នុងការប្តឹងផ្តល់

ឬ ប្តឹងតវ៉ាក្នុងរឿងក្តីរដ្ឋប្បវេណីរហូតដល់បានសងគ្រប់នូវសោហ៊ុយ ប្រាក់ពិន័យ និង ការប្រាក់នោះ ។

វាក្យខ័ណ្ឌនេះ មិនហាមឃាត់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនធ្វើការប្តឹងតវ៉ាចំពោះការកំណត់សោហ៊ុយ ប្រាក់ពិន័យ ឬ ការប្រាក់ដែលខ្លួនត្រូវជំពាក់ឡើយ ។

ប្រសិនបើភាគីមួយប្តឹងជំទាស់ថា ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនជំពាក់ក្រសួងពាណិជ្ជកម្មនូវសោហ៊ុយ ប្រាក់ពិន័យ ឬ ការប្រាក់ពីក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ត្រូវដាក់បង្កាន់ដៃទទួលប្រាក់របស់ក្រសួងពាណិជ្ជកម្មទៅឱ្យតុលាការពិនិត្យ ។ តុលាការត្រូវទទួលយកបង្កាន់ដៃនោះជាភស្តុតាង រហូតដល់មានតឹកតាងផ្សេងៗទៀត ។

**មាត្រា ៧.-**

ក្រុមហ៊ុនដែលគ្រប់គ្រងដោយច្បាប់នេះ មានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ២

## ក្រុមហ៊ុនសហកម្មសិទ្ធិ

### ផ្នែកទី ១

### ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

### ក.-ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**មាត្រា ៨.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាកិច្ចសន្យារវាងបុគ្គលពីរ ឬ ច្រើន ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬ សកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជ-កិច្ចរួម ក្នុងគោលបំណងរកប្រាក់ចំណេញ ។

**មាត្រា ៩.-**

កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ។ ប្រសិនបើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ ។

**មាត្រា ១០.-**

ក្នុងករណីដែលកិច្ចសន្យានោះមិនច្បាស់លាស់ តុលាការត្រូវពិចារណានូវវាលវិធានដូចខាងក្រោម ដើម្បីកំណត់ថាតើភាគីទាំងអស់មានគោលបំណងរួមក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឬទេ :

ក-ក្នុងករណីដែលបុគ្គលពីរ ឬ ច្រើន កាន់កាប់ទ្រព្យសម្បត្តិរួមគ្នា ថាតើបុគ្គលទាំងនោះចែករំលែកប្រាក់ចំណេញដែលបានមកដោយទ្រព្យទាំងនោះឬទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ កើតឡើងដោយទ្រព្យសម្បត្តិរួមឬទេ ។

ខ-ក្នុងករណីដែលបុគ្គលពីរ ឬ ច្រើនចែករំលែកប្រាក់ចំណូលដែលបានមកពីការធ្វើពាណិជ្ជកិច្ច ថាតើបុគ្គលទាំងនោះ មានសិទ្ធិចូលរួមក្នុងទ្រព្យសម្បត្តិណាមួយដែលបង្កើតប្រាក់ចំណូលនោះឬទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះកើតឡើងដោយទ្រព្យសម្បត្តិរួមនោះឬទេ ។

**មាត្រា ១១.-**

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើង ភាគីនៃកិច្ចសន្យាត្រូវជាប់កាតព្វកិច្ចចាប់ពីពេលដែលកិច្ចសន្យានោះ ត្រូវបានធ្វើឡើងចប់សព្វគ្រប់លើកលែងតែកិច្ចសន្យាមានចែងផ្សេងពីនេះ ។

**មាត្រា ១២.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីសហកម្មសិទ្ធិករទូទៅម្នាក់ៗ ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈចាប់ពី

ពេលដែលបានចុះបញ្ជី ស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ហើយមានសិទ្ធិដូចតទៅ :

ក-ជាម្ចាស់លើចលននិងអចលនទ្រព្យក្នុងនាមក្រុមហ៊ុន ។

ខ-ធ្វើពាណិជ្ជកិច្ចក្នុងនាមក្រុមហ៊ុន ។

គ-ចុះកិច្ចសន្យាក្នុងនាមក្រុមហ៊ុន ។

ឃ-ប្តឹង ឬ ត្រូវគេប្តឹងក្នុងនាមក្រុមហ៊ុន ។

**មាត្រា ១៣.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទទួលបាននូវនីតិបុគ្គលិកលក្ខណៈសញ្ជាតិខ្មែរលុះត្រាតែ :

ក-ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-អត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចាប់ពី ៥១(ហាសិបមួយ)ភាគរយត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលមានសញ្ជាតិខ្មែរ ។

**មាត្រា ១៤.-**

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់បញ្ចូលនូវនាមរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ហើយនៅខាងក្រោយ ឬ ខាងក្រោមនាមករណ៍នោះត្រូវបន្ថែមពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ" ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវប្រើប្រាស់នាមករណ៍របស់ខ្លួននៅក្នុងពេលធ្វើពាណិជ្ជកិច្ច ។

**មាត្រា ១៥.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ និងការចុះផ្សាយ ដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវរក្សាទុកជាឯកសារនូវសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយនៅទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ។

## ខ_ ទំនាក់ទំនងពីសហកម្មសិទ្ធិករទូទៅម្នាក់ ទៅសហកម្មសិទ្ធិករទូទៅម្នាក់ទៀត

**មាត្រា ១៦._**

សហកម្មសិទ្ធិករទូទៅម្នាក់ៗអាច :

ក-បង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ជាសាច់ប្រាក់ ជាវត្ថុ ជាសេវាពីមុនដែលបានផ្តល់រួចមកហើយយ៉ាងពិតប្រាកដ ឬ ជាការសន្យាថានឹងផ្តល់នូវសេវានាពេលអនាគត ។

ខ-ដាក់ភាគទុនជាសេវាដែលជាចំណេះដឹង ឬ សកម្មភាពផ្សេងៗ ប៉ុន្តែមិនត្រូវរាប់បញ្ចូលនូវការប្រើប្រាស់ឥទ្ធិពលដែលទទួលបានពីមុខងារជាមន្ត្រីសាធារណៈ ។

**មាត្រា ១៧._**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ គឺជាកូនបំណុលនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចំពោះរាល់អ្វីៗដែលខ្លួនបានសន្យាចូលរួមទៅក្នុងក្រុមហ៊ុន ។

**មាត្រា ១៨._**

នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ទ្រព្យសម្បត្តិជាភាគទុន សហកម្មសិទ្ធិករទូទៅនោះត្រូវធ្វើការផ្ទេរសិទ្ធិពីម្ចាស់ ឬ ពីសិទ្ធិដែលខ្លួនមានលើទ្រព្យនោះ ទៅដាក់ជាទ្រព្យរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ១៩._**

នៅពេលសហកម្មសិទ្ធិករទូទៅ បានទទួលយល់ព្រមបង់ភាគទុននូវចំនួនទឹកប្រាក់ណាមួយ ហើយខកខានមិនបានបង់វិញ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួល

ខុសត្រូវចំពោះការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះបានសន្យាបង់ រួមទាំងការខូចខាតបន្ថែមទៀត ដែលត្រូវទាមទារពីសហកម្មសិទ្ធិករទូទៅនោះ ។

**មាត្រា ២០.-**

នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ភាគទុន ជាចំណេះដឹង ជាសេវា ឬ ជាសកម្មភាព សហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចរហូត ដរាបណាបុគ្គលនោះនៅតែជាសហកម្មសិទ្ធិករទូទៅ ។

កិច្ចសន្យាជាលាយលក្ខណ៍អក្សរ សៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ប្រសិនបើភាគទុនរបស់សហកម្ម-សិទ្ធិករទូទៅជាចំណេះដឹង ជាសេវា ឬ ជាសកម្មភាព ។

**មាត្រា ២១.-**

ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួមមានទាំងភាគទុនជាសាច់ប្រាក់ និងជាវត្ថុ ។ ភាគទុនជាវត្ថុត្រូវវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការវាយតម្លៃនោះ ។

ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនត្រូវរាប់បញ្ចូលនូវភាគទុនជាចំណេះដឹង ជាសេវា ឬ ភាគទុនជាសកម្មភាពទេ ។

**មាត្រា ២២.-**

ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវគណនាជារូបិយវត្ថុជាតិ ។

**មាត្រា ២៣.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវមានសិទ្ធិទទួលប្រាក់ចំណេញ និងត្រូវរួមចំណែកការខាតបង់របស់ក្រុមហ៊ុន ។

ខទាំងឡាយនៃកិច្ចសន្យាណា ដែលដកសហកម្មសិទ្ធិករទូទៅពីសិទ្ធិទទួលប្រាក់ចំណេញត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព ។

ខទាំងឡាយនៃកិច្ចសន្យាណា ដែលដកសហកម្មសិទ្ធិករទូទៅពីការជាប់កាតព្វកិច្ចក្នុងការរួមចំណែកការខាតបង់ ត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាពចំពោះតតិយជនឡើយ ។

**មាត្រា ២៤.-**

សមាមាត្រនៃផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅម្នាក់ៗនៅក្នុងទ្រព្យសម្បត្តិ ប្រាក់ចំណេញ និងការខាតបង់គឺស្មើគ្នា លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យា ។

ប្រសិនបើកិច្ចសន្យាចែងអំពីផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅ ដោយសំដៅចំពោះតែទ្រព្យសម្បត្តិ ប្រាក់ចំណេញ ឬការខាតបង់ ពេលនោះសមាមាត្រ ដែលបានបង្កើតឡើងក្នុងករណីនេះ ត្រូវបានសន្មតជាមុន ដើម្បីអនុវត្តទៅលើតែករណីទាំងពីរនោះ ។

**មាត្រា ២៥.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុននូវរាល់ផលកម្រៃ និងប្រាក់ចំណេញទាំងឡាយ ដែលសហកម្មសិទ្ធិករទូទៅនោះ បានមកពីការធ្វើអាជីវកម្មណាមួយនៅក្នុងពាណិជ្ជកិច្ច ឬ ពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅផ្សេងទៀត ។ សហកម្មសិទ្ធិករទូទៅទាំងឡាយ មិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ ។

**មាត្រា ២៦.-**

គ្មានសហកម្មសិទ្ធិករទូទៅណាម្នាក់ ត្រូវទទួលប្រាក់បៀវត្សពីការធ្វើពាណិជ្ជកិច្ចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

**មាត្រា ២៧.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនូវរាល់ការខូចខាតដែលបង្កឡើងដោយកំហុសឆ្គងរបស់សហកម្មសិទ្ធិករទូទៅនោះ ។

**មាត្រា ២៨.-**

សហកម្មសិទ្ធិករទូទៅដែលប្រកបកិច្ចការពាណិជ្ជកម្មដោយស្មោះត្រង់ចំពោះក្រុមហ៊ុន មានសិទ្ធិទទួលនូវសំណងនៃការខូចខាតដែលខ្លួនបានធ្វើក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិទទួលនូវសំណងនៃការខូចខាតចំពោះកិច្ចសន្យាដែលខ្លួនបានធ្វើ និងការខាតបង់ទាំងឡាយដែលខ្លួនទទួលរងនៅក្នុងការប្រតិបត្តិពាណិជ្ជកិច្ចសម្រាប់ក្រុមហ៊ុននោះ ។

**មាត្រា ២៩.-**

មាត្រា ២៨ នៃច្បាប់នេះអនុវត្តនៅពេលដែល :

ក-សហកម្មសិទ្ធិករទូទៅ ក្នុងនាមខ្លួនឯងផ្ទាល់ និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួមគ្នា ជាម្ចាស់បំណុលនៃកូនបំណុលតែមួយ ។

ខ-បំណុលទាំងពីរនឹងត្រូវសង ។

គ-កូនបំណុលត្រូវសងទៅសហកម្មសិទ្ធិករទូទៅ ប៉ុន្តែមិនសងទៅក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទេ ។ ក្នុងករណីនេះ ចំនួននៃប្រាក់សំណងដែលសហកម្មសិទ្ធិករទូទៅទទួល ត្រូវបែងចែកទៅតាមសមាមាត្រទៅនឹងបំណុលផ្ទាល់ខ្លួន និងបំណុលចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

**មាត្រា ៣០.-**

រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្ម-សិទ្ធិទូទៅបាន លុះត្រាតែសហកម្មសិទ្ធិករទូទៅនោះ ប្រើប្រាស់ក្នុងប្រយោជន៍របស់ក្រុមហ៊ុន ។

រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានក្នុងលក្ខណៈជាការប្រើប្រាស់ផ្ទាល់ខ្លួន លុះត្រាតែសហកម្មសិទ្ធិករទូទៅនោះមានការយល់ព្រមជាឯកច្ឆន្ទពីគ្រប់សហកម្មសិទ្ធិករទូទៅផ្សេងទៀត ។

រាល់សហកម្មសិទ្ធិករទូទៅ ត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅក្នុងករណីមិនប៉ះពាល់ដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀត ដែលប្រើប្រាស់ទ្រព្យសម្បត្តិនោះ ។

**មាត្រា ៣១.–**

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយអាចក្លាយជាសហកម្មសិទ្ធិករទូទៅដោយគ្មានការយល់ព្រមជាឯកច្ឆន្ទ ពីគ្រប់សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានឡើយ ។

សហកម្មសិទ្ធិករទូទៅម្នាក់ អាចប្រគល់សិទ្ធិឱ្យទៅបុគ្គលផ្សេង ដើម្បីទទួលប្រាក់កាសជំនួសខ្លួនបាន ដោយមិនចាំបាច់មានការយល់ព្រមពីសហកម្មសិទ្ធិករទូទៅដទៃទៀតឡើយ ។ ការប្រគល់សិទ្ធិបែបនេះ មិនធ្វើឱ្យអ្នកទទួលសិទ្ធិនោះក្លាយទៅជាសហកម្មសិទ្ធិករទូទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទេ ។

**មាត្រា ៣២.–**

សហកម្មសិទ្ធិករទូទៅម្នាក់ អាចផ្ទេរអត្ថប្រយោជន៍របស់ខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបាន ដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

**មាត្រា ៣៣.–**

ភាគទុនជាទ្រព្យ ឬ ប្រាក់ចំណេញរបស់សហកម្មសិទ្ធិករទូទៅណាម្នាក់នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចត្រូវបានប្រើប្រាស់ជាទ្រព្យធានានូវកាតព្វកិច្ចផ្ទាល់ខ្លួនរបស់សហកម្មសិទ្ធិករទូទៅនោះ ។ ទ្រព្យធានានោះ ត្រូវមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

ការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព ។

**មាត្រា ៣៤.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយអាចធ្វើសេចក្តីសម្រេចអំពីសិទ្ធិរបស់ខ្លួននៅក្នុងការគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

**មាត្រា ៣៥.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយ អាចតែងតាំងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ឬ បុគ្គលដែលមិនមែនជាសហកម្មសិទ្ធិករទូទៅ ឱ្យគ្រប់គ្រងកិច្ចការជំនួសខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះបាន ។

អ្នកគ្រប់គ្រងអាចអនុវត្តរាល់សកម្មភាពនៅក្នុងសិទ្ធិអំណាចរបស់ខ្លួនដរាបណាអ្នកគ្រប់គ្រងនោះមិនប្រព្រឹត្តអំពើក្លែងបន្លំ ។ ការប្រព្រឹត្តរបស់អ្នកគ្រប់គ្រងត្រូវជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

អ្នកគ្រប់គ្រងត្រូវបានដកហូតចេញពីមុខតំណែងដោយសំឡេងភាគច្រើនដោយប្រៀបនៃវត្តមានរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយក្នុងពេលបោះឆ្នោត លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ៣៦.-**

នៅពេលដែលបុគ្គលច្រើនរូបត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងក្រុមហ៊ុន អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់ៗ អាចអនុវត្តសកម្មភាពដាច់ដោយឡែកពីគ្នាបាន លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ៣៧.-**

សហកម្មសិទ្ធិករទូទៅត្រូវបានចាត់ទុកថាមានសិទ្ធិគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

សកម្មភាពដែលបានអនុវត្តដោយសហកម្មសិទ្ធិករទូទៅម្នាក់ ដែលទាក់ទងទៅនឹងសកម្មភាពរួមរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវជាប់កាតព្វកិច្ចទៅនឹងសហកម្មសិទ្ធិករទូទៅផ្សេងទៀតដែរ ។

**មាត្រា ៣៨.-**

រាល់សហកម្មសិទ្ធិករទូទៅមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ហើយការអនុវត្តសិទ្ធិនោះមិនត្រូវបានបង្អាក់ដោយសារកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រាល់សេចក្តីសម្រេចត្រូវធ្វើឡើងដោយការបោះឆ្នោតតាមសំឡេងភាគច្រើនដោយប្រៀបរបស់សហកម្មសិទ្ធិករទូទៅ ដោយមិនគិតតម្លៃអត្ថប្រយោជន៍របស់គេនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ។ ប៉ុន្តែសេចក្តីសម្រេចក្នុងការកែប្រែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវធ្វើឡើងដោយសំឡេងឆ្នោតជាឯកច្ឆន្ទ ។

**មាត្រា ៣៩.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗមានសិទ្ធិទទួលព័ត៌មានអំពីកិច្ចការទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិពិគ្រោះយោបល់លើសៀវភៅបញ្ជី និងកំណត់ហេតុ ទោះបីជាសហកម្មសិទ្ធិករទូទៅនោះគ្មានតួនាទីជាអ្នកគ្រប់គ្រងក៏ដោយ ។

នៅក្នុងការអនុវត្តសិទ្ធិនេះ សហកម្មសិទ្ធិករទូទៅមិនត្រូវបង្អាក់កិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុនដោយគ្មានហេតុផលត្រឹមត្រូវ ឬ មិនត្រូវធ្វើឱ្យរាំងស្ទះដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀតក្នុងការអនុវត្តសិទ្ធិដូចគ្នាឡើយ ។

## គ_ ទំនាក់ទំនងនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅជាមួយតតិយជន

### មាត្រា ៤០._

សហកម្មសិទ្ធិករទូទៅម្នាក់ៗគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ ហើយសហកម្មសិទ្ធិករទូទៅទាំងនោះត្រូវជាប់កាតព្វកិច្ចចំពោះក្រុមហ៊ុននូវរាល់អំពើដែលខ្លួនបានអនុវត្ត ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

ការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវបានចាត់ទុកជាគ្មានប្រសិទ្ធភាព ។

### មាត្រា ៤១._

សហកម្មសិទ្ធិករទូទៅម្នាក់ដែលបានចុះកិច្ចសន្យាជាមួយតតិយជន ត្រូវបានជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលណាដែលកាតព្វកិច្ចនោះស្ថិតក្នុងវង្វង់អាជីវកម្មរបស់ក្រុមហ៊ុន ឬ នៅពេលណាដែលកម្មវត្ថុនៃកិច្ចសន្យានោះជាទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

### មាត្រា ៤២._

សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវកាតព្វកិច្ចទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

តតិយជនត្រូវទាមទារការអនុវត្តកាតព្វកិច្ចបំណុល ឬ ទ្រព្យសម្បត្តិពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅសិន មុននឹងទាមទារពីសហកម្មសិទ្ធិករទូទៅ ។

### មាត្រា ៤៣._

បុគ្គលណាដែលចូលជាសហកម្មសិទ្ធិករទូទៅ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលកើតរួចហើយ ត្រូវទទួលខុសត្រូវចំពោះបំណុលទាំងអស់ ដែលកើតឡើងដោយសារក្រុមហ៊ុន មុនពេលដែលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅដូចដែលខ្លួនជាសហកម្មសិទ្ធិករទូទៅនៅពេលបំណុលនោះកើតឡើងដែរ ។ ប៉ុន្តែបំណុលទាំងឡាយ

ណាដែលបានកើតឡើងមុនពេលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅ បំណុលនោះអាចត្រូវបានចេញសងដោយទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយមិនត្រូវបានចេញសងដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បុគ្គលនោះឡើយ លើកលែងតែបុគ្គលនោះមានការព្រមព្រៀងផ្សេងនៅក្នុងលិខិតជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៤៤.—**

ការជូនដំណឹងទៅសហកម្មសិទ្ធិករទូទៅណាម្នាក់ ឬ ការដឹងឮរបស់សហកម្មសិទ្ធិ-ករទូទៅណាម្នាក់ដែលពាក់ព័ន្ធទៅនឹងការងាររបស់ក្រុមហ៊ុន ត្រូវចាត់ទុកថាជាសេចក្ដីជូនដំណឹង និងការដឹងឮដល់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះដែរ លើកលែងតែមានការក្លែងបន្លំ ដែលប្រព្រឹត្តឡើងដោយការឃុបឃិតពីសហកម្មសិទ្ធិករទូទៅនោះចំពោះក្រុមហ៊ុន ។

**មាត្រា ៤៥.—**

បុគ្គលណាម្នាក់ដែលធ្វើឱ្យបុគ្គលផ្សេងទៀតជឿទុកចិត្តដោយផ្ទាល់ ឬ ដោយប្រយោលថាខ្លួនជាសហកម្មសិទ្ធិករទូទៅ ប៉ុន្តែការពិតបុគ្គលនោះមិនមែនជាសហកម្ម-សិទ្ធិករទូទៅទេ ត្រូវទទួលខុសត្រូវចំពោះតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយដោយស្មោះត្រង់ដូចសហកម្មសិទ្ធិករទូទៅពិតៗដែរ ។

ក្នុងករណីមានបុគ្គលក្លែងបន្លំ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនទទួលខុសត្រូវចំពោះតតិយជនណាឡើយ លើកលែងតែក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះមិនបានចាត់វិធានការដើម្បីការពារតតិយជននោះ ក្រោយពេលដែលក្រុមហ៊ុនបានដឹងថាមានការក្លែងបន្លំហើយ ។

**មាត្រា ៤៦.—**

សហកម្មសិទ្ធិករទូទៅណាម្នាក់ ដែលមិនបានប្រកាសចេញមុខដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួលស្គាល់ថាជាសហកម្ម-សិទ្ធិករទូទៅកំបាំងមុខ ។ សហកម្មសិទ្ធិករទូទៅនោះ ត្រូវទទួលខុសត្រូវចំពោះតតិយ

ជនទាំងឡាយនូវរាល់កាតព្វកិច្ច ដូចសហកម្មសិទ្ធិករទូទៅទាំងឡាយដែលបានប្រកាសចេញមុនដែរ ។

**មាត្រា ៤៧.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនអាចបោះចេញ ឬ បែងចែកមូលបត្រ ឬ ប័ណ្ណដែលអាចលក់ដូរបានទៅឱ្យសាធារណជនឡើយ ។

កិច្ចសន្យាដែលចូលជាធរមានទៅក្នុងការបោះចេញមូលបត្រ ឬ ប័ណ្ណដែលធ្វើឡើងផ្ទុយពីមាត្រានេះត្រូវចាត់ទុកជាមោឃៈ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវសងនូវការខូចខាតទាំងឡាយដែលបង្កឡើងពីមោឃភាពនៃកិច្ចសន្យាមូលបត្រ ឬ ប័ណ្ណទៅឱ្យតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ ។

## ឃ- ការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ

**មាត្រា ៤៨.-**

បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលដែលបុគ្គលនោះ :

- បានផ្ទេរផលប្រយោជន៍របស់ខ្លួន
- បានទទួលមរណភាព
- ត្រូវបានដាក់ក្រោមការពិនិត្យអង្កេតពេលក្ស័យធន
- បានអនុវត្តសិទ្ធិដើម្បីដកខ្លួនចេញ
- ត្រូវបានបណ្តេញចេញពីក្រុមហ៊ុន
- បានទទួលសាលក្រមតុលាការអនុញ្ញាតឱ្យដកខ្លួនចេញ ឬ បញ្ជាឱ្យរឹបអូសអត្ថប្រយោជន៍របស់បុគ្គលនោះ ។

**មាត្រា ៤៩.-**

បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ បង្កឱ្យមានការរំលាយជាស្វ័យប្រវត្តិនូវក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ លើកលែងតែកិច្ចសន្យាចែងផ្សេងពីនេះ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចបន្តសកម្មភាពទៅបាន ដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ និងដោយការអនុវត្តលក្ខខណ្ឌតម្រូវនៃការតម្កល់ទុក និងការចុះបញ្ជី ដើម្បីបង្ហាញអំពីការកែប្រែនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

ប្រសិនបើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ កិច្ចសន្យានោះត្រូវធ្វើការកែប្រែឱ្យស្របតាមនោះដែរ ។

**មាត្រា ៥០.-**

បុគ្គលណាមួយដែលអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រៅពីដោយសារការផ្ទេរ ឬដោយសារការរឹបអូស អត្ថប្រយោជន៍របស់ខ្លួនបុគ្គលនោះអាចទទួលនូវតម្លៃណាមួយនៃអត្ថប្រយោជន៍របស់ខ្លួន អំពីការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនេះបាន ។ សហកម្មសិទ្ធិករទូទៅដទៃទៀត ត្រូវបង់ការចំណាយជាចាំបាច់ដល់បុគ្គលនោះ នូវតម្លៃណាមួយដែលអាចធ្វើទៅបានដោយឆាប់រហ័សជាមួយនិងការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ ។

តម្លៃនៃអត្ថប្រយោជន៍ត្រូវបានកំណត់ ដូចដែលមានចែងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ឬកិច្ចសន្យាក្នុងចំណោមសហកម្មសិទ្ធិករទូទៅទាំងឡាយ ។

បើមិនដូច្នោះទេ តម្លៃនោះត្រូវកំណត់ដោយអ្នកឯកទេសដែលបានជ្រើសតាំងដោយសហកម្មសិទ្ធិករទូទៅទាំងឡាយ ឬដោយតុលាការ ។

**មាត្រា ៥១.-**

សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរួមគ្នាបង្កើតឡើងដោយមានអាយុកាលមិនកំណត់ ឬកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលមាន

ចែងអំពីការបម្រុងទុកនូវសិទ្ធិដកខ្លួន សហកម្មសិទ្ធិករទូទៅនោះអាចដកខ្លួនចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបាន តាមការជូនដំណឹងអំពីការដកខ្លួនដោយសុទ្ធចិត្ត ។

សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរួមគ្នាបង្កើតឡើងដោយមានអាយុកាលកំណត់ អាចដកខ្លួនចេញបាន តែក្នុងករណីមានការយល់ព្រមពីមតិភាគច្រើនដាច់ខាតរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយ បើមិនដូច្នោះទេលុះត្រាតែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចែងផ្សេងពីនេះ ។

**មាត្រា ៥២.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយអាចបណ្តេញចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនូវសហកម្មសិទ្ធិករទូទៅ ដែលខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ឬ ដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ តាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលមានការជំទាស់ សហកម្មសិទ្ធិករទូទៅទាំងឡាយអាចស្នើសុំការអនុញ្ញាតពីតុលាការ ដើម្បីដកសហកម្មសិទ្ធិករទូទៅនោះចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ តុលាការអាចអនុញ្ញាតនូវការស្នើសុំនោះបាន លុះត្រាតែតុលាការពិចារណាឃើញថាការសុំដកចេញនោះសមស្រប ហើយចេញដីកាផ្អែកទៅតាមកំហុសរបស់សហកម្មសិទ្ធិករទូទៅ ។

## ១_ ការរំលាយ និង ការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**មាត្រា ៥៣.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវរំលាយដោយមូលហេតុដូចខាងក្រោម :

ក-មូលហេតុដែលមានចែងក្នុងកិច្ចសន្យា

-គោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់

-គ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត

-តាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ

ខ- តុលាការអាចរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានតាមមូលហេតុស្របច្បាប់ ។ នៅពេលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានរំលាយ ក្រុមហ៊ុននោះអាចធ្វើការជម្រះបញ្ជីបាន ។

**មាត្រា ៥៤.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានបង្កើតឡើងដោយមានកាលកំណត់មួយនៃកិច្ចសន្យា អាចពន្យារបន្តសកម្មភាពរបស់ខ្លួនបានដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

**មាត្រា ៥៥.-**

ការទទួលដាក់រួមនូវអត្ថប្រយោជន៍ទាំងអស់ទៅក្នុងដៃសហកម្មសិទ្ធិករទូទៅតែម្នាក់ មិនមែនជាមូលហេតុនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ដរាបណាមានបុគ្គលណាមួយផ្សេងទៀតក្លាយជាសហកម្មសិទ្ធិករទូទៅ ក្នុងអំឡុង ១២០ (មួយរយម្ភៃ)ថ្ងៃ គិតចាប់ពីថ្ងៃដែលអត្ថប្រយោជន៍នោះដាក់បញ្ចូលគ្នា ។

**មាត្រា ៥៦.-**

សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅដែលធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវចប់ នៅពេលដែលក្រុមហ៊ុននោះត្រូវបានរំលាយ លើកលែងតែចំពោះសកម្មភាពទាំងឡាយណាដែលជាវិបាកដ៏ចាំបាច់នៃពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដែលបានធ្វើពុំទាន់ចប់សព្វគ្រប់ ។ ប៉ុន្តែរាល់កិច្ចការដែលបានធ្វើជាប្រក្រតីក្នុងក្រុមហ៊ុនដោយសហកម្មសិទ្ធិករទូទៅ ដែលមិនបានដឹងជាមុនអំពីការរំលាយក្រុមហ៊ុននោះ ហើយនៅតែធ្វើសកម្មភាពដោយស្មោះត្រង់ សហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចជាមួយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិករទូទៅដទៃទៀត ដូចដែលក្រុមហ៊ុននោះនៅជាធរមាននៅឡើយ ។

**មាត្រា ៥៧.-**

ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនប៉ះពាល់ទៅនឹងសិទ្ធិតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយដោយស្មោះត្រង់ និងមិនប៉ះពាល់ទៅនឹងបុគ្គលណាមួយដែលបានចុះកិច្ចសន្យាជាមួយសហកម្មសិទ្ធិករទូទៅ ឬ មិនប៉ះពាល់ទៅនឹងភ្នាក់ងារណាម្នាក់ដែលធ្វើកិច្ចការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

**មាត្រា ៥៨.-**

នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ បន្តរហូតដល់ចប់នូវការជម្រះបញ្ជីរបស់ក្រុមហ៊ុននោះ ។

**មាត្រា ៥៩.-**

សហកម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ តាមទម្រង់បែបបទដែលបានកំណត់ និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជីផង ។

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤(បួន)សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបោះពុម្ព ឬ ផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅទីនោះ ឬ នៅក្នុងការផ្សព្វផ្សាយផ្សេងទៀតដូចមានចែងក្នុងបទបញ្ញារបស់ក្រសួងពាណិជ្ជកម្ម ។ លិខិតជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវមានចែងក្នុងបទបញ្ញារបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៦០.-**

នៅពេលធ្វើការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ សិទ្ធិក្នុងការកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវប្រគល់ឱ្យអ្នកជម្រះបញ្ជី ។

អ្នកជម្រះបញ្ជីត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកចាត់ចែងលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ អ្នកជម្រះបញ្ជីត្រូវបានផ្តល់សិទ្ធិពេញលេញក្នុងការចាត់ចែងទាំងមូល ។

អ្នកជម្រះបញ្ជីមានសិទ្ធិទាមទារពីសហកម្មសិទ្ធិករទូទៅទាំងអស់នូវឯកសារនានា និងការបកស្រាយដែលពាក់ព័ន្ធដល់សិទ្ធិ និងកាតព្វកិច្ចនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ៦១.-**

អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិទៅសងបំណុលបៀវត្សបុគ្គលិក បំណុលពន្ធរបស់រដ្ឋ និងបំណុលផ្សេងទៀតទៅតាមសិទ្ធិបុរិមាជាមុន រួចទើបធ្វើការបែងចែកភាគទុន ។

អ្នកជម្រះបញ្ជីត្រូវធ្វើការកាត់ចំណែកទ្រព្យសម្បត្តិដែលនៅសេសសល់ ឱ្យទៅសហកម្មសិទ្ធិករទូទៅទាំងឡាយទៅតាមសមាមាត្រស្មើៗគ្នា ប្រសិនបើគ្មានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ។

ក្នុងករណីដែលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានរួមទាំងទ្រព្យសម្បត្តិរបស់តតិយជនផង អ្នកជម្រះបញ្ជីត្រូវតែបង្វិលទ្រព្យសម្បត្តិរបស់តតិយជនទៅឱ្យតតិយជននោះវិញ ។

**មាត្រា ៦២.-**

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរហូតដល់រយៈពេល ១០(ដប់)ឆ្នាំ ចាប់ពីពេលដែលបានជម្រះបញ្ជីរួច ។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះតម្រូវឱ្យទុកជាភស្តុតាង ។

**មាត្រា ៦៣.-**

ការជម្រះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ចប់ដោយធ្វើការតម្កល់ទុកនូវសេចក្តីជូនដំណឹងអំពីការបិទបញ្ជីនោះ នៅក្រសួងពាណិជ្ជកម្មតាមបែបបទដែលបានកំណត់ទុក ។ ការតម្កល់ទុកឯកសារនេះគឺជាការលុបចោលនូវនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

# <u>កិច្ចសន្យាក្រុមហ៊ុនសិទ្ធិទូទៅ</u>

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**កិច្ចសន្យា**
**ម៉ូវ គន្ធា ហាន់ណា ហ្គាយ ស.ឧ**
**MOV KUNTHEA HANNA GUY GENERAL PARTNERSHIP**

កិច្ចសន្យាសហកម្មសិទ្ធិទូទៅនេះគឺត្រូវបានធ្វើឡើងនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧ រវាង៖
ដែលមាន អត្តសញ្ញាណប័ណ្ណ អាសយដ្ឋាននៅភូមិ តាអង្គ សង្កាត់ត្រើយកោះ ស្រុកកំពង់បាយ ខេត្តកំពត ព្រះរាជាណាចក្រកម្ពុជា និង
ដែលមានកាន់លិខិតឆ្លងដែនលេខ អស័យដ្ឋានអចិន្ត្រៃនៅ 4Blackwood Parade, Burnie Tasmania, 7320, Australia និងទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ៣៥E0 ផ្លូវផ្សារចាស់ ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុង កំពត ខេត្តកំពត ព្រះរាជាណាចក្រកម្ពុជា។

## ឈ្មោះ និងពាណិជ្ជកម្ម

ភាគីទាំងពីរបានព្រមព្រៀងបង្កើតទម្រង់ពាណិជ្ជកម្មសហកម្មសិទ្ធិទូទៅមួយដោយដាក់ឈ្មោះថា **ម៉ូវ គន្ធា ហាន់ណា ហ្គាយ ស.ឧ/ MOV KUNTHEA HANNAGUY GENERAL PARTNERSHIP** ដើម្បីធ្វើពាណិជ្ជកម្មទៅលើការផលិតសំលៀកបំពាក់។
ការិយាល័យកណ្តាលនៃការធ្វើពាណិជ្ជកម្មនេះគឺស្ថិតនៅកាច់ជ្រុងផ្លូវលេខ ៣៣ និង ៧៣៦ ភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត ព្រះរាជាណាចក្រកម្ពុជា។

## អាណត្តិរបស់ពាណិជ្ជកម្ម

កិច្ចសន្យាសហកម្មសិទ្ធិទូទៅនេះនឹងមានសុពលភាពចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧ ហើយនឹងបន្តរហូតដល់កិច្ចសន្យាសហកម្មសិទ្ធិទូទៅនេះត្រូវបានបញ្ចប់។

## ដើមទុនធ្វើពាណិជ្ជកម្ម

ដើមទុននៃកិច្ចសន្យាសហកម្មសិទ្ធិទូទៅនេះគឺត្រូវបានបែងចែកជាថវិកាសុទ្ធដោយដៃគូធ្វើពាណិជ្ជកម្មដែលមានដើមទុនសរុបចំនួន១៦៨,៨០០,០០០ រៀល =($ ៤២,២០០, អត្រា៤០០០រៀល)
( មួយរយ ហុកសិប ប្រាំបីលាន ប្រាំបីសែន រៀល ស្មើនឹង បួនមឺន ពីរពាន់ ពីររយ ដុល្លារ )
ដែលបានភាគទុនដូចខាងក្រោម៖

-ម៉ូវ គន្ធា ដើមទុន ( ៥១ % ) = ៨៦,០៨៨,០០០រៀល= $ ២១,៥២២(ប៉ែតសិបប្រាំមួយលាន ប្រាំបីម៉ឺន ប្រាំបីពាន់ រៀល ស្មើនឹង ពីរម៉ឺន មួយពាន់ ប្រាំរយ ម្ភៃពីរ ដុល្លារ)

-Hanna Rachel Guy ដើមទុន ( ៤៩ %)= ៨២,៧១២,០០០រៀល=$ ២០,៦៧៨ (ប៉ែតសិបពីរលាន ប្រាំពីរសែន មួយម៉ឺន ពីរពាន់រៀល ស្មើរនឹង ពីរម៉ឺន ប្រាំមួយរយ ចិតសិប ប្រាំបី ដុល្លារ)

គណនីដើមទុនដាច់ដោយឡែកនឹងត្រូវបានរក្សាទុកដោយដៃគូនីមួយៗ។ មិនមានដៃគូណាក្នុងចំណោមដៃគូទាំងពីរមានសិទ្ធិដកផ្នែកណាមួយនៃដើមទុនគណនីរបស់គាត់ឡើយ។ ដោយផ្អែកទៅលើតម្រូវការរបស់ភាគីទាំងពីរ គណនីដើមទុននៃសហកម្មសិទ្ធិទូទៅទាំងពីរ នឹងត្រូវបានរក្សាទុកគ្រប់ពេលក្នុងសមមាត្រដែលសហកម្មសិទ្ធិទូទៅបែងចែកនូវប្រាក់ចំណេញរបស់ភាគីទាំងពីរ។

## ប្រាក់ចំណេញ និងខាតបង់

ដៃគូនីមួយៗជាដំបូងនឹងទទួលបានការបែងចែកប្រាក់ខែស្មើភាពគ្នាដោយយោងទៅតាមកិច្ចសន្យារៀងៗខ្លួនជាមួយ **ម៉ូវ គន្ធា ហាន់ណា ហ្គាយ ស.ឧ/ MOV KUNTHEA HANNA GUY GENERAL PARTNERSHIP** ទៅនឹងការចូលរួមចំណែកម្នាក់ៗ។ប្រាក់ចំណេញសុទ្ធ ( ចំណេញទាំងអស់ )នៃសហកម្មសិទ្ធិទូទៅបន្ទាប់ពីការបែងចែកប្រាក់ចំណេញស្មើគ្នានឹងត្រូវចែកគ្នាដោយស្មើ រវាងសហកម្មសិទ្ធិទូទៅ និងប្រាក់ខាតបង់ទាំងអស់ នឹងត្រូវដាក់បន្ថែមទៀតដោយស្មើភាពរបស់ភាគីទាំងពីរ។ គណនីចំណូលដាច់ដោយឡែកមួយ នឹងត្រូវបានរក្សាទុកសម្រាប់ភាគីនីមួយៗ។ ប្រាក់ចំណេញនិងការខាតបង់ សហកម្មសិទ្ធិទូទៅនឹងត្រូវគិតចូលទៅក្នុងគណនីប្រាក់ចំណូលដាច់ដោយឡែករបស់ភាគីនីមួយៗ។ ប្រសិនបើសហកម្មសិទ្ធិទូទៅណាម្នាក់មិនមានសមតុល្យសាច់ប្រាក់នៅក្នុងគណនីប្រាក់ចំណូលរបស់គាត់ទេ ប្រាក់ខាតបង់នឹងត្រូវគិតបញ្ចូលជាមួយនឹងគណនីដើមទុន។

## ប្រាក់បៀវត្ស៍ និង ការដកប្រាក់

មិនមានដៃគូណាម្នាក់នឹងទទួលបានប្រាក់បៀវត្ស៍ចំពោះសេវាកម្មដែលបានផ្តល់ចំពោះសហកម្មសិទ្ធិទូទៅទេ។ យូរៗម្តង ដៃគូនីមួយៗអាចនឹងដកសមតុល្យសាច់ប្រាក់ក្នុងគណនីរបស់គាត់បាន។

## ភាគទុន

មិនមានភាគទុនដែលនឹងត្រូវបង់ថ្លៃទៅលើការចូលរួមភាគទុនដំបូងនៃការធ្វើសហកម្មសិទ្ធិទូទៅទេ ឬការចូលរួមដើមទុនបន្តបន្ទាប់នៃសហកម្មសិទ្ធិទូទៅទេ។

## ការកិច្ចក្នុងការគ្រប់គ្រង និងលក្ខខណ្ឌ

ដៃគូទាំងពីរនឹងមានសិទ្ធិស្មើគ្នាក្នុងការគ្រប់គ្រងពាណិជ្ជកម្មសហកម្មសិទ្ធិទូទៅនេះ ហើយដៃគូនីមួយៗនឹងមានភក្តីភាពលះបង់ពេលវេលាទាំងអស់របស់គាត់ដើម្បីដឹកនាំអាជីវកម្ម។ ដោយគ្មានការព្រមព្រៀងពីភាគីម្ខាងទៀត ដៃគូណាក៏ដោយនឹងមិនអាចឈរជាតំណាងដៃគូរបស់ខ្លួនដើម្បី ខ្ចីលុយ ឬឱ្យលុយខ្ចីឬ ធ្វើ ឬប្រគល់ជូន ឬទទួលយកក្រដាសស្នាមអាជីវកម្ម ឬអនុម័តដាក់បញ្ចាំកិច្ចសន្យាជានា ឬបង់ប្រាក់ជានា ឬជួល ឬទិញ ឬធ្វើកិច្ចសន្យាទិញ ឬលក់ ឬធ្វើកិច្ចសន្យាដើម្បីលក់ទ្រព្យសម្បត្តិណាមួយសម្រាប់ ឬ

Scanned with CamScanner

របស់សហកម្មសិទ្ធិទូទៅជាជាងប្រភេទទ្រព្យសម្បត្តិដែលបានទិញ
និងលក់ទៅតាមតម្លៃទូទៅនៃការធ្វើពាណិជ្ជកម្មរបស់ខ្លួនឡើយ។

## កិច្ចការធនាគារ

រាល់មូលនិធិទាំងអស់របស់សហកម្មសិទ្ធិទូទៅនឹងត្រូវបានដាក់តំកល់ទុកទៅតាមឈ្មោះរបស់វា ដូចជាការពិនិត្យមើលគណនី ឬទុកក្នុងគណនីដែលបានរៀបចំកំណត់ដោយសហកម្មសិទ្ធិទាំងពីរ។ រាល់ការដកប្រាក់ទាំងអស់
ត្រូវបានធ្វើឡើងដោយមានការត្រួតពិនិត្យព្រមទាំងមានចុះហត្ថលេខាដោយសហកម្មសិទ្ធិទូទៅទាំងពីរ។

## ការកត់ត្រា

សៀវភៅកត់ត្រាសហកម្មសិទ្ធិទូទៅនឹងត្រូវបានរក្សាទុក ក្នុងការការិយាល័យកណ្តាលមួយ ហើយដៃគូពាណិជ្ជកម្មនីមួយៗនឹងមានសិទ្ធិចូលទៅការិយាល័យនោះបានគ្រប់ពេលទាំងអស់។ សៀវភៅកត់ត្រាទាំងអស់នឹងត្រូវបានរក្សាទុកជាមូលដ្ឋាននៃឆ្នាំសារពើពន្ធ ការចាប់ផ្តើមដំបូងគឺនៅថ្ងៃទី ០១ ខែ មករា និងបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ហើយនឹងត្រូវបិទ
និងត្រូវបានធ្វើសមតុល្យនៅចុងឆ្នាំសារពើពន្ធនីមួយៗ។

## ការបញ្ចប់ពាណិជ្ជកម្មសហកម្មសិទ្ធិករទូទៅដោយស្ម័គ្រចិត្ត

ភាពជាសហកម្មសិទ្ធិករទូទៅអាចនឹងត្រូវបានរំលាយចោលគ្រប់ពេលដោយកិច្ចសន្យារវាងដៃគូទាំងពីរ ក្នុងពេលដែលភាគីទាំងពីរដំណើរការនីតិវិធីដោយបន្ទាន់សមហេតុសមផលដើម្បីទូទាត់បញ្ចប់ភាពជាសហកម្មសិទ្ធិករទូទៅ។ ឈ្មោះពាណិជ្ជកម្ម និងទ្រព្យសម្បត្តិពាណិជ្ជកម្មនឹងត្រូវបានដាក់លក់។ ទ្រព្យសម្បត្តិក្នុងការធ្វើពាណិជ្ជកម្មនឹងត្រូវប្រើប្រាស់ ហើយនិង បែកចែកតាមវិធីដូចខាងក្រោម៖

(១) បង់ថ្លៃ ឬផ្តល់ជាការបង់ថ្លៃបំណុល និង ការចំណាយទៅលើការជម្រះបំណុល និងកាតព្វកិច្ចផ្សេងៗរបស់ការធ្វើពាណិជ្ជកម្មសហកម្មសិទ្ធិករទូទៅ។

(២) ធ្វើឱ្យគណនីប្រាក់ចំណូលរបស់សហកម្មសិទ្ធិករទូទៅមានភាពស្មើគ្នា

(៣) ទូទាត់សមតុល្យគណនីចំណូលនៃសហកម្មសិទ្ធិករទូទៅ

(៤) ធ្វើឱ្យគណនីដើមទុនរបស់សហកម្មសិទ្ធិករទូទៅមានភាពស្មើគ្នា និង

(៥) ទូទាត់សមតុល្យនៃគណនីដើមទុនរបស់សហកម្មសិទ្ធិករទូទៅ។

## មរណភាព

ដោយផ្អែកទៅគោលការណ៍មរណភាពនៃសហកម្មសិទ្ធិករទូទៅទាំងពីរ សហកម្មសិទ្ធិទូទៅដែលនៅរស់នឹងមានសិទ្ធិទាំងទិញភាគទុននៃមរណជនក្នុងនាមជាសហកម្មសិទ្ធិទូទៅ ឬទាំងមានសិទ្ធិបញ្ចប់កិច្ចសន្យា និងជម្រះទូទាត់ពាណិជ្ជកម្មសហកម្មសិទ្ធិករទូទៅ។ ប្រសិនបើសហកម្មសិទ្ធិទូទៅដែលនៅរស់សម្រេចទិញភាគទុនរបស់មរណជន គាត់នឹងផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរនៃការសម្រេចទិញភាគទុនក្នុងរយៈពេលបី(៣)ខែ បន្ទាប់ពីមរណភាពរបស់សហកម្មសិទ្ធិទូទៅដោយផ្អែកទៅលើអ្នកប្រតិបត្តិការកេរមរតក ឬ អ្នកកាន់កិច្ចការរដ្ឋបាលរបស់មរណជន

Scanned with CamScanner

ឬប្រសិនបើការសម្រេចជ្រើសរើសមិនមានអ្នកតំណាងស្របច្បាប់ដែលត្រូវបានតែងតាំង ដោយផ្អែកទៅលើទាយាទស្របច្បាប់ណាម្នាក់ក្នុងចំណោមទាយាទស្របច្បាប់របស់មរណជនដែលមានអស យង្វានច្បាស់លាស់ចុងក្រោយ។

ប្រសិនបើសហកម្មសិទ្ធិខ្ទង់នៅរស់សម្រេចទិញភាគហ៊ុនរបស់មរណជនក្នុងនាមជាដៃគូ តម្លៃទិញនឹងមានតម្លៃស្មើនឹងគណនីដើមទុនរបស់មរណជនដែលជាកាលបរិច្ឆេទមរណភាពរបស់គាត់ បូកផ្សំជាមួយនឹងគណនីប្រាក់ចំណូលរបស់មរណជន ចុងបញ្ចប់នៃឆ្នាំសារពើពន្ធដំបូង នឹងត្រូវកើនឡើងដោយភាគហ៊ុនរបស់គាត់នៃប្រាក់ចំណេញពីសហកម្មសិទ្ធិខ្ទង់ឬមានការថយចុះដោយភា គហ៊ុនរបស់គាត់នៃការខាតបង់ក្នុងការធ្វើពាណិជ្ជកម្មសហកម្មសិទ្ធិខ្ទង់ចំពោះរយៈពេលពីការចាប់ផ្ដើមនៃឆ្នាំ សារពើពន្ធក្នុងពេលដែលមរណភាពរបស់គាត់បានកើតឡើងរហូតដល់ចុងបញ្ចប់នៃប្រតិទិនខែនៅពេលដែ លមរណភាពរបស់គាត់បានកើតឡើង
និងមានការថយចុះដោយគិតទៅលើការដកប្រាក់ចំពោះគណនីចំណូលរបស់គាត់អំឡុងពេលណាមួយ។ មិនមានប្រាក់កម្រៃណានឹងត្រូវបានធ្វើឡើងសម្រាប់កេរ្តិ៍ឈ្មោះជំនួញ ឈ្មោះអាជីវកម្ម ប័ណ្ណប៉ាតង់ ឬ ទ្រព្យសម្បត្តិអរូបីដទៃទៀតឡើយ
លើកលែងតែទ្រព្យសម្បត្តិទាំងនោះត្រូវបានកត់ត្រាបង្ហាញនៅលើសៀវភៅកត់ត្រាពាណិជ្ជកម្មសហកម្មសិទ្ធិ ខ្ទង់ភ្លាមៗមុនពេលមរណភាពរបស់មរណជន
ប៉ុន្តែទោះជាយ៉ាងណាក៏ដោយសហកម្មសិទ្ធិខ្ទង់ដែលនៅរស់នឹងត្រូវបានផ្ដល់សិទ្ធិឱ្យប្រើប្រាស់យីហោពា ណិជ្ជកម្មសហកម្មសិទ្ធិខ្ទង់បាន។

លើកលែងអ្វីផ្សេងទៀតដែលបានចែង នីតិវិធីដើម្បីជាការខូចខាត និង ការបែងចែកទ្រព្យសម្បត្តិនៃការធ្វើពាណិជ្ជកម្មសហកម្មសិទ្ធិខ្ទង់នឹងដូចគ្នាដូចដែលបានចែងក្នុងចំណុចពា ក់ព័ន្ធទៅនឹងការបញ្ចប់សហកម្មសិទ្ធិ។

**មជ្ឈត្តកម្ម**

ករណីមានជម្លោះ ឬ ការតវ៉ាណាមួយកើតឡើង ឬពាក់ព័ន្ធនឹងកិច្ចសន្យា នេះ ឬ ការបំពានណាមួយកើតឡើង នឹងត្រូវបានដោះស្រាយដោយមជ្ឈត្តកម្មអនុលោមទៅតាមច្បាប់ របស់តុលាការកម្ពុជា និង
ការវិនិច្ឆ័យដោយផ្អែកទៅលើការសម្រេចអាចនឹងត្រូវបានដាក់ស្នើទៅតុលាការណាមួយដែលមានដែនសមត្ថ កិច្ចក្នុងការដោះស្រាយវិវាទ។

បានអនុម័តនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៧

(ហត្ថលេខា)

(ហត្ថលេខា)